# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា



# ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម

# ២០១៦-២០២៥

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧

# មាតិកា

**បញ្ជីអក្សរកាត់** ........ vi
**អារម្ភកថា** ........ vii
**បុព្វកថា** ........ x
**ខ្លឹមសារសង្ខេបប្រតិបត្តិ** ........ xii
**ជំពូកទី១៖ ទិដ្ឋភាពទូទៅ** ........ ១
**១.១ សេចក្តីផ្តើម** ........ ១
**១.២ ស្ថានភាពសេដ្ឋកិច្ច-សង្គម** ........ ២
**១.៣ ស្ថានភាពប្រជាសាស្ត្រ** ........ ៥
**១.៤ ទស្សនទាននៃប្រព័ន្ធគាំពារសង្គម** ........ ៧
១.៤.១ ភាពចាំបាច់នៃប្រព័ន្ធគាំពារសង្គម ........ ៧
១.៤.២ តួនាទីរបស់រាជរដ្ឋាភិបាលនៅក្នុងប្រព័ន្ធគាំពារសង្គម ........ ៨
១.៤.៣ គោលការណ៍គ្រឹះនៃក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ........ ៩
**១.៥ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមកម្ពុជា** ........ ១០
**១.៦ អភិក្រមជាលក្ខណៈវដ្តជីវិតនៃប្រព័ន្ធគាំពារសង្គម** ........ ១១
**១.៧ រចនាសម្ព័ន្ធនៃឯកសារក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម** ........ ១២
**ជំពូកទី២៖ ប្រព័ន្ធជំនួយសង្គម** ........ ១៣
**២.១ ការឆ្លើយតបនឹងគ្រោះអាសន្ន** ........ ១៣
២.១.១ ទិដ្ឋភាពទូទៅ ........ ១៣
២.១.២ បញ្ហាប្រឈម ........ ១៤
២.១.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត ........ ១៤
**២.២ ការអភិវឌ្ឍមូលធនមនុស្ស** ........ ១៤
២.២.១ ទិដ្ឋភាពទូទៅ ........ ១៤
២.២.១.១ ការគាំពារស្ត្រីមានផ្ទៃពោះ និងកុមារ ........ ១៤
២.២.១.២ អាហារូបត្ថម្ភនៅតាមសាលារៀន ........ ១៥
២.២.១.៣ ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា ........ ១៥
២.២.២ បញ្ហាប្រឈម ........ ១៥
២.២.២.១ ការគាំពារស្ត្រីមានផ្ទៃពោះ និងកុមារ ........ ១៥
២.២.២.២ ការផ្តល់អាហារនៅតាមសាលារៀន ........ ១៦
២.២.២.៣ ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា ........ ១៦
២.២.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត ........ ១៦
២.២.៣.១ កម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ និងកុមារ ........ ១៦
២.២.៣.២ កម្មវិធីផ្តល់អាហារនៅតាមសាលារៀន ........ ១៧
២.២.៣.៣ កម្មវិធីអាហារូបករណ៍សម្រាប់ថ្នាក់បឋមសិក្សា និងមធ្យមសិក្សា ........ ១៧
**២.៣ ការបណ្តុះបណ្តាលវិជ្ជាជីវៈ** ........ ១៧

២.៣.១ ទិដ្ឋភាពទូទៅ ...... ១៧
២.៣.២ បញ្ហាប្រឈម ...... ១៨
២.៣.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត ...... ១៨
**២.៤ សុខុមាលភាពរបស់ប្រជាជនងាយរងគ្រោះ** ...... ១៩
២.៤.១ ទិដ្ឋភាពទូទៅ ...... ១៩
២.៤.២ បញ្ហាប្រឈម ...... ១៩
២.៤.២.១ ជនពិការ ...... ១៩
២.៤.២.២ ជនចាស់ជរា ...... ១៩
២.៤.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត ...... ២០
២.៤.៣.១ កម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនពិការ ...... ២០
២.៤.៣.២ កម្មវិធីគាំពារជនចាស់ជរា ...... ២០
**ជំពូកទី៣៖ ប្រព័ន្ធសន្តិសុខសង្គម** ...... ២១
**៣.១ សោធន** ...... ២១
៣.១.១ ទិដ្ឋភាពទូទៅ ...... ២១
៣.១.២ បញ្ហាប្រឈម ...... ២៣
៣.១.២.១ ក្របខ័ណ្ឌស្ថាប័ន ...... ២៣
*ក. លក្ខណៈរាយប៉ាយនៃស្ថាប័នប្រតិបត្តិករ* ...... ២៣
*ខ. អសង្គតិភាពនៃតារាំកាលិក* ...... ២៣
៣.១.២.២ ក្របខ័ណ្ឌហិរញ្ញវត្ថុ ...... ២៤
*ក. សក្តានុពលនៃកំណើនចំណាយយ៉ាងគំហុក* ...... ២៤
*ខ. ការមិនទាន់អនុវត្តនូវអត្រាភាគទាន* ...... ២៥
*គ. បម្រែបម្រួលកត្តាប្រជាសាស្ត្រ* ...... ២៥
៣.១.២.៣ ក្របខ័ណ្ឌច្បាប់ និងត្រួតពិនិត្យ ...... ២៥
៣.១.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត ...... ២៥
៣.១.៣.១ ក្របខ័ណ្ឌស្ថាប័ន ...... ២៦
*ក. ការធ្វើឲ្យមានសង្គតិភាពរវាងរបបសោធនសាធារណៈ* ...... ២៦
*ខ. ការធ្វើឯកភាពរូបនីយកម្មរបបសោធនដែលមានស្រាប់* ...... ២៦
*គ. ការរៀបចំប្រព័ន្ធចាកចេញពីការងារដោយស្ម័គ្រចិត្តសម្រាប់មន្ត្រីរាជការ* ...... ២៦
*ឃ. ការដាក់ឲ្យដំណើរការរបបសោធនសម្រាប់កម្មករនិយោជិត* ...... ២៦
*ង. ការដាក់ឲ្យដំណើរការរបបសោធនសម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលមិនក្រីក្រ* ...... ២៧
*ច. ការដាក់ឲ្យដំណើរការរបបសោធនឯកជនស្ម័គ្រចិត្ត* ...... ២៧
*ឆ. ការសម្រួលសមាជិកភាព* ...... ២៧
៣.១.៣.២ ក្របខ័ណ្ឌហិរញ្ញវត្ថុ ...... ២៨
៣.១.៣.៣ ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ ...... ២៩
**៣.២ ការថែទាំសុខភាព** ...... ២៩

៣.២.១ ទិដ្ឋភាពទូទៅ ..........២៩
៣.២.១.១ ការថែទាំសុខភាពសម្រាប់ជនក្រីក្រ និងសម្រាប់កុមារ ..........២៩
៣.២.១.២ ការធានារ៉ាប់រងសុខភាពតាមសហគមន៍ ..........៣០
៣.២.១.៣ ការធានារ៉ាប់រងសុខភាពក្នុងវិស័យឯកជន..........៣០
៣.២.២ បញ្ហាប្រឈម ..........៣១
៣.២.២.១ ក្របខ័ណ្ឌស្ថាប័ន ..........៣១
*ក. ភាពពាយប៉ាយនៃរបបថែទាំសុខភាព*..........៣១
*ខ. ប្រព័ន្ធថែទាំបឋម និងគុណភាពនៃសេវាសុខាភិបាល*..........៣១
៣.២.២.២ ក្របខ័ណ្ឌហិរញ្ញវត្ថុ ..........៣១
*ក. សមធម៌ក្នុងការប្រើប្រាស់សេវាថែទាំសុខភាព*..........៣១
*ខ. ការថែទាំសុខភាពដោយប្រើប្រាស់ប្រាក់ចេញពីហោប៉ៅ (Out-of-pocket)* ..........៣២
៣.២.២.៣ ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ..........៣២
៣.២.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត..........៣២
៣.២.៣.១ ក្របខ័ណ្ឌស្ថាប័ន ..........៣២
*ក. ការដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់កម្មករនិយោជិត*..........៣២
*ខ. ការដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ* ..........៣៣
*គ. ការបង្កើនគុណភាពសុខាភិបាល* ..........៣៣
*ឃ. ការលើកកម្ពស់ការយល់ដឹងអំពីការថែទាំ និងការការពារសុខភាព*..........៣៣
*ង. យន្តការត្រួតពិនិត្យការទូទាត់សេវាសុខាភិបាល*..........៣៤
*ច. ការសិក្សាសមិទ្ធិលទ្ធភាពលើការធានារ៉ាប់រងបន្ត*..........៣៤
*ឆ. ការគ្រប់គ្រងមូលនិធិសមធម៌ និងមូលនិធិគន្ធបុប្ផា*..........៣៤
*ជ. ការបង្កើនការចូលរួមពីមូលដ្ឋានសុខាភិបាលឯកជន*..........៣៤
*ឈ. ការដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលមិនក្រីក្រ*..........៣៥
៣.២.៣.២ ក្របខ័ណ្ឌហិរញ្ញវត្ថុ ..........៣៥
*ក. គោលការណ៍នៃការធ្វើហិរញ្ញប្បទានទ្រទ្រង់ប្រព័ន្ធថែទាំសុខភាព*..........៣៥
*ខ. ការកំណត់អត្រាភាគទាន* ..........៣៦
*គ. ការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស*..........៣៦
៣.២.៣.៣ ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ ..........៣៦
**៣.៣ ហានិភ័យការងារ**..........៣៧
៣.៣.១ ទិដ្ឋភាពទូទៅ ..........៣៧
៣.៣.២ បញ្ហាប្រឈម ..........៣៧
៣.៣.២.១ របបហានិភ័យការងារសម្រាប់កម្មករនិយោជិត..........៣៧
៣.៣.២.២ របបហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ..........៣៧
៣.៣.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត ..........៣៨
៣.៣.៣.១ របបហានិភ័យការងារសម្រាប់កម្មករនិយោជិត ..........៣៨
៣.៣.៣.២ របបហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ..........៣៨

**៣.៤ និកម្មភាព** ......៣៨
៣.៤.១ ទិដ្ឋភាពទូទៅ......៣៨
៣.៤.២ បញ្ហាប្រឈម......៣៩
៣.៤.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត ......៣៩
**៣.៥ ពិការភាព** ......៣៩
៣.៥.១ ទិដ្ឋភាពទូទៅ......៣៩
៣.៥.២ បញ្ហាប្រឈម......៤០
៣.៥.២.១ ការកំណត់អត្តសញ្ញាណជនពិការ ......៤០
៣.៥.២.២ បញ្ហាហិរញ្ញវត្ថុ ......៤០
៣.៥.២.៣ គុណភាពនៃការស្តារលទ្ធភាពពលកម្ម ......៤០
៣.៥.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត ......៤១
៣.៥.៣.១ កំណែទម្រង់ការកំណត់អត្តសញ្ញាណរបស់ជនពិការ ......៤១
៣.៥.៣.២ ការកំណត់លក្ខខណ្ឌនៃការផ្តល់ការគាំពារ ......៤១
៣.៥.៣.៣ ការជំរុញការចូលរួមវិភាគទានពីវិស័យឯកជន ......៤១
៣.៥.៣.៤ ការបង្កើនគុណភាពស្តារលទ្ធភាពពលកម្មជនពិការ ......៤១
៣.៥.៣.៥ ការបង្កើនការបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ ......៤១
៣.៥.៣.៦ ការធ្វើសមាហរណកម្មការគ្រប់គ្រងមូលនិធិជនពិការ ......៤២
**ជំពូកទី៤៖ អភិបាលកិច្ច** ......៤៣
**៤.១ ទិដ្ឋភាពទូទៅ**......៤៣
**៤.២ បញ្ហាប្រឈម** ......៤៣
**៤.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត**......៤៣
៤.៣.១ កម្រិតគោលនយោបាយ......៤៤
៤.៣.១.១ សមាសភាពនៃក្រុមប្រឹក្សាជាតិគាំពារសង្គម ......៤៤
៤.៣.១.២ មុខងារនៃក្រុមប្រឹក្សាជាតិគាំពារសង្គម......៤៤
៤.៣.២ កម្រិតបញ្ញត្តិករ......៤៤
៤.៣.៣ កម្រិតប្រតិបត្តិករ......៤៥
៤.៣.៣.១ ប្រតិបត្តិករជំនួយសង្គម......៤៥
៤.៣.៣.២ ប្រតិបត្តិករសន្តិសុខសង្គម......៤៥
៤.៣.៣.៣ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ស្ថាប័នប្រតិបត្តិករសន្តិសុខសង្គម......៤៦
*ក. ក្រុមប្រឹក្សាភិបាល*......៤៦
*ខ. គណៈកម្មាធិការដំនាញ*......៤៦
*គ. គោលការណ៍ប្រតិបត្តិ*......៤៦
*ឃ. យន្តការជ្រើសរើសម្ចាស់ផ្លង*......៤៦
**ជំពូកទី៥៖ បញ្ហាឆ្លងវិស័យ** ......៤៨
**៥.១ ការវិនិយោគ** ......៤៨
៥.១.១ ទិដ្ឋភាពទូទៅ ......៤៨

៥.១.២ បញ្ហាប្រឈម ......................................................................................................................៤៨
៥.១.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត........................................................................................៤៨
៥.១.៣.១ ការបន្តផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនបោះផ្សាយ...........................................៤៨
៥.១.៣.២ ជំរុញការអភិវឌ្ឍទីផ្សារសញ្ញាបណ្ណ ..............................................................................៤៩
៥.១.៣.៣ ការរៀបចំគោលការណ៍ណែនាំស្តីពីវិនិយោគ ..................................................................៤៩
៥.១.៣.៤ ការរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងការវិនិយោគមូលនិធិ ...........................................៤៩
៥.២ គោលនយោបាយពន្ធដារ.............................................................................................................៤៩
៥.២.១ ទិដ្ឋភាពទូទៅ..............................................................................................................................៤៩
៥.២.២ បញ្ហាប្រឈម ................................................................................................................................៥០
៥.២.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត.................................................................................................៥០
៥.២.៣.១ របបពន្ធលើការបង់ភាគទានចូលក្នុងរបបសន្តិសុខសង្គម ................................................៥០
៥.២.៣.២ របបពន្ធសម្រាប់ប្រាក់ចំណេញពីការវិនិយោគមូលនិធិ.................................................៥០
៥.២.៣.៣ របបពន្ធសម្រាប់តាវកាលិករបបសន្តិសុខសង្គម ...........................................................៥០
៥.២.៣.៤ របបពន្ធសម្រាប់ការចូលរួមវិភាគទានសប្បុរសធម៌ក្នុងមូលនិធិជំនួយសង្គម ...............៥០
៥.៣ ប្រព័ន្ធចុះបញ្ជី ..............................................................................................................................៥១
៥.៣.១ ទិដ្ឋភាពទូទៅ..............................................................................................................................៥១
៥.៣.២ បញ្ហាប្រឈម ................................................................................................................................៥១
៥.៣.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត ................................................................................................៥១
៥.៤ ការអប់រំ និងផ្សព្វផ្សាយ ................................................................................................................៥២
៥.៤.១ ទិដ្ឋភាពទូទៅ ..............................................................................................................................៥២
៥.៤.២ បញ្ហាប្រឈម.................................................................................................................................៥២
៥.៤.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត .................................................................................................៥២
៥.៤.៣.១ ការលើកកម្ពស់ចំណេះដឹងដោយផ្ទាល់..........................................................................៥២
៥.៤.៣.២ ការលើកកម្ពស់ចំណេះដឹងដោយប្រយោល .....................................................................៥៣
ជំពូកទី៦៖ ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ២០១៦-២០២៥....៥៤
ឧបសម្ព័ន្ធ៖
១. សទ្ទានុក្រម
២. សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៥២ សសរ. ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសសម្រាប់រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ក.ក.ជ | ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | Council for Agriculture and Rural Development |
| គ.ម.ក | គណៈកម្មការមូលបត្រកម្ពុជា | Securities and Exchange Commission of Cambodia |
| ប.ជ.ស | បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល | National Social Security Fund for Civil Servants |
| ប.ជ.អ | បេឡាជាតិអតីតយុទ្ធជន | National Fund for Veterans |
| ប.ស.ស | បេឡាជាតិរបបសន្តិសុខសង្គម | National Social Security Fund |
| ផ.ស.ស | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product |
| ម.ជ.ព | មូលនិធិជនពិការ | People with Disability Fund |
| AFD | ទីភ្នាក់ងារដើម្បីការអភិវឌ្ឍបារាំង | Agence Française De Dévelopment |
| CBHI | ការធានារ៉ាប់រងសុខភាពតាមសហគមន៍ | Community-based Health Insurance |
| DB | របបសោធនប្រភេទកំណត់តាវកាលិកជាមុន | Defined Benefit Pension |
| DC | របបសោធនប្រភេទកំណត់ភាគទានជាមុន | Defined Contribution Pension |
| EU | សហភាពអឺរ៉ុប | European Union |
| GIZ | កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ | Deutsche Gesellschaft für Internationale Zusammenabeit |
| ILO | អង្គការពលកម្មអន្តរជាតិ | International Labour Organization |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន | Japan International Cooperation Agency |
| OOP | ប្រាក់ចេញពីហោប៉ៅ | Out Of Pocket |
| PAYG | ការទូទាត់តាមដំណើរ | Pay As You Go |
| SBP | កម្មវិធីស្ពានចម្លងបន្តជំនាញ | Skill Bridging Program |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | Sustainable Development Goals |
| TVET | ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ | Technical Vocational Education and Training |
| UHC | ប្រព័ន្ធថៃទាំសុខភាពសកល | Universal Health Coverage |
| UNICEF | អង្គការមូលនិធិកុមាររបស់អង្គការសហប្រជាជាតិ | United Nations Children's Fund |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់អភិវឌ្ឍន៍អន្តរជាតិ | United States Agency for International Development |
| VSTP | កម្មវិធីបណ្ដុះបណ្ដាលជំនាញតាមលិខិតបញ្ជាក់ | Voucher Skills Training Program |
| WFP | អង្គការស្បៀងអាហារពិភពលោក | World Food Program |

# អារម្ភកថា

ជានិច្ចជាកាល អាទិភាពគោលនយោបាយចម្បងរបស់រាជរដ្ឋាភិបាលគឺការរក្សាសន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខជាតិដែលជាបុរេលក្ខខណ្ឌដ៏ចាំបាច់ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ចដែលនឹងអនុញ្ញាតឲ្យកម្ពុជាងើបឡើងវិញ ហើយចាប់ផ្តើមការអភិវឌ្ឍជាថ្មីម្តងទៀតពីស្ថានភាពខ្ទេចខ្ទាំគ្រប់វិស័យក្រោមរបបប្រល័យពូជសាសន៍នាឆ្នាំ១៩៧៥-១៩៧៩។ ទន្ទឹមនេះ ចាប់តាំងពីដំណាក់កាលដំបូងនៃការស្តារសេដ្ឋកិច្ចជាតិ ក្នុងគោលបំណងកសាងធនធានមនុស្ស និងលើកកម្ពស់ភាពថ្លៃថ្នូររបស់ប្រជាជនឡើងវិញ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្ពស់ទៅលើសកម្មភាពគាំពារសង្គមនានា។

បន្ទាប់ពីបានទទួលសន្តិភាពពេញលេញនៅទូទាំងប្រទេសនាឆ្នាំ១៩៩៨ កម្ពុជាបានបង្ហាញមុខមាត់ថ្មីប្រកបដោយភាពរឹងប៉ឹង និងវិជ្ជមាន។ ប្រទេសជាតិមានការរីកចម្រើនជាលំដាប់ ក្នុងខណៈបោះជំហានលើមាគ៌ានៃការកសាង និងការអភិវឌ្ឍលើគ្រប់វិស័យ។ ប្រជាជនកម្ពុជាបាននិងកំពុងទទួលផ្លែផ្កាពីសេចក្តីសុខសន្តិភាព ស្ថិរភាពនយោបាយ និងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ក្នុងអត្រាមធ្យមប្រមាណ ៧.៧ ភាគរយ នាអំឡុងពេលពីរទសវត្សកន្លងមកនេះ។ អត្រាភាពក្រីក្រត្រូវបានកាត់បន្ថយពី ៥៣ ភាគរយ នៅឆ្នាំ២០០៤ មក ១៣.៥ ភាគរយ នៅឆ្នាំ២០១៤។ លើសពីនេះទៀត ផ្លែផ្កានៃកំណើនសេដ្ឋកិច្ចក៏ត្រូវបានបែងចែកក្នុងលក្ខណៈកាន់តែមានសមធម៌ ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈការថយចុះនៃមេគុណវិសមភាពនៃការប្រើប្រាស់ពី ០.៤១ នៅឆ្នាំ២០០៧ មកនៅត្រឹម ០.២៩ នៅឆ្នាំ២០១២ ជាមួយនឹងការរំពឹងថាតួលេខនេះនឹងបន្តថយចុះថែមទៀតនៅឆ្នាំខាងមុខ។ សមិទ្ធិផលទាំងនេះគឺជាការពិតដែលមិនអាចបដិសេធបាន និងជាមោទនភាពសម្រាប់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា។ ជាពិសេស បើធៀបទៅនឹងស្ថានភាពសេដ្ឋកិច្ចនិងសង្គមនៅកម្រិតសូន្យ ដែលរាជរដ្ឋាភិបាលបានទទួលមរតកពីឆ្នាំ១៩៧៩ សមិទ្ធិផលនាពេលបច្ចុប្បន្ននេះគឺជាការបោះជំហានដ៏សម្បើមឆ្ពោះទៅរកការសម្រេចបាននូវគោលដៅសម្រាប់រយៈពេលខាងមុខ ការពន្លឿនកំណើនសេដ្ឋកិច្ច ការបង្កើតឱកាសការងារជាអតិបរមា និងការកសាងសង្គមមួយប្រកបដោយសមធម៌ តាមរយៈការផ្តោតទៅលើការអនុវត្ត និងការជំរុញការកែទម្រង់ចាំបាច់នានាលើគ្រប់វិស័យ។ កន្លងមក រាជរដ្ឋាភិបាលបានខិតខំដាក់ឲ្យដំណើរការនិងទ្រទ្រង់គោលនយោបាយសង្គមកិច្ចជាច្រើន។ តាមរយៈនេះ ប្រជាជនកម្ពុជា ជាពិសេស ប្រជាជនក្រីក្រនិងងាយរងគ្រោះទទួលបានការគាំពារក្រោមរូបភាពផ្សេងៗ ក្នុងក្របខ័ណ្ឌនៃការងារគាំពារសង្គមដូចជា ការបង្កើតមជ្ឈមណ្ឌលកុមារកំព្រា មជ្ឈមណ្ឌលជនពិការ មជ្ឈមណ្ឌលគាំពារសុខភាពមាតានិងទារក ការឧបត្ថម្ភចំពោះប្រជាជនក្រីក្រដែលមកសម្រាកព្យាបាលឬសម្រាលកូន និងការផ្តល់ការអប់រំតាំងពីកម្រិតបឋមដល់កម្រិតឧត្តមសិក្សាដោយឥតបង់ថ្លៃជាដើម។ល។ លើសពីនេះ រាជរដ្ឋាភិបាលបានបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិរបបសន្តិសុខសង្គម បេឡាជាតិអតីតយុទ្ធជន និងមូលនិធិជនពិការ ដើម្បីផ្តល់ការធានាសន្តិសុខប្រាក់ចំណូលសម្រាប់ប្រជាជនតាមមុខសញ្ញាពាក់ព័ន្ធនានាមានជាអាទិ៍ ការផ្តល់តាវកាលិកសោធន ថែទាំសុខភាព ហានិភ័យការងារ ពិការភាព

និងតាវកាលិកផ្សេងៗទៀត។ សកម្មភាពទាំងនេះមានសង្គតិភាពទៅនឹងគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងឯកសារគោលនយោបាយសំខាន់ៗ ជាពិសេស យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

សេចក្តីប្រាថ្នា និងការខិតខំរបស់រាជរដ្ឋាភិបាល គឺប្រែក្លាយឋានៈរបស់កម្ពុជាឲ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ក្នុងបរិបទនេះ រាជរដ្ឋាភិបាលទទួលស្គាល់យ៉ាងមុតមាំថា ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមគឺជាកត្តាដ៏សំខាន់ដើម្បីសម្រេចបាន "**កំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងបរិយាប័ន្ន**"។ ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ចំពោះសន្តិសុខប្រាក់ចំណូលរបស់ប្រជាជន រាជរដ្ឋាភិបាលបានកំណត់ចក្ខុវិស័យរយៈពេលវែងសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមគឺ "**ការកសាងប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាប័ន្ន ប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុ ដែលជាឧបករណ៍បម្រើដល់ការកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ហើយរួមចំណែកដល់ការអភិវឌ្ឍ និងគាំពារធនធានមនុស្សកាន់តែទូលំទូលាយ និងជំរុញកំណើនសេដ្ឋកិច្ច**"។

ផ្អែកលើចក្ខុវិស័យនេះ និងឈរលើមូលដ្ឋាននៃស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងវឌ្ឍនភាពក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច-សង្គមកិច្ច ពេលនេះគឺជាវេលាដ៏សមស្របបំផុតក្នុងការរៀបចំ "**ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម**" ដែលមានលក្ខណៈទូលំទូលាយ ដោយផ្តោតលើសសរស្តម្ភពីរគឺ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។

គោលបំណងនៃការរៀបចំឯកសារនេះ គឺដើម្បីកំណត់ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការធានាឲ្យបាននូវសន្តិសុខប្រាក់ចំណូល និងកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ប្រជាជន សំដៅលើកកម្ពស់សុខុមាលភាពនិងសាមគ្គីភាពសង្គម ព្រមទាំង កាត់បន្ថយភាពក្រីក្រជាអតិបរមា។ គោលដៅចម្បងនៃក្របខ័ណ្ឌគោលនយោបាយនេះ គឺធ្វើការបន្សី ប្រមូលផ្តុំ និងពង្រឹងកម្មវិធីដែលមានស្រាប់ ដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព និងសង្គតិភាពនៃរបបឬកម្មវិធីទាំងឡាយក្នុងប្រព័ន្ធគាំពារសង្គមទាំងមូល រួមទាំងការពង្រីកវិសាលភាពដែលនៅតូចចង្អៀតនៅឡើយ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាជនគ្រប់ស្រទាប់ ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ព្រមទាំង រៀបចំឲ្យមានក្របខ័ណ្ឌអភិបាលកិច្ច និងបញ្ហាឆ្លងវិស័យ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រង និងបង្កើនប្រសិទ្ធភាពចំណាយថវិកា។

ក្របខ័ណ្ឌគោលនយោបាយនេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនលទ្ធភាពទទួលបានសេវាជំនួយសង្គម និងសន្តិសុខសង្គម សម្រាប់មន្ត្រីសាធារណៈ និងវិស័យឯកជន ព្រមទាំង ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ដើម្បីសម្រេចបាននូវស្ថានភាពល្អប្រសើរក្នុងការផ្តល់សេវាគាំពារសង្គមសម្រាប់ប្រជាជនកម្ពុជា ដែលឆ្លើយតបចំពោះចក្ខុវិស័យថ្មីនៃប្រព័ន្ធគាំពារសង្គម រាជរដ្ឋាភិបាលនឹងខិតខំបង្កើតកម្មវិធី និងយន្តការនានា ដើម្បីឈានជាបណ្តើរៗទៅរកការគ្របដណ្តប់ដ៏ទូលំទូលាយ។ ទន្ទឹមនឹងនេះ

កិច្ចការចំពោះមុខ គឺការធ្វើកំណែទម្រង់ប្រព័ន្ធគាំពារសង្គម ដែលផ្តោតលើការគាំពារជាពិសេសចំពោះប្រជាជនក្រីក្រនិងងាយរងគ្រោះ និងការកសាងនូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដើម្បីធានាប្រសិទ្ធភាព និងចីរភាពនៃប្រព័ន្ធគាំពារសង្គមទៅអនាគត។

ដើម្បីធានាភាពជាម្ចាស់លើឯកសារដ៏មានសារៈសំខាន់នេះ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ត្រូវបានរៀបចំក្រោមការដឹកនាំនិងសម្របសម្រួលដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធរួមមានៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល ក្រសួងមុខងារសាធារណៈ ក្រសួងផែនការ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងអប់រំ យុវជន និងកីឡា និងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។

ជាការពិតណាស់ ការអនុវត្តគោលនយោបាយគាំពារសង្គមត្រូវការធនធានហិរញ្ញវត្ថុ ធនធានមនុស្សនិងហេដ្ឋារចនាសម្ព័ន្ធស្ថាប័នសមស្រប ដែលជាបញ្ហាប្រឈមសម្រាប់អ្នករៀបចំគោលនយោបាយក៏ដូចជាសម្រាប់ស្ថាប័នអនុវត្ត។ ទោះបីជាដូច្នេះក្តី ខ្ញុំមានការជឿជាក់ថា ជាមួយនឹងការប្តេជ្ញាចិត្តខ្ពស់និងស្មារតីនៃភាពជាម្ចាស់របស់ក្រសួង-ស្ថាប័នរដ្ឋនានា ព្រមទាំងគួបផ្សំជាមួយការគាំទ្រពីដៃគូអភិវឌ្ឍន៍ផងនោះ ភាគីពាក់ព័ន្ធទាំងអស់នឹងធ្វើការក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធដើម្បីដោះស្រាយបញ្ហាប្រឈមទាំងឡាយ សំដៅសម្រេចបាននូវមហិច្ឆតាដែលបានបំផុសនៅក្នុងឯកសារក្របខ័ណ្ឌគោលនយោបាយនេះ។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមនេះនឹងជួយផ្លាស់ប្តូរជាវិជ្ជមានជាលំដាប់នូវកម្រិតជីវភាព និងគុណភាពនៃជីវិតរបស់ប្រជាជនកម្ពុជាគ្រប់រូប។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# បុព្វកថា

ដោយទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពីរាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដឹកនាំរៀបចំឯកសារក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ដែលមានគោលបំណងកំណត់ឲ្យបានច្បាស់លាស់អំពីគោលនយោបាយកំណែទម្រង់ស៊ីជម្រៅលើប្រព័ន្ធនេះ សំដៅធានាសន្តិសុខប្រាក់ចំណូលរបស់ប្រជាជនឲ្យកាន់តែប្រសើរឡើង ព្រមទាំង រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។

ឯកសារក្របខ័ណ្ឌគោលនយោបាយនេះ រៀបចំឡើងដើម្បីសម្រេចគោលដៅ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបីរបស់រាជរដ្ឋាភិបាល គឺ "**ការបន្តអភិវឌ្ឍ និងពង្រឹងប្រព័ន្ធគាំពារសង្គមឲ្យមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព និងប្រសិទ្ធភាព**"។ ឯកសារនេះ បានបង្ហាញឲ្យឃើញពីតថភាពជាក់ស្តែងនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជា និងបានកំណត់ពីបញ្ហាប្រឈមសំខាន់ៗដែលកម្ពុជាបាន និងកំពុងជួបប្រទះ ព្រមទាំងកំណត់គោលដៅយុទ្ធសាស្ត្រ និងផែនការ ដែលត្រូវអនុវត្តទៅតាមដំណាក់កាលខ្លី មធ្យម និងវែង។ ការរៀបចំឯកសារក្របខ័ណ្ឌគោលនយោបាយនេះ បានផ្អែកលើបទពិសោធន៍ និងការអនុវត្តល្អៗពីបណ្តាប្រទេសនានាលើសកលលោក ជាពិសេស ប្រទេសជិតខាង និងបានបញ្ចៀសពីតម្រាប់តាមកំហុសនាអតីតកាល។ ការកំណត់គោលដៅយុទ្ធសាស្ត្រ និងផែនការដែលត្រូវអនុវត្ត ផ្តោតលើគោលការណ៍សំខាន់ៗមួយចំនួនដូចខាងក្រោម៖

១. **កំណែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រងប្រព័ន្ធគាំពារសង្គមទាំងមូល** តាមរយៈការកំណត់ឲ្យបានច្បាស់ពីតួនាទីរបស់ស្ថាប័នពាក់ព័ន្ធ ពោលគឺ កម្រិតគោលនយោបាយ កម្រិតបញ្ញត្តិករ និងកម្រិតប្រតិបត្តិករ

២. **ការបង្កើនប្រសិទ្ធភាពចំណាយថវិការដ្ឋ** តាមរយៈការកែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័នប្រតិបត្តិករ និងការកំណត់យន្តការបង់ភាគទានដើម្បីទ្រទ្រង់គោលនយោបាយអាទិភាពទៅតាមកម្រិតនៃប្រាក់ចំណូលរបស់ប្រជាជន និងទៅតាមលទ្ធភាពទ្រទ្រង់នៃថវិកាជាតិ

៣. **ការពង្រីកវិសាលភាពគ្របដណ្តប់ជាអតិបរមា** ដើម្បីជំរុញឲ្យប្រជាជនគ្រប់រូបទទួលបានការគាំពារផ្អែកលើប្រភេទនៃកម្មវិធី ឬរបបនីមួយៗ និងទៅតាមដំណាក់កាលនៃការអភិវឌ្ឍជាបន្តបន្ទាប់ និង

៤. **ការពិនិត្យលើបញ្ហាឆ្លងវិស័យ** ដើម្បីជំរុញផែនការអភិវឌ្ឍន៍គាំពារសង្គមឲ្យដំណើរការទៅមុខដោយរលូន ចៀសវាងការរាំងស្ទះ ដោយសារភាពយឺតយ៉ាវ ឬភាពអសកម្មនៃដំណើរការអភិវឌ្ឍន៍របស់វិស័យពាក់ព័ន្ធផ្សេងៗ។

ឯកសារនេះ ជាក្របខ័ណ្ឌគោលនយោបាយជាតិ និងជាផែនទីមគ្គុទ្ទេសក៍រយៈពេលវែងសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅប្រទេសកម្ពុជា ដែលបង្ហាញពីចង្កោមសកម្មភាព និងសកម្មភាព តាមលំដាប់លំដោយ និងជាជំហានៗក្នុងដំណាក់កាលខ្លី មធ្យម និងវែង ព្រមទាំងមានការរៀបចំនូវយន្តការតាមដានសមស្របដើម្បីធានាការអនុវត្តប្រកបដោយជោគជ័យ។ ទន្ទឹមនេះ របៀបវារៈនៃកំណែទម្រង់នៅក្រោមក្របខ័ណ្ឌគោលនយោបាយនេះមានលក្ខណៈបត់បែនទន់ភ្លន់ ដែលអនុញ្ញាតឲ្យរាជរដ្ឋាភិបាលអាចធ្វើបច្ចុប្បន្នកម្ម និងកែលម្អគោលនយោបាយ ឬសកម្មភាពចាំបាច់នានា ស្របទៅតាមការវិវឌ្ឍនៃសេដ្ឋកិច្ច និងសង្គម។

ដំណើរការនៃការរៀបចំ "**ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម**" ត្រូវបានទទួលការយកចិត្តទុកដាក់ និងកិច្ចសហការយ៉ាងល្អពីបណ្ដាក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងជួររាជរដ្ឋាភិបាល ព្រមទាំង ពីដៃគូអភិវឌ្ឍន៍ ប្រកបដោយស្មារតីជាម្ចាស់ចំពោះកិច្ចការកែទម្រង់ប្រព័ន្ធគាំពារសង្គមនៅកម្ពុជា។ ផ្អែកលើការខិតខំរបស់គ្រប់ភាគី សេចក្ដីព្រាង "**ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម**" ត្រូវបានបញ្ចប់ជាស្ថាពរ និងបានទទួលការឯកភាពពីគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ និងបានទទួលការអនុម័តនៅក្នុងកិច្ចប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រីក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ**ព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះកិច្ចសហការយ៉ាងរឹងមាំរបស់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលរួមមាន៖ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល ក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមុខងារសាធារណៈ ក្រសួងយុត្តិធម៌ និងក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងជាពិសេស ក្រុមការងារបច្ចេកទេសអន្តរក្រសួងសម្រាប់រៀបចំឯកសារក្របខ័ណ្ឌគោលនយោបាយនេះ ដែលមានអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាលេខាធិការដ្ឋាន។

ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះការជួយជ្រោមជ្រែងយ៉ាងពេញទំហឹងពីដៃគូអភិវឌ្ឍន៍នានា ដូចជា GIZ USAID ILO AFD JICA UNICEF និង EU ដែលនាំឲ្យឯកសារគោលនយោបាយនេះ មានភាពគ្រប់ជ្រុងជ្រោយ និងលេចចេញជារូបរាងឡើង។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មេសា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

# ខ្លឹមសារសង្ខេបប្រតិបត្តិ

ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ គឺជាផែនទីបង្ហាញផ្លូវរយៈកាលវែង ដែលផ្តោតលើសសរស្តម្ភចំនួនពីរគឺ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។ ប្រព័ន្ធជំនួយសង្គម មានជាតុផ្សំចំនួន ៤ រួមមានៈ (១) ការឆ្លើយតបទៅនឹងគ្រោះអាសន្ន (២) ការអភិវឌ្ឍមូលធនមនុស្ស (៣) ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង (៤) សុខុមាលភាពសម្រាប់ប្រជាជនងាយរងគ្រោះ។ ដោយឡែក ប្រព័ន្ធសន្តិសុខសង្គមមានជាតុផ្សំ ៥ គឺៈ (១) សោធន (២) ថែទាំសុខភាព (៣) ហានិភ័យការងារ (៤) និកម្មភាព និង (៥) ពិការភាព។

ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម គឺការកសាងប្រព័ន្ធគាំពារសង្គមមួយដែលមានប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុ ដើម្បីបម្រើដល់គោលនយោបាយកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ហើយរួមចំណែកដល់ការអភិវឌ្ឍនិងគាំពារធនធានមនុស្សឲ្យកាន់តែរឹងមាំ និងទូលំទូលាយ ព្រមទាំង ជំរុញកំណើនសេដ្ឋកិច្ចជាតិ។

គោលបំណងនៃការរៀបចំឯកសារនេះ គឺដើម្បីកំណត់ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការធានាឲ្យបាននូវសន្តិសុខប្រាក់ចំណូល និងកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ប្រជាជន សំដៅលើកកម្ពស់សុខុមាលភាពនិងសាមគ្គីភាពសង្គម ព្រមទាំង កាត់បន្ថយភាពក្រីក្រជាអតិបរមា។

គោលដៅចម្បងនៃក្របខ័ណ្ឌគោលនយោបាយនេះ គឺធ្វើការបន្សុី ប្រមូលផ្តុំ និងពង្រឹងកម្មវិធីដែលមានស្រាប់ ដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព និងសង្គតិភាពនៃរបបឬកម្មវិធីទាំងឡាយក្នុងប្រព័ន្ធគាំពារសង្គមទាំងមូល រួមទាំងការពង្រីកវិសាលភាពដែលនៅតូចចង្អៀតនៅឡើយ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាជនគ្រប់ស្រទាប់ ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ព្រមទាំង រៀបចំឲ្យមានក្របខ័ណ្ឌអភិបាលកិច្ចនិងការពិនិត្យលើបញ្ហាឆ្លងវិស័យ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រងនិងបង្កើនប្រសិទ្ធភាពចំណាយថវិកា។

ប្រព័ន្ធសន្តិសុខសង្គម នឹងជំរុញឲ្យប្រជាជនគ្រប់រូបចូលរួមសន្សំប្រាក់ (បង់ភាគទាន) នៅក្នុងមូលនិធិរួមមួយ ដើម្បីការពារហានិភ័យពីការធ្លាក់ចូលក្នុងភាពក្រីក្រនៅពេលចាស់ជរា និងនៅពេលមានតម្រូវការសេវាថែទាំសុខភាព ព្រមទាំង ហានិភ័យផ្សេងៗទៀត។ ចំពោះក្រុមប្រជាជនក្រីក្រនិងងាយរងគ្រោះដែលគ្មានលទ្ធភាពបង់ភាគទាន រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពក្នុងការបង់ភាគទានជំនួស។

យន្តការកៀរគរភាគទាននៅក្នុងប្រព័ន្ធសន្តិសុខសង្គម នឹងបង្កើតជាប្រភពហិរញ្ញវត្ថុក្នុងស្រុកសម្រាប់ការវិនិយោគទៅលើមូលបត្ររដ្ឋ ដែលទុកលទ្ធភាពឲ្យរាជរដ្ឋាភិបាលអាចយកប្រភពហិរញ្ញវត្ថុនេះទៅធ្វើការវិនិយោគសាធារណៈបាន។ យន្តការនេះ គឺជាមធ្យោបាយដ៏ប្រសើរ ក្នុងការដកខ្លួនចេញពីការពឹងផ្អែកទាំងស្រុងលើហិរញ្ញប្បទានក្រៅប្រទេស ព្រមទាំង ជួយជំរុញការអភិវឌ្ឍទីផ្សារទុនក្នុងស្រុកផងដែរ។

ក្របខ័ណ្ឌគោលនយោបាយនេះ ឆ្លុះបញ្ចាំងពីតថភាពជាក់ស្តែងនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជា និងកំណត់បញ្ហាប្រឈមសំខាន់ៗដែលបាននិងកំពុងជួបប្រទះ ព្រមទាំង កំណត់យុទ្ធសាស្ត្រ និងគោលដៅអនាគត ដែលត្រូវអនុវត្តទៅតាមដំណាក់កាលខ្លី មធ្យម និងវែង ដោយផ្តោតសំខាន់លើទិដ្ឋភាព ៤ គឺ៖ (១) ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ (២) ក្របខ័ណ្ឌស្ថាប័ន (៣) ក្របខ័ណ្ឌហិរញ្ញវត្ថុ និង (៤) ធនធានមនុស្ស។ និន្នាការនៃការវិវឌ្ឍនៅលើសកលលោក និងបទពិសោធន៍ពីបណ្តាប្រទេសនានា ក៏ត្រូវបានលើកយកមកពិភាក្សា និងដាក់បញ្ចូលដោយកែសម្រួលឲ្យស្របទៅនឹងបរិបទកម្ពុជា។

ឯកសារនេះ មានភាពទន់ភ្លន់ អាចកែលម្អបានអាស្រ័យលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈម និងល្បឿននៃការអភិវឌ្ឍឲ្យបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ក. វឌ្ឍនភាព

រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធិផលជាច្រើន និងអនុវត្តកម្មវិធីកំណែទម្រង់ប្រកបដោយជោគជ័យជាបន្តបន្ទាប់ លើប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។ សមិទ្ធិផលសំខាន់ៗរួមមាន៖

- **ប្រព័ន្ធជំនួយសង្គម៖** ការដាក់ឲ្យដំណើរការកម្មវិធីជំនួយសង្គមនានា រួមមាន (១) មូលនិធិសមធម៌ដើម្បីផ្តល់ជូនក្រុមគ្រួសារក្រីក្រនូវការថែទាំសុខភាពដោយឥតបង់ថ្លៃ (២) គម្រោងជំនួយស្បៀងអាហាររបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងកម្មវិធីសន្តិសុខស្បៀងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីដោះស្រាយបញ្ហាអសន្តិសុខស្បៀង (៣) កម្មវិធីផ្តល់អាហារូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះនិងកុមារ ដើម្បីលើកកម្ពស់សុខភាពមាតា និងទារក (៤) កម្មវិធីអាហារូបករណ៍ថ្នាក់បឋមសិក្សា ដើម្បីជំរុញឲ្យមានការចុះឈ្មោះចូលរៀនទាន់ពេលវេលាពីសំណាក់កុមារក្រីក្រ (៥) កម្មវិធីផ្តល់អាហារនៅតាមសាលារៀន ដើម្បីទ្រទ្រង់ការលូតលាស់នៃកាយសម្បទា និងស្មារតីកុមារក្នុងការទទួលយកចំណេះដឹង និង (៦) កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីលើកកម្ពស់ជំនាញវិជ្ជាជីវៈឲ្យឆ្លើយតបទៅនឹងតម្រូវការនៃទីផ្សារពលកម្ម។
- **ប្រព័ន្ធសន្តិសុខសង្គម៖** ការដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមមួយចំនួន រួមមាន៖ បេឡាជាតិរបបសន្តិសុខសង្គម បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិអតីតយុទ្ធជន និងមូលនិធិជនពិការ។ ស្ថាប័នទាំងនេះ មានគោលដៅផ្តល់ការគាំពារសន្តិសុខប្រាក់ចំណូល ដែលអាចបណ្តាលមកពីការឈឺថ្កាត់ គ្រោះថ្នាក់ការងារ ពិការភាព មាតុភាព និងចាស់ជរា ជាដើម សម្រាប់ក្រុមគោលដៅមួយចំនួនដូចជា មន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន ជនពិការ និងកម្មករនិយោជិត។

## ខ. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធិផលទាំងឡាយ ក៏នៅមានបញ្ហាប្រឈមសំខាន់ៗដែលត្រូវដោះស្រាយ ដូចជា៖

- វិសាលភាពគ្របដណ្តប់នៃកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនៅមិនទាន់ទូលំទូលាយនិងគ្របដណ្តប់ពេញលេញ ដែលធ្វើឲ្យក្រុមប្រជាជនមួយចំនួន មិនទាន់ទទួលបានការគាំពារ
- ដំណើរការគ្រប់គ្រងកម្មវិធី និងរបបមិនមានលក្ខណៈប្រមូលផ្តុំ នាំឲ្យមានផលប៉ះពាល់ដល់ប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការបំពេញការងារ និងចំណាយថវិកាខ្ពស់ ព្រមទាំង នាំឲ្យមានអសង្គតិភាពចំពោះអត្ថប្រយោជន៍រវាងក្រុមប្រជាជនគោលដៅផ្សេងៗ
- យន្តការសម្របសម្រួលកម្រិតគោលនយោបាយរវាងស្ថាប័នពាក់ព័ន្ធ និងយន្តការត្រួតពិនិត្យដើម្បីធានាបាននូវប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពនៃប្រតិបត្តិការគ្រប់គ្រង និងចាត់ចែងកម្មវិធី និងរបបនីមួយៗនៅមានការខ្វះខាត
- បរិដ្ឋានវិនិយោគនៅមិនទាន់មានភាពល្អប្រសើរ ខណៈដែលគោលនយោបាយពន្ធដារក៏នៅមិនទាន់កំណត់ឲ្យបានច្បាស់លាស់
- ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណ និងអត្រានុកូលដ្ឋានប្រជាជនទូទៅ ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប្រជាជនក្រីក្រនិងងាយរងគ្រោះ និងប្រព័ន្ធចុះបញ្ជីរបស់ស្ថាប័នប្រតិបត្តិករនៅមិនទាន់បានតភ្ជាប់គ្នា ដែលនាំឲ្យមានការត្រួតគ្នាលើការកំណត់អត្តសញ្ញាណ និងការចុះបញ្ជី និងការផ្តល់អត្ថប្រយោជន៍ត្រួតគ្នាផងដែរ និង
- ការយល់ដឹងអំពីប្រព័ន្ធគាំពារសង្គម ដូចជាអត្ថប្រយោជន៍ និងកាតព្វកិច្ចក្នុងការចូលរួមរបស់ប្រជាជននៅក្នុងរបប ឬកម្មវិធីនីមួយៗនៅមានកម្រិត។

## គ. យុទ្ធសាស្ត្រ និងគោលដៅអនាគត

យុទ្ធសាស្ត្រ និងគោលដៅអនាគត សម្រាប់អនុវត្តដើម្បីសម្រេចបានគោលដៅ និងគោលបំណងនៃឯកសារក្របខ័ណ្ឌគោលនយោបាយនេះ មានដូចខាងក្រោម៖

- ការរៀបចំដាក់ឲ្យដំណើរការកម្មវិធីជាតិជំនួយសង្គមថ្មី និងការពង្រីកវិសាលភាពលើកម្មវិធីដែលមានស្រាប់ដើម្បីបង្កើនការគាំពារបន្ថែមដល់ជនក្រីក្រនិងងាយរងគ្រោះ តាមរយៈ៖
  - ការសិក្សារៀបចំដាក់ឲ្យដំណើរការកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ និងកុមារ ដើម្បីឆ្លើយតបនឹងបញ្ហាកង្វះអាហារូបត្ថម្ភ
  - ការសិក្សាអំពីលទ្ធភាព ក្នុងការពង្រីកវិសាលភាពកម្មវិធីអាហារូបករណ៍ថ្នាក់បឋមសិក្សា និងមធ្យមសិក្សា ព្រមទាំង កម្មវិធីផ្តល់អាហារនៅតាមសាលារៀន
  - ការបង្កើន និងពង្រឹងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលផ្តោតជាពិសេសលើយុវជនមកពីគ្រួសារក្រីក្រ និងងាយរងគ្រោះ
  - ការដាក់ឲ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនពិការ និង
  - ការសិក្សាអំពីការដាក់ឲ្យដំណើរការកម្មវិធីគាំពារជនចាស់ជរា
- ការរៀបចំដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមថ្មី និងពង្រីកវិសាលភាពលើរបបដែលមានស្រាប់ដើម្បីបង្កើនការគាំពារដល់ប្រជាជនគ្រប់រូប តាមរយៈ៖

- ការជំរុញការអភិវឌ្ឍប្រព័ន្ធសោធន និងថែទាំសុខភាពឲ្យសម្រេចបានវិសាលភាពគ្រប ដណ្តប់សកល ដើម្បីផ្តល់ការគាំពារជូនប្រជាជនគ្រប់រូប ទាំងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ និង
- ការពង្រឹងការលើកកម្ពស់សុខុមាលភាពជនពិការ និងការសិក្សាអំពីលទ្ធភាពក្នុងការ ដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមផ្នែកនិកម្មភាព

- ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធស្ថាប័ន និងការបែងចែកតួនាទីភារកិច្ចឲ្យបានច្បាស់លាស់ ពោលគឺ កម្រិតគោលនយោបាយ កម្រិតបញ្ញត្តិករ និងកម្រិតប្រតិបត្តិករ ដូចខាងក្រោម៖
  - ការរៀបចំបង្កើត "ក្រុមប្រឹក្សាជាតិគាំពារសង្គម" ដើម្បីដើរតួនាទីជាស្ថាប័នសម្រប-សម្រួលកម្រិតគោលនយោបាយ
  - ការរៀបចំបង្កើតស្ថាប័នបញ្ញត្តិករ ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យស្ថាប័នប្រតិបត្តិករ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព
  - ការធ្វើសមាហរណកម្មស្ថាប័នប្រតិបត្តិករសន្តិសុខសង្គមទាំងអស់រួមមាន៖ ប.ស.ស ប.ជ.ស ប.ជ.អ និង ម.ជ.ព ឲ្យទៅជាស្ថាប័នតែមួយ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការ គ្រប់គ្រង ការផ្តល់សេវាជូនប្រជាជន និងការគ្រប់គ្រងចំណាយថវិកា និង
  - ការសិក្សាអំពីលទ្ធភាពក្នុងការបង្កើតប្រតិបត្តិករជំនួយសង្គម ដើម្បីដើរតួជាច្រកចេញ-ចូលតែមួយសម្រាប់គ្រប់គ្រង និងចាត់ចែងហិរញ្ញប្បទានជំនួយសង្គមទាំងអស់
- ការលើកកម្ពស់បរិដ្ឋានវិនិយោគ ដើម្បីផ្តល់ជាជម្រើសសម្រាប់ការវិនិយោគមូលនិធិសន្តិសុខ សង្គម និងការកំណត់ឲ្យបានច្បាស់អំពីគោលនយោបាយពន្ធដារ ពាក់ព័ន្ធនឹងប្រតិបត្តិការ គាំពារសង្គម
- ការតភ្ជាប់ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណនិងអត្រានុកូលដ្ឋានប្រជាជនទូទៅ ប្រព័ន្ធគ្រប់គ្រង អត្តសញ្ញាណប្រជាជនក្រីក្រនិងងាយរងគ្រោះ និងប្រព័ន្ធចុះបញ្ជីរបស់ស្ថាប័នប្រតិបត្តិករ ដើម្បីបង្កើនប្រសិទ្ធភាពការងារ កាត់បន្ថយពេលវេលា និងចំណាយ និង
- ការបង្កើនការលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម។

ជារួម យុទ្ធសាស្ត្រនិងផែនការសកម្មភាពកំណែទម្រង់នីមួយៗ ដែលមានចែងក្នុងក្របខ័ណ្ឌ គោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ គឺមានភាពប្រទាក់ក្រឡាគ្នាទៅវិញទៅមក។ ភាពយឺតយ៉ាវនៃកំណែទម្រង់នៃកម្មវិធី ឬរបបណាមួយ អាចមានផលប៉ះពាល់អវិជ្ជមានដល់ដំណើរការ នៃការធ្វើកំណែទម្រង់កម្មវិធីឬរបបផ្សេងទៀត និងប្រព័ន្ធគាំពារសង្គមទាំងមូល។ ដូច្នេះ រាជរដ្ឋាភិបាល នឹងផ្តោតការយកចិត្តទុកដាក់លើការអនុវត្ត និងល្បឿននៃការកែទម្រង់ ដោយតាមដានជាប្រចាំលើ វឌ្ឍនភាព និងបញ្ហាប្រឈមរបស់កម្មវិធី ឬរបបនីមួយៗ ដែលអាចកើតមានឡើង ដើម្បីចាត់វិធានការ សមស្រប និងទាន់ពេលវេលា។

# ◆ ជំពូកទី ១

# ទិដ្ឋភាពទូទៅ

# ជំពូកទី១
# ទិដ្ឋភាពទូទៅ

## ១.១ សេចក្តីផ្តើម

ប្រជាជនកម្ពុជា មានទម្លាប់រស់នៅតាមបែបគ្រួសារ និងសហគមន៍ ដោយការពឹងអាស្រ័យ និងជួយយកអាសាគ្នា ជាពិសេស ពេលមានជំងឺឈឺថ្កាត់ ពេលមានគ្រោះអាសន្នផ្សេងៗ ឬពេលធ្លាក់ខ្លួនជរាគ្មានទីពឹង ជាដើម។ ទម្លាប់នេះ នៅតែបន្តឃើញមានជាហូរហែរនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ជាពិសេស គឺការពឹងផ្អែកគ្នាទៅវិញទៅមកក្នុងរង្វង់សាច់ញាតិនិងក្រុមគ្រួសារ។ ទម្លាប់ទាំងនេះ បង្ហាញឲ្យឃើញពីសាមគ្គីភាពដ៏ល្អទាំងក្នុងក្រុមគ្រួសារ និងសហគមន៍ ដែលគប្បីបន្តរក្សាឲ្យបានគង់វង្ស។ ទោះយ៉ាងណា បទពិសោធន៍នៃបណ្តាប្រទេសនៅក្នុងនិងក្រៅតំបន់ ជាពិសេស ប្រទេសដែលមានទំនៀមទម្លាប់ប្រពៃណីប្រហាក់ប្រហែលប្រទេសកម្ពុជាបានបង្ហាញថា ទម្លាប់ទាំងនេះមាននិន្នាការថយចុះជាបន្តបន្ទាប់ពីមួយជំនាន់ទៅមួយជំនាន់ ដោយសារកត្តាផ្សេងៗជាច្រើន។ និន្នាការនេះ បានបង្ហាញឲ្យឃើញយ៉ាងច្បាស់ពីតម្រូវការចាំបាច់នៃប្រព័ន្ធគាំពារសង្គម ដើម្បីផ្តល់នូវការគាំពារសម្រាប់ប្រជាជនម្នាក់ៗឲ្យចៀសផុតពីការធ្លាក់ខ្លួនចូលទៅក្នុងភាពក្រីក្រ ដោយសារការទទួលរងឥទ្ធិពលពីគ្រោះធម្មជាតិ តម្រូវការសេវាសុខាភិបាល ការធ្លាក់ខ្លួនពិការ ឬការឈានចូលវ័យចាស់ជរា ជាដើម។ល។

កន្លងមក រាជរដ្ឋាភិបាលតែងផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ដែលស្តែងចេញពីការដាក់ឲ្យដំណើរការបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) បេឡាជាតិអតីតយុទ្ធជន (ប.ជ.អ) និងមូលនិធិជនពិការ (ម.ជ.ព) ព្រមទាំង ការអនុម័តយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងងាយរងគ្រោះ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការដាក់ឲ្យដំណើរការកម្មវិធីជាតិជំនួយសង្គមមួយចំនួន។ សម្រាប់អាណត្តិទី៥នេះ រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ក្នុងនោះយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ បានកំណត់យក "**ការបន្តពង្រឹង និងអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឲ្យមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព និងប្រសិទ្ធភាព**" ជាគោលដៅអាទិភាព។

នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ សំដៅជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឲ្យកាន់តែរឹងមាំនិងល្អប្រសើរឡើង ព្រមទាំង អាចគ្របដណ្តប់ប្រជាជនគ្រប់រូប ជាពិសេសប្រជាជនក្រីក្រនិងងាយរងគ្រោះ។

ចក្ខុវិស័យរយៈកាលវែងរបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម គឺការកសាងប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាប័ន្ន ប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុ ដែលជាឧបករណ៍បម្រើដល់ការកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ហើយរួមចំណែកដល់ការអភិវឌ្ឍ និងគាំពារធនធានមនុស្សកាន់តែទូលំទូលាយ និងជំរុញកំណើនសេដ្ឋកិច្ច។

គោលបំណងនៃការរៀបចំឯកសារនេះ គឺដើម្បីកំណត់ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការធានាឲ្យបាននូវសន្តិសុខប្រាក់ចំណូល និងកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់ប្រជាជន សំដៅលើកកម្ពស់សុខុមាលភាពនិងសាមគ្គីភាពសង្គម ព្រមទាំង កាត់បន្ថយ ភាពក្រីក្រជាអតិបរមា។ គោលដៅចម្បងនៃក្របខ័ណ្ឌគោលនយោបាយនេះ គឺធ្វើការបន្សុី ប្រមូលផ្តុំ និងពង្រឹងកម្មវិធីដែលមានស្រាប់ ដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព និងសង្គតិភាពនៃរបបឬកម្មវិធី ទាំងឡាយក្នុងប្រព័ន្ធគាំពារសង្គមទាំងមូល រួមទាំងការពង្រីកវិសាលភាពដែលនៅតូចចង្អៀតនៅឡើយ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាជនគ្រប់ស្រទាប់ ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ព្រម ទាំង រៀបចំឲ្យមានក្របខ័ណ្ឌអភិបាលកិច្ច និងការពិនិត្យលើបញ្ហាឆ្លងវិស័យ ដើម្បីធានាឲ្យបាននូវ ប្រសិទ្ធភាពនៃការគ្រប់គ្រង និងបង្កើនប្រសិទ្ធភាពចំណាយថវិកា។

ឯកសារគោលនយោបាយនេះ ឆ្លុះបញ្ចាំងពីវឌ្ឍនភាព និងសមិទ្ធិផលនានាដែលទទួលបាន ជោគជ័យនាពេលកន្លងមក ទន្ទឹមនឹងការកំណត់អំពីបញ្ហាប្រឈមនានា ដែលបាននិងកំពុងជួបប្រទះ ព្រមទាំង បញ្ហាប្រឈមជាយថាភាពនានាដែលអាចនឹងកើតមានឡើងនៅថ្ងៃអនាគតដើម្បីជាមូលដ្ឋាន ក្នុងការកំណត់យុទ្ធសាស្ត្រ និងគោលដៅអនាគត សម្រាប់ឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនោះ។ វិធានការចម្បងៗនឹងត្រូវបានដាក់ចេញជាដំណាក់កាលខ្លី មធ្យម និងវែង ដោយផ្អែកលើទិដ្ឋភាព ៤ គឺ (១) សមធម៌ (២) ភាពទ្រទ្រង់បាននៃថវិកា (៣) ប្រសិទ្ធភាព និង (៤) ចីរភាព។

ប្រព័ន្ធគាំពារសង្គមកម្ពុជាមានសសរស្តម្ភ២គឺ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។ ប្រព័ន្ធជំនួយសង្គមផ្តល់ការគាំពារដល់ប្រជាជនដែលរស់នៅក្រោម និងក្បែរបន្ទាត់ភាពក្រីក្រ ដោយផ្តោត ជាពិសេសលើកុមារ និងស្ត្រីមានផ្ទៃពោះ ជនពិការ និងជនចាស់ជរាគ្មានទីពឹង។ ប្រព័ន្ធសន្តិសុខសង្គម ផ្តល់ការគាំពារហានិភ័យលើផ្នែកសោធន ថែទាំសុខភាព ហានិភ័យការងារ និកម្មភាព និងពិការភាព ដល់ក្រុមប្រជាជននៃវិស័យសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រព័ន្ធ។

## ១.២ ស្ថានភាពសេដ្ឋកិច្ច-សង្គម

យោងតាមការវាយតម្លៃរបស់ធនាគារពិភពលោកនៅឆ្នាំ២០១៥ ព្រះរាជាណាចក្រកម្ពុជាត្រូវ បានទទួលស្គាល់ជាប្រទេសឯកត្តករមួយ សម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែង។ ក្នុង រយៈពេល ២ ទសវត្សចុងក្រោយនេះ អត្រាកំណើនសេដ្ឋកិច្ចមធ្យមប្រចាំឆ្នាំមានកម្រិតប្រមាណ ៧.៧ ភាគរយ ហើយអត្រាកំណើនដ៏គួរជាទីមោទនៈនេះ ត្រូវបានរំពឹងថានឹងរក្សាសន្ទុះបន្តទៀតសម្រាប់ រយៈពេលមធ្យមខាងមុខ។ នៅឆ្នាំ២០១៥ ទោះបីជាសេដ្ឋកិច្ចសកលលោកមិនទាន់មានភាពរឹងមាំក្តី ក៏ កម្ពុជាអាចរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើន សេដ្ឋកិច្ចក្នុងរង្វង់ ៧ ភាគរយ កម្រិតអតិផរណាទាបប្រមាណ ១.២ ភាគរយ និងអត្រាប្តូរប្រាក់មាន ស្ថិរភាពក្នុងរង្វង់ ៤.០៥០ រៀលក្នុង ១ ដុល្លារអាមេរិក។ ឱនភាពថវិកាជាតិបានធ្លាក់ចុះជាលំដាប់មក ត្រឹមជិត ៣ ភាគរយ ក្នុងឆ្នាំ២០១៥ តាមរយៈការខំប្រឹងប្រែងអនុវត្តកម្មវិធីកំណែទម្រង់គ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ ជាពិសេស អនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨

ក៏ដូចជាការបង្កើនប្រសិទ្ធភាពចំណាយថវិកាជាតិ។ សមតុល្យជញ្ជីងទូទាត់ជាមធ្យមមានអតិរេក ប្រមាណ ៣ ភាគរយនៃ ផ.ស.ស ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយឱនភាពគណនីចរន្ត បានបន្តកាត់បន្ថយជាបន្តបន្ទាប់។

**រូបភាពទី១៖ អត្រាកំណើនផលិតផលក្នុងស្រុកសរុប (ផ.ស.ស)**




ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ជាលទ្ធផលនៃការអភិវឌ្ឍសេដ្ឋកិច្ចល្អប្រសើរ អត្រាភាពក្រីក្រនៅកម្ពុជា ត្រូវបានកាត់បន្ថយ គួរឲ្យកត់សម្គាល់ ដោយសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សក្នុងការកាត់បន្ថយភាពក្រីក្របាន ប្រមាណ ៤ ភាគរយក្នុងមួយឆ្នាំ ដែលធ្វើឲ្យអត្រាភាពក្រីក្រធ្លាក់ចុះយ៉ាងលឿនពី ៥៣ ភាគរយ ក្នុងឆ្នាំ ២០០៤ មកត្រឹម ១៣.៥ ភាគរយ ក្នុងឆ្នាំ២០១៤។ ផលិតផលក្នុងស្រុកសរុបគិតជាមធ្យមសម្រាប់ មនុស្សម្នាក់បានកើនពី ៤៨៧ ដុល្លារនៅឆ្នាំ២០០៥ ដល់ប្រមាណ ១,២១៥ ដុល្លារនៅឆ្នាំ២០១៥ ដែលធ្វើឲ្យកម្ពុជាប្រែក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

**រូបភាពទី២៖ កំណើន ផ.ស.ស សម្រាប់មនុស្សម្នាក់ (គិតជាដុល្លារ)**




ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លែផ្កានៃកំណើនសេដ្ឋកិច្ច ក៏ត្រូវបានបែងចែកក្នុងលក្ខណៈកាន់តែមានសមភាព។ មេគុណ ឬ សន្ទស្សន៍ ដែលវាស់កម្រិតវិសមភាពនៅក្នុងចំណាយសម្រាប់ការប្រើប្រាស់ក្នុងចំណោមប្រជាជនបាន ថយចុះពី ០.៤១ នៅឆ្នាំ២០០៧ មកនៅត្រឹម ០.២៩ នៅឆ្នាំ២០១២។ ទន្ទឹមនឹងនេះ ការលើកកម្ពស់

សុខភាពរបស់ប្រជាជនក៏ទទួលបានវឌ្ឍនភាពគួរឲ្យកត់សម្គាល់។ អត្រាមរណភាពមាតាថយចុះពី ២០៦ នៅឆ្នាំ២០១៣ មកនៅត្រឹម ១៤០ នៅឆ្នាំ២០១៥ ក្នុងកំណើតទារក ១០០ ០០០ នាក់។ រីឯ អត្រាមរណភាពទារកក៏ថយចុះផងដែរពី ២៧ នៅឆ្នាំ២០១៣ មកនៅត្រឹម ២២ នៅឆ្នាំ២០១៥ ក្នុងកំណើតទារក ១ ០០០ នាក់។

**រូបភាពទី៣៖ អត្រាមរណភាពមាតា និងទារក**




ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៤-២០១៨

ជារួម ការរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍវិស័យផលិតកម្ម ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ បានគាំទ្រដល់ការរីកចម្រើនសកម្មភាពសេដ្ឋកិច្ចប្រកបដោយភាពរឹងមាំ ព្រមទាំង បានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

សមិទ្ធិផលទាំងនេះទទួលបាននៅក្នុងបរិបទនៃស្ថិរភាពនយោបាយនិងសង្គម និងឆ្លុះបញ្ចាំងពីភាពជោគជ័យនៃគោលនយោបាយកំណែទម្រង់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ដោយការអនុវត្តយន្តការសេដ្ឋកិច្ចទីផ្សារ ការទាញយកឧត្តមភាពប្រៀបធៀបពីការប្រកួតប្រជែង និងតាមរយៈការបង្កើតបរិដ្ឋានអំណោយផលសម្រាប់ការវិនិយោគរបស់វិស័យឯកជន។

ការធ្លាក់ចុះនៃអត្រាភាពក្រីក្រ និងមេគុណវិសមភាពនៃការប្រើប្រាស់បានស្ដែងឡើង ទន្ទឹមនឹងការរីកចម្រើននៃទីផ្សារការងារនៅប្រទេសកម្ពុជា។ ការរីកចម្រើននៃវិស័យឯកជន និងពិពិធកម្មសេដ្ឋកិច្ចបានស្រូបយកកម្លាំងពលកម្មកាន់តែច្រើនឡើងជាលំដាប់ចេញពីវិស័យផលិតកម្មប្រពៃណី ជាពិសេសវិស័យកសិកម្ម ទៅកាន់វិស័យកម្មន្តសាលកម្ម ឧស្សាហកម្ម និងសេវាកម្ម។

បច្ចុប្បន្ន ប្រជាជនភាគច្រើនស្ថិតក្នុងវ័យពលកម្ម ដែលគួបផ្សំនឹងអត្រានិកម្មភាពទាប គឺជាកត្តាចលករដ៏សំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច។

ជាមួយនឹងសន្ទុះនៃវឌ្ឍនភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន ស្របពេលដែលសេដ្ឋកិច្ចពិភពលោកត្រូវបានរំពឹងថានឹងមានភាពរឹងមាំឡើងវិញជាលំដាប់ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលដៅប្រកបដោយមហិច្ឆតារបស់ខ្លួន គឺការផ្លាស់ប្ដូរឋានៈកម្ពុជាពីប្រទេសដែលមានចំណូលទាបទៅជាប្រទេសមាន

ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទៅជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ការសម្រេចបាននូវមហិច្ឆតានេះ នឹងផ្តល់មូលដ្ឋានគ្រឹះមួយរឹងមាំជាថ្មីទៀតសម្រាប់ការសម្រេចបាននូវគោលដៅសេដ្ឋកិច្ច-សង្គមក្នុងកម្រិតមួយកាន់តែខ្ពស់។

## ១.៣ ស្ថានភាពប្រជាសាស្ត្រ

កម្ពុជា ត្រូវបានចាត់ទុកជាប្រទេសដែលមានប្រជាជនវ័យក្មេងច្រើន ដោយសារប្រជាជនដែលមានអាយុលើសពី ៦៥ ឆ្នាំមានចំនួនប្រមាណតែ ៥ ភាគរយប៉ុណ្ណោះនៃចំនួនប្រជាជនសរុប នៅឆ្នាំ២០១៥។ ទោះយ៉ាងណា អត្រាកំណើនប្រជាជនមាននិន្នាការថយចុះជាបន្តបន្ទាប់ពី ១.៤៦ ភាគរយនៅឆ្នាំ២០១៤ មកនៅ ១.៣៦ ភាគរយនៅឆ្នាំ២០១៨។

**រូបភាពទី៤៖ អត្រាកំណើនប្រជាជនកម្ពុជាចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៨**




ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៤-២០១៨

ដោយសារអត្រាកំណើនប្រជាជនបានថយចុះជាបន្តបន្ទាប់ ស្របពេលដែលអាយុកាលសង្ឃឹមរស់របស់ប្រជាជនមាននិន្នាការកើនឡើង កម្ពុជាក៏បាននិងកំពុងបោះជំហានក្លាយទៅជាសង្គមដែលមានមនុស្សចាស់ច្រើន ឬសង្គមចាស់ជរា (Aging Society) បន្តិចម្តងៗផងដែរ។

**រូបភាពទី៥៖ ការព្យាករណ៍កំណើនប្រជាជនរហូតដល់ឆ្នាំ២១០០**




ប្រភព៖ អង្គការពលកម្មអន្តរជាតិ

ការអភិវឌ្ឍនៃវិស័យសុខាភិបាល និងការទទួលបាននូវចំណីអាហារ និងជីវជាតិគ្រប់គ្រាន់ គឺជាកត្តាចម្បងដែលនាំឲ្យមានការកើនឡើងនៃអាយុកាលសង្ឃឹមរស់របស់ប្រជាជនកម្ពុជា។ យោងតាមការព្យាករណ៍របស់អង្គការសហប្រជាជាតិ ចាប់ពីឆ្នាំ២០៣០ទៅ កម្រិតអាយុកាលសង្ឃឹមរស់របស់ប្រជាជនកម្ពុជានឹងកើនឡើងខ្ពស់ជាង៧០ឆ្នាំ ដែលកត្តានេះ ក៏មានផលប៉ះពាល់ផងដែរចំពោះអត្រាទ្រទ្រង់មនុស្សចាស់ (កម្លាំងពលកម្មដែលមានអាយុពី១៥ឆ្នាំដល់៥៩ឆ្នាំ ទ្រទ្រង់ជនចាស់ជរាដែលមានអាយុចាប់ពី៦០ឆ្នាំឡើងទៅ) ដូចមានបង្ហាញក្នុងរូបភាពទី៨។ និន្នាការនៃការប្រែក្លាយទៅជាសង្គមដែលមានមនុស្សចាស់ច្រើន បង្ហាញពីតម្រូវការចាំបាច់ក្នុងការសន្សំប្រាក់សម្រាប់គាំពារនៅពេលចាស់ជរាដើម្បីទ្រទ្រង់ការរស់នៅនិងដើម្បីជៀសវាងពីការធ្លាក់ចូលក្នុងភាពក្រីក្រ។

**រូបភាពទី៦៖ អាយុកាលសង្ឃឹមរស់របស់ប្រជាពលរដ្ឋកម្ពុជា**




ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៤-២០១៨

**រូបភាពទី៧៖ ការព្យាករណ៍អាយុកាលសង្ឃឹមរស់រហូតដល់ឆ្នាំ២០៥០**




ប្រភព៖ របាយការណ៍ប្រជាជនពិភពលោករបស់អង្គការសហប្រជាជាតិឆ្នាំ២០១៥

### រូបភាពទី៨៖ ការព្យាករណ៍ចំនួនវ័យពលកម្មដែលត្រូវទ្រទ្រង់វ័យជរា




ប្រភព៖ របាយការណ៍ប្រជាជនពិភពលោករបស់អង្គការសហប្រជាជាតិឆ្នាំ២០១៥

## ១.៤ ទស្សនទាននៃប្រព័ន្ធគាំពារសង្គម

### ១.៤.១ ភាពចាំបាច់នៃប្រព័ន្ធគាំពារសង្គម

នៅក្នុងបរិបទនៃក្របខ័ណ្ឌគោលនយោបាយនេះ ប្រព័ន្ធគាំពារសង្គមសំដៅដល់គោលនយោបាយ កម្មវិធី សកម្មភាព រួមទាំងក្របខ័ណ្ឌគតិយុត្តិ និងស្ថាប័ន ដែលត្រូវបានរៀបចំឡើងដើម្បីផ្តល់ការគាំពារ និងពង្រឹងសមត្ថភាពរបស់សមាជិកក្នុងសង្គមកម្ពុជាក្នុងការឆ្លើយតបចំពោះហានិភ័យសេដ្ឋកិច្ច និងភាពងាយរងគ្រោះមួយចំនួន ដែលកើតឡើងពីការប្រែប្រួលលក្ខខណ្ឌរស់នៅ និងការងារ។

ការគាំពារសង្គមគឺជាការប្តេជ្ញាខិតខំជាក់ស្តែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលធ្លាប់បានអនុវត្តជាច្រើនមកហើយ និងដែលចាំបាច់ត្រូវធ្វើការពង្រឹង និងពង្រីកបន្ថែមទៀត។ កត្តាទាំងនោះ ទាមទារការយកចិត្តទុកដាក់កាន់តែខ្ពស់ពីរាជរដ្ឋាភិបាលទៅលើការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជា ដែលក្នុងនោះរួមមានជាបឋមគឺ៖

១. ភាពចាំបាច់ក្នុងការវិនិយោគលើធនធានមនុស្ស ក្នុងខណៈជំរុញផលិតភាពពលកម្ម។ ការធានាបាននូវសន្តិសុខប្រាក់ចំណូលជូនប្រជាជន និងជំរុញឲ្យពួកគាត់មានលទ្ធភាពបង្កើនចំណាយ ដែលជាកម្លាំងចលករយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិឲ្យកាន់តែមានប្រសិទ្ធភាព និងប្រកបដោយបរិយាប័ន្ន

២. តម្រូវការក្នុងការធានាបាននូវយុត្តិធម៌ និងសមធម៌សង្គម តាមរយៈការលើកកម្ពស់ឋានៈសេដ្ឋកិច្ច-សង្គមនៃប្រជាជនក្រីក្រនិងងាយរងគ្រោះ ហើយដូចនោះជំរុញនូវសាមគ្គីភាព ភាពសុខសាន្ត និងសន្តិភាពសង្គម

៣. ភាពចាំបាច់ក្នុងការត្រៀមលក្ខណៈ ដើម្បីឆ្លើយតបចំពោះបម្រែបម្រួលកត្តាប្រជាសាស្ត្រ និងការប្រែក្លាយទៅជាសង្គមចាស់ជរា

៤. ការបន្ស៊ី ប្រមូលផ្តុំ និងពង្រឹងរបបឬកម្មវិធីដែលមានស្រាប់ សំដៅបង្កើនប្រសិទ្ធភាព តម្លា-ភាព និងសង្គតិភាព ជាមួយនឹងការពង្រីកវិសាលភាពឲ្យបានទូលំទូលាយ

៥. ការបង្កើតយន្តការគាំពារហានិភ័យពីការធ្លាក់ចូលក្នុងភាពក្រីក្រ ដោយសារវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាយថាហេតុ នៅចំពោះមុខលក្ខខណ្ឌសេដ្ឋកិច្ចបើកចំហរបស់ប្រទេសកម្ពុជា ព្រមទាំងទំនាក់ទំនងកាន់តែទូលាយ និងភាពកាន់តែប្រទាក់ក្រឡានៃសេដ្ឋកិច្ចក្នុងប្រទេស ជាមួយសេដ្ឋកិច្ចតំបន់ និងពិភពលោក និងការឆ្លងរាលដាលនៃវិបត្តិ និង

៦. ការសម្រួលនិងជំរុញសញ្ច័យហិរញ្ញវត្ថុ ដែលនឹងដើរតួជាប្រភពហិរញ្ញប្បទានរយៈកាលវែង យ៉ាងសំខាន់សម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តក្នុងប្រទេស តាមរយៈការវិនិយោគលើមូលបត្ររដ្ឋ។ លើសពីនេះ សញ្ច័យហិរញ្ញវត្ថុក៏អាចជួយជំរុញការអភិវឌ្ឍទីផ្សារទុន និងប្រព័ន្ធហិរញ្ញវត្ថុ តាមរយៈការវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត ក៏ដូចជាទីផ្សារអចលនទ្រព្យផងដែរ។

### ១.៤.២ តួនាទីរបស់រាជរដ្ឋាភិបាលនៅក្នុងប្រព័ន្ធគាំពារសង្គម

កត្តាចាំបាច់ខាងលើបញ្ជាក់ថា សកម្មភាពគាំពារសង្គមមានលក្ខណៈពហុវិស័យ និងពាក់ព័ន្ធទៅនឹងសមាជិកសង្គមគ្រប់វ័យ និងគ្រប់ស្រទាប់។ រាជរដ្ឋាភិបាលមានតួនាទីទ្រទ្រង់ប្រព័ន្ធគាំពារសង្គម តាមរយៈគោលនយោបាយ ឬសកម្មភាពជាក់លាក់មួយចំនួនគឺៈ (១) ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ (២) ការរៀបចំក្របខ័ណ្ឌគ្រប់គ្រង និងបញ្ញត្តិកម្មប្រកបដោយប្រសិទ្ធភាព និង (៣) ការផ្តល់នូវជម្រើសនិងដំណោះស្រាយហិរញ្ញប្បទានសមស្រប ចំពោះសកម្មភាពគាំពារសង្គម។

ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ គឺជាមូលដ្ឋានគ្រឹះនៃការគាំពារសង្គម ជាពិសេសតាមរយៈការរក្សាអតិផរណាឲ្យស្ថិតក្នុងកម្រិតទាប និងចីរភាពប្រាក់ចំណូលសមស្រប។ នៅក្នុងបរិបទនេះដែរ ការកាត់បន្ថយហានិភ័យនៃការកើតមាននូវវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានន័យថាជាការកាត់បន្ថយនូវភាពងាយរងគ្រោះរបស់ប្រជាជន ដែលផ្តោតជាបឋមលើជនក្រីក្រ។

លើសពីនេះ គោលនយោបាយគាំពារសង្គមត្រូវមានសង្គតិភាពនិងទំនាក់ទំនងជិតស្និទ្ធជាមួយគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំង យុទ្ធសាស្ត្រ គោលនយោបាយ និងកម្មវិធីតាមវិស័យសំខាន់ៗដែលបំពេញឲ្យគ្នាទៅវិញទៅមក និងរួមគ្នាបង្កើតជាក្របខ័ណ្ឌរួម ដែលមានសក្តានុពលអាចលើកកម្ពស់សមធម៌និងសុខុមាលភាពសង្គម ក្នុងបរិបទនៃការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន មានជាអាទិ៍ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ គោលនយោបាយវិស័យអប់រំ សុខាភិបាល សង្គមកិច្ច ការអភិវឌ្ឍធនធានមនុស្ស ការផ្តល់ហិរញ្ញប្បទានប្រកបដោយបរិយាប័ន្ន ការគាំពារបរិស្ថាន និងការគ្រប់គ្រងគ្រោះធម្មជាតិ ព្រមទាំង គោលនយោបាយយេនឌ័រ ជាដើម។ល។

ការជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមត្រូវផ្អែកលើហិរញ្ញប្បទានសមស្រប។ របប និងកម្មវិធីគាំពារសង្គមអាចនឹងត្រូវផ្តល់ហិរញ្ញប្បទាននិងអនុវត្តដោយវិស័យសាធារណៈ ដៃគូអភិវឌ្ឍន៍ អង្គការ-

សមាគម-សហគមន៍ស្ម័គ្រចិត្តនានា និងបណ្ដាញមិនផ្លូវការផ្សេងៗ។ ទោះយ៉ាងណា ជំនួយឧបត្ថម្ភរបស់ដៃគូអភិវឌ្ឍន៍ និងបណ្ដាញមិនផ្លូវការផ្សេងៗនឹងត្រូវថយចុះ ដោយសារការរីកចម្រើនជាលំដាប់នៃសេដ្ឋកិច្ច។ ក្នុងបរិការណ៍នេះ ហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល គឺជាប្រភពដ៏សំខាន់ដែលនឹងត្រូវផ្ដោតការយកចិត្តទុកដាក់លើការបន្តនិរន្តរភាពកម្មវិធី និងរបបគាំពារសង្គមទាំងនោះតាមការចាំបាច់។ ដូច្នេះសកម្មភាពគាំពារសង្គមនឹងត្រូវទ្រទ្រង់ដោយប្រភពហិរញ្ញប្បទាន ២ គឺ ថវិការដ្ឋ និងហិរញ្ញប្បទានដោយការរួមចំណែកបង់ភាគទាន (ដោយនិយោជក និយោជិត និង/ឬប្រជាជនទូទៅ)។

រាជរដ្ឋាភិបាលនឹងដាក់ឲ្យដំណើរការប្រព័ន្ធគាំពារសង្គមជាដំណាក់កាល ទៅតាមការវិវឌ្ឍនៃសេដ្ឋកិច្ច និងសង្គម។ ការទ្រទ្រង់របស់រដ្ឋលើដំណើរការប្រព័ន្ធគាំពារសង្គមទាមទារនូវលំហថវិកាក្នុងកម្រិតសមស្រប ដើម្បីផ្សារភ្ជាប់ទៅនឹងកម្រិតនៃអត្ថប្រយោជន៍ដែលនឹងផ្ដល់ជូនចំពោះប្រជាជន។ យ៉ាងណាមិញ មហិច្ឆតាខ្ពស់នៃការគាំពារសង្គមទាមទារនូវចំណាយធនធានដ៏សម្បើម ដែលអាចមិនឆ្លើយតបទៅនឹងសមត្ថភាពថវិកា។ ការបង្កើនចំណូលដើម្បីទ្រទ្រង់ប្រព័ន្ធគាំពារសង្គម តាមរយៈការបង្កើនអត្រាពន្ធខ្ពស់មិនសមស្របនឹងក្លាយជារបាំងសម្រាប់ការវិនិយោគក្នុងស្រុក មិនលើកទឹកចិត្ត និងមិនជំរុញសកម្មភាពសេដ្ឋកិច្ច ហើយដូចនោះនឹងបង្កផលប៉ះពាល់ជាអវិជ្ជមានដល់កំណើនសេដ្ឋកិច្ច។ ដូច្នេះ ការកំណត់គោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធគាំពារសង្គម ត្រូវមានតុល្យភាពជាមួយនឹងលំហថវិកាជាតិ ស្ថានភាពសេដ្ឋកិច្ច និងសង្គម។

### ១.៤.៣ គោលការណ៍គ្រឹះនៃក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម

ក្នុងទិដ្ឋភាពសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ ដែលមានភាពប្រទាក់ក្រឡា និងស្មុគស្មាញ និងដើម្បីធានាឲ្យប្រព័ន្ធគាំពារសង្គមអាចបំពេញតួនាទីជាឧបករណ៍ប្រកបដោយប្រសិទ្ធភាព ក្នុងការសម្រេចចក្ខុវិស័យរយៈកាលវែង និងគោលបំណងដែលបានកំណត់ ការរៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយ ព្រមទាំងការអនុវត្តកម្មវិធី/សកម្មភាពគាំពារសង្គម គប្បីត្រូវអនុលោមតាមគោលការណ៍ណែនាំសំខាន់ៗមួយចំនួនដូចតទៅៈ

១. ការពង្រឹងតួនាទីក្បាលម៉ាស៊ីនដឹកនាំ ពោលគឺតួនាទីរបស់រដ្ឋាភិបាលក្នុងការរៀបចំនិងដាក់ចេញនូវគោលនយោបាយ ការសម្របសម្រួលសកម្មភាពនិងកម្មវិធីគាំពារសង្គមទាំងឡាយ ព្រមទាំង ការត្រួតពិនិត្យកម្រិតជាតិលើប្រព័ន្ធគាំពារសង្គម

២. ភាពឆ្លើយតបសមរម្យនឹងតម្រូវការ និងលក្ខខណ្ឌជាក់ស្ដែង ដែលនឹងផ្អែកលើការសិក្សាវិភាគត្រឹមត្រូវលើតម្រូវការ ការផ្គត់ផ្គង់ និងហិរញ្ញប្បទានពាក់ព័ន្ធ

៣. ភាពសមស្របនៃកម្រិតភាគទានដែលត្រូវបង់ និងអត្ថប្រយោជន៍ដែលទទួលបាន ដើម្បីធានាការចូលរួមទូលំទូលាយរបស់ប្រជាជន

៤. និរន្តរភាពហិរញ្ញវត្ថុដោយផ្អែកលើលទ្ធភាពទ្រទ្រង់នៃថវិកាជាតិ និងការកសាងសមត្ថភាពរបស់បុគ្គល ក្រុមគ្រួសារ និងសហគមន៍

៥. សមធម៌ និងសាមគ្គីភាពសង្គម ដែលជានានូវការជួយគ្នាទៅវិញទៅមកនៃក្រុមសមាជិកក្នុងសង្គម តាមរយៈយន្តការបែងចែកឡើងវិញនូវប្រាក់ចំណូល និង
៦. ភាពទន់ភ្លន់ និងឆ្លើយតបនឹងបម្រែបម្រួលនៃបរិបទ ដែលទាមទារឲ្យមានការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រ និងគោលនយោបាយគាំពារសង្គម តាមករណីចាំបាច់។

## ១.៥ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមកម្ពុជា

ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ មានវិសាលភាពគ្របដណ្តប់លើប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។ វិសាលភាពដ៏ទូលំទូលាយនេះ ផ្តល់នូវក្របខ័ណ្ឌសម្រាប់ការតភ្ជាប់ទំនាក់ទំនងរវាងប្រព័ន្ធទាំងពីរ ដែលមានលក្ខណៈបំពេញគ្នាទៅវិញទៅមក។

ប្រព័ន្ធជំនួយសង្គម ជាប្រព័ន្ធសម្រាប់គ្រប់គ្រងកម្មវិធីជំនួយសង្គម ដែលរួមបញ្ចូលអន្តរាគមន៍សម្រាប់ជាប្រយោជន៍ដល់ប្រជាជនក្រីក្រនិងងាយរងគ្រោះ ដែលធ្វើហិរញ្ញប្បទានដោយចំណូលថវិកាជាតិ និង/ឬជំនួយអភិវឌ្ឍន៍ផ្លូវការ។ ប្រព័ន្ធជំនួយសង្គមនៅកម្ពុជាមានធាតុផ្សំ ៤ រួមមាន៖ (១) ការឆ្លើយតបទៅនឹងគ្រោះអាសន្ន (២) ការអភិវឌ្ឍមូលធនមនុស្ស (៣) ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង (៤) សុខុមាលភាពសម្រាប់ប្រជាជនងាយរងគ្រោះ។

ប្រព័ន្ធសន្តិសុខសង្គម ជាប្រព័ន្ធសម្រាប់គ្រប់គ្រងកម្មវិធីសន្តិសុខសង្គម ដែលរួមបញ្ចូលកម្មវិធីដែលរៀបចំឡើងដើម្បីជួយដល់ប្រជាជន ក្នុងការការពារពួកគាត់ពីការធ្លាក់ចុះភ្លាមៗនៃប្រាក់ចំណូលដែលបណ្តាលមកពីជំងឺ លំហែមាតុភាព គ្រោះថ្នាក់ការងារ និកម្មភាព ទុព្វលភាព ជរាភាព (ឬចូលនិវត្តន៍) និងមរណភាពនៃអ្នកដែលរកចំណូលសម្រាប់គ្រួសារ។ របបសន្តិសុខសង្គមតម្រូវឲ្យសមាជិក និង/ឬភាគីពាក់ព័ន្ធបង់ភាគទានជាកាតព្វកិច្ចទៅតាមអត្រាជាក់លាក់។ រាជរដ្ឋាភិបាលប្រកាន់ខ្ជាប់លើគោលការណ៍ផ្តល់ឧបត្ថម្ភធនជូនដល់ប្រជាជនដែលមិនមានលទ្ធភាពបង់ភាគទាន ពោលគឺប្រជាជនក្រីក្រនិងងាយរងគ្រោះ។ ប្រព័ន្ធសន្តិសុខសង្គមនៅក្នុងប្រទេសកម្ពុជាមានធាតុផ្សំ ៥ គឺ (១) សោធន (២) ថែទាំសុខភាព (៣) ហានិភ័យការងារ (៤) និកម្មភាព និង (៥) ពិការភាព។

**រូបភាពទី៩៖ ក្របខ័ណ្ឌគាំពារសង្គមកម្ពុជា**



## ១.៦ អភិក្រមជាលក្ខណៈវដ្តជីវិតនៃប្រព័ន្ធគាំពារសង្គម

បញ្ហាប្រឈមចម្បងនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា គឺវិសាលភាពមិនទាន់គ្របដណ្តប់ចំពោះប្រជាជនគ្រប់រូប និងកង្វះកម្មវិធីជាក់លាក់មួយចំនួន ដើម្បីឆ្លើយតបចំពោះហានិភ័យ ដែលអាចកើតមានក្នុងដំណាក់កាលណាមួយនៃវដ្តជីវិត។ ការណ៍នេះ បង្កឲ្យមានហានិភ័យសង្គម ដោយធ្វើឲ្យប្រជាជនងាយធ្លាក់ចូលទៅក្នុងភាពក្រីក្រ។

ក្នុងផ្នែកជំនួយសង្គម ប្រជាជនក្រីក្រនិងងាយរងគ្រោះបានទទួលនូវការគាំពារផ្នែកសុខភាពតាមរយៈការដាក់ឲ្យដំណើរការមូលនិធិសមធម៌ ទន្ទឹមនឹងការទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីជាទុនសម្រាប់ការស្វែងរកការងារធ្វើ ព្រមទាំង ការទទួលបានសេវាលើកកម្ពស់សម្បទាវិជ្ជាជីវៈពីមូលនិធិជនពិការ។ ភាពខ្វះចន្លោះនៃប្រព័ន្ធជំនួយសង្គមបច្ចុប្បន្ន គឺការលើកកម្ពស់កម្មវិធីអាហារូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះនិងកុមារ ការផ្តល់អាហារូបករណ៍ដើម្បីលើកទឹកចិត្តដល់ការចុះឈ្មោះចូលរៀនឲ្យបានទាន់ពេលវេលា និងការលើកកម្ពស់ជីវភាពសម្រាប់ជនចាស់ជរាផងដែរ។

ចំពោះផ្នែកសន្តិសុខសង្គម បច្ចុប្បន្ន មន្ត្រីសាធារណៈទទួលបានការគាំពារនៅពេលចូលនិវត្តន៍ និងពេលបាត់បង់សមត្ថភាពការងារពី ប.ជ.ស និង ប.ជ.អ។ រីឯ កម្មករនិយោជិតទទួលបានការថែទាំសុខភាពជម្ងឺវិជ្ជាជីវៈ និងគ្រោះថ្នាក់ការងារពី ប.ស.ស។ ដោយឡែក ការថែទាំសុខភាពទូទៅសម្រាប់មន្ត្រីសាធារណៈ និងកម្មករនិយោជិត ព្រមទាំង ប្រជាជនទូទៅ នៅមានភាពខ្វះចន្លោះនៅឡើយ។ ជាមួយគ្នានេះ កម្មករនិយោជិត និងប្រជាជនទូទៅ ក៏មិនទាន់ទទួលបានការគាំពារសម្រាប់ពេលចូលនិវត្តន៍ពីការងារឬពេលឈានចូលវ័យជរានៅឡើយ។ ចំណែក ហានិភ័យក្នុងការបាត់បង់ការងារ ក៏មិនទាន់មានការការពារ។ រូបភាពខាងក្រោមបង្ហាញពីវិវឌ្ឍនភាព និងភាពខ្វះចន្លោះនៃប្រព័ន្ធគាំពារសង្គមទាំងមូលទៅតាមវដ្តជីវិតរបស់មនុស្ស។

### រូបភាពទី១០៖ អភិក្រមជាលក្ខណៈវដ្តជីវិតនៃប្រព័ន្ធគាំពារសង្គម



## ១.៧ រចនាសម្ព័ន្ធនៃឯកសារក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម

ការរៀបចំឯកសារនេះ បានឆ្លុះបញ្ចាំងពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម ព្រមទាំង ផលប៉ះពាល់នៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ដែលអាចមានឥទ្ធិពលដល់ស្ថិរភាពនៃថវិកាជាតិ ប្រព័ន្ធហិរញ្ញវត្ថុ វិស័យសេដ្ឋកិច្ច និងសង្គមកិច្ចទាំងមូល។

ការអនុវត្តកម្មវិធីកំណែទម្រង់ ដែលបានដាក់ចេញនៅក្នុងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ នេះ ត្រូវគិតគូរដល់បញ្ហាប្រឈមជាក់ស្តែងក្នុងពេលអនុវត្ត ពីព្រោះសកម្មភាពកំណែទម្រង់មួយចំនួន ទាមទារឲ្យមានបុរេលក្ខខណ្ឌសមស្របទៅតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ច និងនយោបាយ។ ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នមានសមត្ថកិច្ចអង្គការជាតិនិងអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍នានា គឺជាកត្តាសំខាន់ដើម្បីសម្រេចជោគជ័យក្នុងការធ្វើកំណែទម្រង់។ ដូច្នេះ រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់លើល្បឿននៃដំណើរការកែទម្រង់ និងតាមដានជាប្រចាំលើការអនុវត្តជាក់ស្តែង និងបញ្ហាប្រឈមដែលអាចកើតមានឡើងដើម្បីចាត់វិធានការសមស្រប និងទាន់ពេលវេលា។

ឯកសារក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ មានរចនាសម្ព័ន្ធដូចតទៅ៖ ជំពូកទី១ ទិដ្ឋភាពទូទៅ ، ជំពូកទី២ ប្រព័ន្ធជំនួយសង្គម ، ជំពូកទី៣ ប្រព័ន្ធសន្តិសុខសង្គម ، ជំពូកទី៤ អភិបាលកិច្ច ، ជំពូកទី៥ បញ្ហាឆ្លងវិស័យ ، និងជំពូកទី៦ ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍឆ្នាំ២០១៦-២០២៥។

# ◆ ជំពូកទី ២

# ប្រព័ន្ធជំនួយសង្គម

# ជំពូកទី២
# ប្រព័ន្ធជំនួយសង្គម

គោលបំណងនៃការពង្រឹងការអភិវឌ្ឍប្រព័ន្ធជំនួយសង្គម គឺដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនក្រីក្រនិងងាយរងគ្រោះ ទន្ទឹមនឹងការពង្រឹងសមត្ថភាពរបស់ពួកគាត់ឲ្យរក្សាបាននូវស្ថិរភាពប្រាក់ចំណូល ក្នុងស្ថានភាពសេដ្ឋកិច្ចដែលមានការប្រកួតប្រជែងខ្លាំង។

កម្មវិធីជំនួយសង្គម គាំទ្រដល់ការសម្រេចគោលដៅអភិវឌ្ឍន៍ជាអាទិភាពរបស់កម្ពុជា រួមមានៈ កំណើនប្រកបដោយបរិយាប័ន្ន ការកាត់បន្ថយភាពក្រីក្រ និងពិពិធកម្មសេដ្ឋកិច្ច។ វត្តមានរបស់ប្រព័ន្ធជំនួយសង្គម រួមចំណែកក្នុងការជំរុញកំណើនផលិតភាពក្នុងសេដ្ឋកិច្ច តាមរយៈការផ្លាស់ប្តូរជីវភាពរបស់ប្រជាជនក្រីក្រនិងងាយរងគ្រោះ ទៅជាប្រជាជនដែលមានចំណូលសមរម្យ ពោលគឺការបង្វែរក្រុមប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅក្នុងប្រព័ន្ធ។ កត្តានេះ ក៏ផ្តល់ផលវិជ្ជមានផងដែរដល់ស្ថិរភាពនៃថវិកាជាតិ និងការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គម តាមរយៈលទ្ធភាពនៃការបង់ពន្ធជូនរដ្ឋ និងលទ្ធភាពក្នុងការបង់ភាគទានចូលក្នុងមូលនិធិសន្តិសុខសង្គម។

កម្មវិធីជំនួយសង្គម ផ្តោតលើការផ្តល់ការគាំពារដល់ប្រជាជនក្រីក្រនិងងាយរងគ្រោះ ដែលក្នុងនោះត្រូវបានបែងចែកជាបីក្រុមរួមមាន (១) ប្រជាជនដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ (២) ប្រជាជនរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ ដែលមានការប្រឈមខ្ពស់ពេលមានវិបត្តិ និង (៣) ប្រជាជនដែលងាយរងគ្រោះ រួមមានៈ ទារកនិងកុមារ ស្ត្រីមានផ្ទៃពោះ គ្រួសារដែលខ្វះអាហារូបត្ថម្ភ ជនពិការ និងជនចាស់ជរាគ្មានទីពឹង។ កុមារតូចៗត្រូវបានយកចិត្តទុកដាក់ជាពិសេស ព្រោះរយៈពេល ១ ០០០ ថ្ងៃដំបូងនៃជីវិតគឺជារយៈពេលដ៏សំខាន់សម្រាប់ការរីកលូតលាស់។ គោលដៅអាទិភាពមួយទៀត គឺការផ្តោតការយកចិត្តទុកដាក់លើកុមារដែលត្រូវទទួលការសិក្សា ព្រោះការសិក្សានៅថ្នាក់បឋមនិងមធ្យមសិក្សាមានការជះឥទ្ធិពលដោយផ្ទាល់ដល់ការងារនិងមុខរបរ និងផលិតភាពនាពេលអនាគត។ ជនពិការ និងជនចាស់ជរាគ្មានទីពឹងក៏នឹងត្រូវទទួលបានការយកចិត្តទុកដាក់ជាពិសេសផងដែរ។

## ២.១ ការឆ្លើយតបនឹងគ្រោះអាសន្ន

### ២.១.១ ទិដ្ឋភាពទូទៅ

គ្រួសារក្រីក្រនិងងាយរងគ្រោះ ងាយនឹងទទួលរងផលប៉ះពាល់ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ រួមមានៈ ទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះ ជាដើម។ ស្ត្រី និងកុមារនៃគ្រួសារក្រីក្រជាទូទៅ រងគ្រោះដោយសារកត្តាទាំងនោះ នៅពេលដែលទ្រព្យសម្បត្តិត្រូវបានបំផ្លាញ បាត់បង់ឱកាសការងារ ឬសេវាសង្គមត្រូវបានកាត់ផ្តាច់ ជាដើម។ល។ វិបត្តិទាំងនេះ ធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពរបស់គ្រួសារក្រីក្រ ក្នុងការងើបខ្លួនចេញពីភាពក្រីក្រ ឬរុញច្រានពួកគេឲ្យត្រឡប់ចូលភាពក្រីក្រវិញ ឬធ្វើឲ្យពួកគេកាន់តែធ្លាក់ចូលជ្រៅទៅក្នុងភាពក្រីក្រ។

រាជរដ្ឋាភិបាល តាមរយៈគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បាននិងកំពុងគ្រប់គ្រងគម្រោងជំនួយស្បៀងអាហារ ដែលផ្គត់ផ្គង់ស្បៀងអាហារដល់គ្រួសារក្រីក្រនៅពេលមានគ្រោះមហន្តរាយកើតឡើង។ បន្ថែមលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏បានបង្កើតកម្មវិធីសន្តិសុខស្បៀងសំដៅការពារសន្តិសុខស្បៀងសម្រាប់ប្រជាជនក្រីក្រនិងងាយរងគ្រោះ ដែលរងផលប៉ះពាល់ពីការកើនឡើងនៃថ្លៃស្បៀងអាហារនៅក្នុងអំឡុងពេលមានគ្រោះអាសន្ន ដែលក្នុងនោះស្បៀងបម្រុងចំនួន ១៦ ០០០ តោន ស្រូវពូជចំនួន ៣ ០០០ តោន និងពូជដំណាំចំនួន ៥០ តោនត្រូវបានរក្សាទុកក្រោមកម្មវិធីនេះ។

### ២.១.២ បញ្ហាប្រឈម

យន្តការដែលមានស្រាប់មិនទាន់មានលក្ខណៈសមស្រប និងគ្រប់គ្រាន់ ដើម្បីដោះស្រាយ និងឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលនឹងអាចកើតមានឡើងជាបន្តបន្ទាប់នៅឡើយ។ បញ្ហាប្រឈមចម្បងនៅពេលនេះ គឺការពង្រឹងសមត្ថភាពហិរញ្ញវត្ថុ សមត្ថភាពស្ថាប័ន និងសមត្ថភាពធនធានមនុស្ស ដើម្បីរៀបចំគោលនយោបាយ ឬកម្មវិធី ដែលជាយន្តការអេចិន្ត្រៃយ៍ ដើម្បីឆ្លើយតបឲ្យទាន់ពេលចំពោះគ្រោះមហន្តរាយនានា។

បញ្ហាប្រឈមមួយចំនួនទៀត គឺតម្រូវការនៃការភ្ជាប់ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពរវាងជំនួយមនុស្សធម៌ និងប្រព័ន្ធជំនួយសង្គម ដើម្បីកំណត់បុគ្គលដែលងាយទទួលរងគ្រោះបំផុតក្នុងពេលដែលមានគ្រោះមហន្តរាយ។

### ២.១.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត

ការកសាងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស គឺជាកត្តាចម្បងដែលត្រូវពង្រឹង ដើម្បីត្រៀមខ្លួនក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយនានាដែលនឹងកើតមានឡើងជាបន្តបន្ទាប់។ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងសមត្ថភាពប្រព័ន្ធស្បៀងបម្រុងកម្រិតជាតិ។

រាជរដ្ឋាភិបាលនឹងសិក្សាអំពីលទ្ធភាពក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដែលមានលក្ខណៈទូលំទូលាយ ដើម្បីកំណត់ឲ្យបានច្បាស់នូវអត្តសញ្ញាណប្រជាជនក្រីក្រនិងងាយរងគ្រោះ តាមរយៈការតភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណជនក្រីក្រ និងជាបន្តបន្ទាប់អភិវឌ្ឍទៅជាប្រព័ន្ធចុះបញ្ជីរួមសម្រាប់គ្រួសារក្រីក្រនិងងាយរងគ្រោះ។

## ២.២ ការអភិវឌ្ឍមូលធនមនុស្ស

### ២.២.១ ទិដ្ឋភាពទូទៅ

#### ២.២.១.១ ការគាំពារស្ត្រីមានផ្ទៃពោះ និងកុមារ

គោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស ផ្តើមចេញពីការគិតគូរលើអាហារូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះនិងកុមារ។ ការទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់គឺជាកត្តាសំខាន់ដើម្បីជំរុញការលូតលាស់និងបង្កើនសមត្ថភាពស្រូបយកចំណេះដឹងរបស់កុមារតូចៗ ដែលនឹងរួមចំណែកដល់លទ្ធផលនៃការសិក្សា និងជាចុងក្រោយផ្តល់នូវផលិតភាពការងារដ៏ល្អប្រសើរ។

គម្រោងសាកល្បងមួយចំនួន ដែលផ្តល់ប្រាក់ឧបត្ថម្ភដើម្បីផ្គត់ផ្គង់អាហារូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះនិងកុមារបាននិងកំពុងអនុវត្តក្នុងភាពជាដៃគូរវាងស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ លទ្ធផលជាបឋមបង្ហាញថា ការវិនិយោគលើគម្រោងទាំងនេះមានផលវិជ្ជមាន និងអាចអនុវត្តបាននៅកម្រិតថ្នាក់ក្រោមជាតិ។

### ២.២.១.២ អាហារូបត្ថម្ភនៅតាមសាលារៀន

ក្រៅពីនេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គការកម្មវិធីស្បៀងអាហារពិភពលោក (WFP) អនុវត្តកម្មវិធីផ្តល់អាហារពេលព្រឹកនៅតាមសាលារៀនដល់សិស្សប្រមាណ ៣០០ ០០០ នាក់ នៅក្នុងខេត្តចំនួន ៩ ដែលជាតំបន់មានអត្រាអសន្តិសុខស្បៀងខ្ពស់ និងមានកម្រិតការអប់រំទាប។ លទ្ធផលនៃការវាយតម្លៃបង្ហាញថា កម្មវិធីនេះបានជំរុញឲ្យមានការកើនឡើងនៃអត្រាចុះឈ្មោះចូលរៀនរបស់កុមារមកពីគ្រួសារក្រីក្រនិងងាយរងគ្រោះ។

### ២.២.១.៣ ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា

ការសម្រេចបាននូវគោលបំណងនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម គឺការផ្តល់ឱកាសឲ្យកុមារកម្ពុជាគ្រប់រូបទទួលបានការអប់រំស្មើៗគ្នា ដែលជាការត្រៀមខ្លួនសម្រាប់ទទួលយកឱកាសការងារសមរម្យ និងក្លាយជាប្រជាជនប្រកបដោយការទទួលខុសត្រូវ។ បច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តកម្មវិធីអាហារូបករណ៍នៅថ្នាក់បឋមសិក្សា ដោយផ្តល់ថវិកាចំនួន ៦០ ដុល្លារក្នុងមួយឆ្នាំសម្រាប់សិស្សរៀនថ្នាក់ទី ៤-៦ ប្រមាណ ៧៥ ០០០ នាក់។ សិស្សប្រមាណ ២៥ ០០០ នាក់បន្ថែមទៀតក៏ទទួលបានអាហារូបករណ៍ផងដែរ តាមរយៈការជួយឧបត្ថម្ភរបស់អង្គការស្បៀងអាហារពិភពលោក។ កម្មវិធីអាហារូបករណ៍ថ្នាក់បឋមសិក្សានេះ មានឥទ្ធិពលទៅលើការចុះឈ្មោះចូលរៀនទាន់ពេលវេលារបស់កុមារមកពីគ្រួសារក្រីក្រនិងងាយរងគ្រោះ។ បន្ថែមលើនេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានផ្តល់អាហារូបករណ៍ថ្នាក់មធ្យមសិក្សា សម្រាប់កុមារមកពីគ្រួសារក្រីក្រនិងងាយរងគ្រោះផងដែរ ក្នុងគោលបំណងលើកទឹកចិត្តដល់យុវជនឲ្យបន្តការរៀនសូត្ររហូតដល់បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ។

## ២.២.២ បញ្ហាប្រឈម

### ២.២.២.១ ការគាំពារស្ត្រីមានផ្ទៃពោះ និងកុមារ

ខណៈដែលគុណភាពនៃសេវាសុខាភិបាលត្រូវបានពង្រឹង ការលើកកម្ពស់អាហារូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះនិងកុមារនៅមិនទាន់មានវឌ្ឍនភាពខ្លាំងក្លានៅឡើយ។ លទ្ធផលនៃការអង្កេតសុខភាព និងប្រជាសាស្ត្រឆ្នាំ២០១៤បង្ហាញថា កុមារអាយុក្រោម ៥ ឆ្នាំ ប្រមាណ ៣២ ភាគរយ មានបញ្ហាកម្ពស់ (ក្រិន) ១០ ភាគរយ មានភាពស្គមស្គាំង និង ២៤ ភាគរយ មានទម្ងន់មិនគ្រប់។ ស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម ៥ ឆ្នាំមកពីគ្រួសារក្រីក្រងាយនឹងជួបប្រទះបញ្ហាកង្វះអាហារូបត្ថម្ភ ដោយសារកង្វះធនធានហិរញ្ញវត្ថុ និងព័ត៌មាន ដែលចាំបាច់ដើម្បីទទួលសេវាថែទាំសុខភាព និងរបបអាហារូបត្ថម្ភ ព្រមទាំង ទឹកស្អាត និងអនាម័យ ផងដែរ។

បញ្ហាប្រឈមចម្បងមួយទៀតគឺកង្វះការពិនិត្យផ្ទៃពោះសមស្រប។ បច្ចុប្បន្ន រាជរដ្ឋាភិបាលបានទទួលជោគជ័យក្នុងការជំរុញឲ្យស្ត្រីកាន់តែច្រើនឡើងមកសម្រាលកូននៅតាមមន្ទីរពេទ្យ និងកាត់បន្ថយការពឹងផ្អែកលើឆ្មបតាមផ្ទះ និងវិធីសាស្ត្របុរាណ។ ប៉ុន្តែស្ត្រីភាគច្រើន ជាពិសេស នៅតាមតំបន់ជនបទ មិនបានមកទទួលយកសេវាពិនិត្យសុខភាពសមស្របក្នុងអំឡុងពេលមានផ្ទៃពោះនៅឡើយ ដោយសារកង្វះការយល់ដឹងពីការគាំពារនេះ និងបញ្ហាហិរញ្ញវត្ថុ ជាដើម។

### ២.២.២.២ ការផ្តល់អាហារនៅតាមសាលារៀន

កម្មវិធីផ្តល់អាហារពេលព្រឹកនៅតាមសាលារៀន មិនទាន់អនុវត្តបានទូទាំងប្រទេសនៅឡើយ ហើយហិរញ្ញប្បទានសម្រាប់ទ្រទ្រង់កម្មវិធីនេះ ពឹងផ្អែកភាគច្រើនលើការឧបត្ថម្ភរបស់ដៃគូអភិវឌ្ឍន៍។ ការគ្រប់គ្រងកម្មវិធីឲ្យមានប្រសិទ្ធភាព ដើម្បីសម្រេចបាននូវគោលដៅលើកកម្ពស់សុខភាពកុមារ និងជំរុញឲ្យកុមារអាចចូលរៀនពេញលេញ នៅតែជាបញ្ហាដែលត្រូវគិតគូរ និងដោះស្រាយ។

### ២.២.២.៣ ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា

បញ្ហាសេដ្ឋកិច្ច គឺជាកត្តាចម្បងដែលមានផលប៉ះពាល់ដល់ឱកាសក្នុងការទទួលយកការអប់រំរបស់កុមារ។ កុមារមកពីគ្រួសារក្រីក្រ និងងាយរងគ្រោះ ត្រូវបានបង្ខំឲ្យបោះបង់ការសិក្សា និងចូលបម្រើការងារមិនផ្លូវការ ដែលនេះជាកត្តាជំរុញឲ្យភាពក្រីក្របន្តពីមួយជំនាន់ទៅមួយជំនាន់។

អត្រាចុះឈ្មោះចូលរៀននៅមានកម្រិតទាបនៅឡើយ ក្នុងចំណោមកុមារមកពីគ្រួសារក្រីក្រនិងងាយរងគ្រោះ។ រីឯ អត្រាបោះបង់ការសិក្សាបែរជាមានកម្រិតខ្ពស់ទៅវិញ។ អត្រាបោះបង់ការសិក្សានៅថ្នាក់បឋមក្នុងឆ្នាំ២០១៣-២០១៤ មានប្រមាណដល់ទៅ ១០.៥ ភាគរយ ដែលក្នុងនោះការចុះឈ្មោះចូលរៀនយឺត គឺជាកត្តាចម្បងពាក់ព័ន្ធដល់ការបោះបង់ការសិក្សានេះ។

កម្មវិធីអាហារូបករណ៍ក៏នៅមានកម្រិតនៅឡើយ។ បច្ចុប្បន្ន អាហារូបករណ៍ត្រូវបានផ្តល់ជូនតែនៅថ្នាក់បឋមសិក្សាថ្នាក់ទី ៤-៦ ប៉ុណ្ណោះ ដែលក្នុងនោះនៅមានសិស្សថ្នាក់ទី ៤-៦ ប្រមាណ ៥០ ០០០ នាក់ទៀតមិនទាន់បានទទួលអាហារូបករណ៍នៅឡើយ។ ករណីនេះ បង្ហាញឲ្យឃើញពីតម្រូវការអាហារូបករណ៍ជាច្រើនទៀត ជាពិសេស សម្រាប់ថ្នាក់បឋមសិក្សាថ្នាក់ទី ១-៣ និងថ្នាក់មធ្យមសិក្សា។

## ២.២.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត

### ២.២.៣.១ កម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ និងកុមារ

រាជរដ្ឋាភិបាលនឹងសិក្សារៀបចំដាក់ឲ្យដំណើរការកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះនិងកុមារ ដែលផ្តោតលើការលើកកម្ពស់អាហារូបត្ថម្ភក្នុងកម្រិតថ្នាក់ជាតិ ផ្អែកលើលទ្ធផលនៃគម្រោងសាកល្បងបច្ចុប្បន្ន។ សមាសធាតុសំខាន់នៃការរៀបចំដាក់ឲ្យដំណើរការកម្មវិធីនេះ គឺការកំណត់ស្ថាប័នអនុវត្ត ដោយបែងចែកតួនាទី និងការទទួលខុសត្រូវឲ្យបានច្បាស់លាស់ រួមទាំង ការកសាងសមត្ថភាព។

កម្មវិធីនេះនឹងចាប់ផ្តើមដាក់ឲ្យដំណើរការនៅក្នុងខេត្តអាទិភាពមួយចំនួន (ខេត្តដែលមានបញ្ហាកង្វះអាហារូបត្ថម្ភខ្លាំងជាងគេ) នៅដំណាក់កាលដំបូង។ យន្តការវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីនេះនឹងត្រូវបានរៀបចំឡើង ហើយលទ្ធផលនៃការវាយតម្លៃនេះ ក៏នឹងត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការពង្រីកវិសាលភាពអនុវត្តនៅតាមបណ្តាខេត្តដទៃទៀត រហូតទូទាំងប្រទេស។

លើសពីនេះ ដើម្បីគាំពារសុខភាពមាតា និងទារក រាជរដ្ឋាភិបាលនឹងបន្តផ្តល់ការទ្រទ្រង់ និងលើកទឹកចិត្តចំពោះស្ត្រីមានផ្ទៃពោះ ជាពិសេសស្ត្រីក្នុងគ្រួសារក្រីក្រ ដើម្បីឲ្យពួកគេអាចទទួលបានការប្រឹក្សាយោបល់ និងការពិនិត្យផ្ទៃពោះសមស្រប។

**២.២.៣.២ កម្មវិធីផ្តល់អាហារនៅតាមសាលារៀន**

រាជរដ្ឋាភិបាលនឹងរៀបចំផែនការសកម្មភាព និងពង្រឹងសមត្ថភាពធនធានមនុស្ស ដើម្បីត្រៀមខ្លួនក្នុងការទទួលយកនូវការគ្រប់គ្រង និងធ្វើហិរញ្ញប្បទានសម្រាប់ទ្រទ្រង់កម្មវិធីនេះនៅឆ្នាំ២០២១ ដែលជាចក្ខុវិស័យបានកំណត់រួចហើយនៅក្នុង "**ផែនទីបង្ហាញផ្លូវស្តីពីកម្មវិធីផ្តល់អាហារតាមសាលារៀន**"។ ប៉ុន្តែមុននឹងបន្ត និងពង្រីកកម្មវិធីនេះ ចាំបាច់ត្រូវមានការវាយតម្លៃនៅលើការអនុវត្តបច្ចុប្បន្ន ព្រមទាំងការសិក្សាឲ្យបានច្បាស់លាស់នូវយន្តការគ្រប់គ្រង និងភាពទ្រទ្រង់បាននៃថវិកា ដើម្បីធានាប្រសិទ្ធភាពនៃកម្មវិធី។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងជំរុញការដាក់ឲ្យដំណើរការកម្មវិធីផ្តល់អាហារនៅតាមសាលារៀនដោយប្រើប្រាស់បន្លែដែលដាំនៅតាមផ្ទះ ដើម្បីបង្កើនគុណភាពអាហារូបត្ថម្ភសម្រាប់កុមារ។

**២.២.៣.៣ កម្មវិធីអាហារូបករណ៍សម្រាប់ថ្នាក់បឋមសិក្សា និងមធ្យមសិក្សា**

រាជរដ្ឋាភិបាលនឹងរៀបចំគោលនយោបាយជាតិស្តីពីអាហារូបករណ៍ ដើម្បីកំណត់អំពីយន្តការសម្រាប់ការគ្រប់គ្រង និងផ្តល់អាហារូបករណ៍ឲ្យមានប្រសិទ្ធភាពខ្ពស់នៅគ្រប់កម្រិតសិក្សា ដើម្បីលើកទឹកចិត្តដល់កុមារមកពីគ្រួសារក្រីក្រនិងងាយរងគ្រោះ ឲ្យចុះឈ្មោះចូលរៀនបានទាន់ពេលវេលា ព្រមទាំងជំរុញឲ្យពួកគេបន្តការសិក្សារហូតចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ ដែលជាកត្តាចាំបាច់ដើម្បីកាត់ផ្តាច់ការផ្ទេរភាពក្រីក្រពីជំនាន់មួយទៅជំនាន់មួយ។

## ២.៣ ការបណ្តុះបណ្តាលវិជ្ជាជីវៈ

### ២.៣.១ ទិដ្ឋភាពទូទៅ

លទ្ធផលនៃការអង្កេតចន្លោះជំរឿននៅឆ្នាំ២០១៣ បានបង្ហាញថា ៦៥ ភាគរយនៃចំនួនប្រជាជនសរុបមានអាយុចាប់ពី ១៥ ដល់ ៦៤ ឆ្នាំស្ថិតនៅក្នុងកម្លាំងពលកម្ម។ រៀងរាល់ឆ្នាំ ប្រជាជនវ័យក្មេងប្រមាណ ២៣ ០០០ នាក់ បានហក់ចូលក្នុងទីផ្សារការងារ។

ទិន្នន័យខាងលើបង្ហាញអំពីតម្រូវការខ្ពស់លើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។ ការបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាកត្តាចម្បងដែលរួមចំណែកក្នុងការ

លើកកម្ពស់ទីផ្សារការងារ។ យុវជនស្ថិតក្នុងអាយុធ្វើការដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់មានឱកាសច្រើនក្នុងការទទួលបានការងារដែលមានប្រាក់ចំណូលខ្ពស់ និងផ្តល់នូវផលិតភាពខ្ពស់។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញជាច្រើន រួមមាន (១) កម្មវិធីគរុនិស្សិតថ្នាក់ឧត្តម និងថ្នាក់មូលដ្ឋាន (២) បច្ចេកទេសក្រោយប្រមូលផល (៣) ការបណ្តុះបណ្តាលស្ពានចម្លងបន្តជំនាញ (Skill Bridging Program) (៤) ការបណ្តុះបណ្តាលពិសេសដល់ជនជាតិភាគតិច (៥) ការបណ្តុះបណ្តាលដើម្បីកាត់បន្ថយភាពក្រីក្រតាមរយៈមូលនិធិជាតិ (៦) ការបណ្តុះបណ្តាលជំនាញសហគ្រិនភាពជូនកម្មករ-កម្មការិនី តាមរយៈមូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី និង (៧) ការហ្វឹកហ្វឺនកូនជាងនៅតាមបណ្តាសហគ្រាសផ្សេងៗ។ ការបណ្តុះបណ្តាលទាំងនេះ មានទាំងវគ្គសិក្សារយៈពេលខ្លីរហូតដល់កម្រិតឧត្តមសិក្សា ដែលក្នុងនោះសិក្ខាកាម និងសិស្ស-និស្សិត ដែលបានបញ្ចប់ការសិក្សាចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ មានចំនួនសរុបប្រមាណ ៦០០ ០០០ នាក់។

### ២.៣.២ បញ្ហាប្រឈម

កម្រិតទាបនៃការទទួលបានការអប់រំ គឺជាបញ្ហាប្រឈមចម្បង ដែលនាំឲ្យយុវជនមួយចំនួនដែលបានឈានចូលក្នុងកម្លាំងពលកម្ម ក្លាយជាយុវជនគ្មានជំនាញ ឬមានជំនាញតិចតួច។ ដើម្បីមានសមត្ថភាពបច្ចេកទេស យុវជនចាំបាច់ត្រូវបញ្ចប់យ៉ាងហោចណាស់ថ្នាក់មធ្យមសិក្សា ដែលជាមូលដ្ឋានអាចទទួលបានការបណ្តុះបណ្តាលជំនាញ និងទទួលកាលានុវត្តភាពប្រសើរនៅក្នុងទីផ្សារការងារ។ បញ្ហាប្រឈមមួយទៀត គឺការផ្គូរផ្គងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទៅនឹងតម្រូវការទីផ្សារការងារ ជាពិសេស គឺភាពចាំបាច់ក្នុងការអភិវឌ្ឍយ៉ាងឆាប់រហ័សនូវជំនាញវិជ្ជាជីវៈច្រើនប្រភេទ នៅក្នុងបរិបទនៃពិពិធកម្មសេដ្ឋកិច្ច ។

### ២.៣.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត

រាជរដ្ឋាភិបាលនឹងបង្កើន និងពង្រីកវិសាលភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យកាន់តែទូលំ-ទូលាយ ជាពិសេស តាមរយៈការផ្តោតលើការពង្រីកកម្មវិធីស្ពានចម្លងបន្តជំនាញ សម្រាប់យុវជនដែលស្ថិតនៅក្រៅប្រព័ន្ធអប់រំផ្លូវការ និងកម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ (Voucher Skills Training Program – VSTP) សម្រាប់ប្រជាជនក្រីក្រនៅតាមជនបទ ដើម្បីទទួលយកវគ្គបណ្តុះបណ្តាលដែលមានវិញ្ញាបនបត្រ។

រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដើម្បីទ្រទ្រង់ការបណ្តុះបណ្តាលវិញ្ញាបនបត្រកម្រិត ១-៣ ជូនដល់យុវជនក្រីក្រ និងស្ត្រីនៅក្នុងវិស័យអាទិភាព ដូចជា៖ វិស័យសំណង់ ជួសជុលគ្រឿងចក្រ ព័ត៌មានវិទ្យា កម្មន្តសាល និងអគ្គិសនី ជាដើម។

លើសពីនេះ ដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជននៅក្នុងទីផ្សារការងារ រាជរដ្ឋាភិបាលក៏នឹងគិតគូរផងដែរអំពីការផ្ដល់លទ្ធភាពជូនយុវជនដែលស្ថិតក្នុងកម្លាំងពលកម្មស្រាប់ ដើម្បីអាចទទួលបានការបំពាក់បំប៉នក្នុងការបង្កើនជំនាញ និងបទពិសោធន៍របស់ខ្លួនថែមទៀត។

ដើម្បីពង្រឹងប្រសិទ្ធភាព និងសក្ដិសិទ្ធិភាពនៃកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈទាំងឡាយ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវមានយន្តការតាមដាន និងវាយតម្លៃសមស្រប។

## ២.៤ សុខុមាលភាពរបស់ប្រជាជនងាយរងគ្រោះ

### ២.៤.១ ទិដ្ឋភាពទូទៅ

ជនពិការ និងជនចាស់ជរា ត្រូវបានចាត់ទុកជាក្រុមប្រជាជនងាយរងគ្រោះ ដោយសារ ជាទូទៅ ពួកគាត់មានឱកាសតិចតួចក្នុងការរកចំណូល និងការទទួលយកសេវាសង្គម ព្រមទាំង មានតម្រូវការច្រើនលើជំនួយអាហារូបត្ថម្ភ និងសេវាថែទាំសុខភាព។

នៅឆ្នាំ២០១៤ កម្ពុជាមានមនុស្សចាស់ដែលមានអាយុចាប់ពី ៦៥ ឆ្នាំឡើងទៅ ប្រមាណ ៥ ភាគរយប៉ុណ្ណោះនៃប្រជាពលរដ្ឋសរុប។ ប៉ុន្តែចំនួននេះរំពឹងថានឹងកើនឡើងជាបន្តបន្ទាប់ ដោយសារការកើនឡើងនៃអាយុកាលសង្ឃឹមរស់ និងបម្រែបម្រួលកត្តាប្រជាសាស្ត្រ។ រីឯ ជនពិការក៏មានចំនួនច្រើនផងដែរ ប្រមាណដល់ទៅជាង ៣០០ ០០០ នាក់ ស្មើនឹងប្រមាណ ២ ភាគរយនៃប្រជាជនសរុបនៅឆ្នាំ២០១៣។

ជាទូទៅ ស្ត្រីទទួលរងការលំបាកដោយសារភាពចាស់ជរាច្រើនជាងបុរស។ ផ្ទុយទៅវិញ បុរសមានភាគរយពិការច្រើនជាងស្ត្រី ដោយសារកត្តាគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឬដោយសគ្រោះថ្នាក់ចរាចរណ៍ ... 

### ២.៤.២ បញ្ហាប្រឈម

#### ២.៤.២.១ ជនពិការ

ជនពិការ ជាពិសេស ជនពិការក្រីក្រតែងជួបប្រទះការរើសអើងពីសង្គម ព្រមទាំង ជួបការលំបាកទាំងផ្នែកកាយសម្បទា និងហិរញ្ញវត្ថុ ដែលរារាំងពួកគាត់ពីការទទួលយកសេវាសុខាភិបាល និងការអប់រំ ព្រមទាំង ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ផងដែរ។ កត្តានេះ នាំឲ្យជនពិការមិនមានលទ្ធភាពក្នុងការចូលរួមចំណែកក្នុងការបង្កើនផលិតភាពក្នុងសេដ្ឋកិច្ច ឬទទួលបានអត្ថប្រយោជន៍ពីកត្តាសេដ្ឋកិច្ចទាំងនេះឡើយ។

#### ២.៤.២.២ ជនចាស់ជរា

ក្នុងសង្គមកម្ពុជាក៏ដូចជាប្រទេសជាច្រើនក្នុងតំបន់អាស៊ីដែរ គ្រួសារ និងវត្តអារាមគឺជាទីពំនាក់របស់ជនចាស់ជរា។ បច្ចុប្បន្ន ថ្វីបើមធ្យោបាយប្រពៃណី នៃការថែរក្សាជនចាស់ជរាបែបនេះនៅតែត្រូវបានរក្សាក្ដី ប៉ុន្តែបទពិសោធន៍នៃការវិវឌ្ឍសង្គមទាំងក្នុង និងក្រៅតំបន់បានបង្ហាញថា ទំនើបកម្មសង្គម ជាពិសេស ការកែប្រែជាលំដាប់នូវឧស្សាហូបនីយកម្ម និងនគរូបនីយកម្មបានធ្វើឲ្យរបៀបរបប និងទម្លាប់

ប្រពៃណីនៃការគាំពារជនចាស់ជរាមានការប្រែប្រួល ដែលតម្រូវឲ្យជនចាស់ជរាកាន់តែច្រើនឡើងត្រូវរស់នៅដោយខ្លួនឯង មិនមានការថែទាំ និងទំនុកបម្រុងពីសមាជិកគ្រួសារឡើយ។ ខណៈដែលការអភិវឌ្ឍប្រព័ន្ធថែទាំសុខភាព និងប្រព័ន្ធសោធននៅមានកម្រិត ការវិវឌ្ឍនេះនាំឲ្យជនចាស់ជរាភាគច្រើនប្រឈមនឹងការធ្លាក់ចូលទៅក្នុងភាពក្រីក្រ។

### ២.៤.៣ យុទ្ធសាស្រ្ត និងគោលដៅអនាគត

#### ២.៤.៣.១ កម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនពិការ

រាជរដ្ឋាភិបាលនឹងបន្តការដាក់ឲ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនពិការ ដែលបានកំណត់នៅក្នុងអនុក្រឹត្យស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍។ កម្មវិធីនេះនឹងត្រូវដាក់ឲ្យអនុវត្តសម្រាប់ជនពិការដែលជាសមាជិកនៃគ្រួសារក្រីក្រ ដែលកាន់កាប់បណ្ណសមធម៌។

អត្ថប្រយោជន៍ និងលក្ខខណ្ឌនៃកម្មវិធីនេះនឹងត្រូវកំណត់ដោយផ្អែកលើលទ្ធភាពទ្រទ្រង់នៃថវិកាជាតិ។ ការរៀបចំយន្តការកំណត់អត្តសញ្ញាណរបស់ជនពិការ គឺជាកត្តាចាំបាច់ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការផ្តល់អត្ថប្រយោជន៍តាមរយៈកម្មវិធីនេះ។

#### ២.៤.៣.២ កម្មវិធីគាំពារជនចាស់ជរា

រាជរដ្ឋាភិបាលនឹងសិក្សាអំពីលទ្ធភាពក្នុងការដាក់ឲ្យដំណើរការកម្មវិធីគាំពារជនចាស់ជរា ដែលជាសមាជិកនៃគ្រួសារដែលកាន់កាប់បណ្ណសមធម៌។ អត្ថប្រយោជន៍ និងលក្ខខណ្ឌនៃកម្មវិធីនេះនឹងត្រូវកំណត់ដោយផ្អែកលើលទ្ធភាពទ្រទ្រង់នៃថវិកាជាតិ។

កម្មវិធីនេះនឹងត្រូវសិក្សាដាក់ឲ្យដំណើរការជាកម្មវិធីកញ្ចប់គ្រួសារ (Family Package) រួមជាមួយនឹងកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ និងកុមារ ។

# ◆ ជំពូកទី៣

# ប្រព័ន្ធសន្តិសុខសង្គម

# ជំពូកទី៣
# ប្រព័ន្ធសន្តិសុខសង្គម

ក្នុងខណៈដែលប្រព័ន្ធជំនួយសង្គម គឺជាយន្តការផ្តល់ការទ្រទ្រង់ឧបត្ថម្ភដោយផ្ទាល់ ឬដោយប្រយោលចំពោះប្រជាជនក្រីក្រនិងងាយរងគ្រោះ ដែលជាធម្មតាត្រូវប្រើប្រាស់ហិរញ្ញប្បទានថវិកាជាតិ និង/ឬជំនួយអភិវឌ្ឍន៍ផ្លូវការ ប្រព័ន្ធសន្តិសុខសង្គមបង្កើតនូវយន្តការមានលក្ខណៈ "កាតព្វកិច្ច" និង "ខ្លួនទីពឹងខ្លួន" ដែលលើកទឹកចិត្តនិងជំរុញឲ្យប្រជាជនស្វែងរកការគាំពារចំពោះមុខហានិភ័យ ដែលអាចផ្តល់ផលប៉ះពាល់ជាអវិជ្ជមានដល់សន្តិសុខប្រាក់ចំណូលរបស់ខ្លួន ដោយសារ ការឈឺថ្កាត់ មាតុភាព គ្រោះថ្នាក់ការងារ និកម្មភាព ពិការភាព ជរាភាព និងមរណភាព ជាដើម។ ប្រព័ន្ធសន្តិសុខសង្គម គឺជាប្រព័ន្ធបង់ភាគទាន ដែលទាមទារឲ្យមានការចូលរួមពីសំណាក់និយោជិត និងនិយោជក ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន និងពីនិវត្តជន ព្រមទាំង ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធផងដែរ។ ទោះជាយ៉ាងណា រាជរដ្ឋាភិបាលនឹងរ៉ាប់រងលើការបង់ភាគទានជំនួសប្រជាជនក្រីក្រងាយរងគ្រោះ និងក្រុមប្រជាជនគោលដៅផ្សេងទៀត ដែលរាជរដ្ឋាភិបាលយល់ថាចាំបាច់ដើម្បីលើកកម្ពស់ជីវភាពជនទាំងនោះទៅតាមលទ្ធភាពនៃការទ្រទ្រង់បាននៃថវិកាជាតិ។ ការរ៉ាប់រងលើការបង់ភាគទានជំនួសទាំងស្រុងឬមួយភាគ ត្រូវអនុវត្តដោយផ្អែកលើលក្ខខណ្ឌសមស្រប និងច្បាស់លាស់ ដើម្បីជៀសវាងការកើតឡើងនូវ "ហានិភ័យចិត្តសាស្ត្រ" (Moral hazard) ដែលមិនលើកទឹកចិត្តដល់ប្រជាជនឲ្យមានការសន្សំសម្រាប់គាំពារហានិភ័យជាយថាហេតុ និង/ឬដែលអាចមានផលប៉ះពាល់ជាអវិជ្ជមានទៅលើផលិតភាពការងារ។ ដោយផ្អែកលើហេតុផលនេះ ក៏ដូចជាកត្តាសំខាន់ដទៃទៀតនៅរយៈកាលវែងទៅអនាគត និងនៅពេលលក្ខខណ្ឌសេដ្ឋកិច្ច-សង្គមសមស្រប រាជរដ្ឋាភិបាលនឹងដកខ្លួនបន្តិចម្តងៗពីការធ្វើហិរញ្ញប្បទានរបបសន្តិសុខសង្គមជាក់លាក់មួយចំនួន។ ដូចនេះ ប្រព័ន្ធសន្តិសុខសង្គមត្រូវពឹងផ្អែកលើប្រភពហិរញ្ញប្បទានពីការបង់ភាគទាន ព្រមទាំង ចំណូលពីការវិនិយោគធនធានហិរញ្ញវត្ថុដែលត្រូវបានប្រមូលផ្តុំនោះ។

## ៣.១ សោធន

### ៣.១.១ ទិដ្ឋភាពទូទៅ

ជាទូទៅ ប្រជាជនកម្ពុជាមិនមានទម្លាប់រៀបចំផែនការហិរញ្ញវត្ថុសម្រាប់ខ្លួនឯងនៅពេលដែលពួកគាត់ឈានចូលវ័យចាស់ជរានោះឡើយ ដោយភាគច្រើនត្រូវពឹងផ្អែកលើការឧបត្ថម្ភរបស់កូន-ចៅ។ ទម្លាប់នេះ ជាកត្តាជំរុញឲ្យប្រជាជនកម្ពុជាប្រឈមនឹងហានិភ័យខ្ពស់ ក្នុងការធ្លាក់ចូលក្នុងភាពក្រីក្រនៅពេលចូលដល់វ័យចាស់ជរា ជាពិសេស ក្នុងករណីកូនចៅដែលជាជំហរសេដ្ឋកិច្ចគ្រួសារស្ថិតក្នុង ឬធ្លាក់ទៅក្នុងក្រុមប្រជាជនក្រីក្រ។ រហូតមកដល់ពេលនេះ មានតែមន្ត្រីរាជការ យោធិន និងនគរបាលបម្រើការងារក្នុងវិស័យសាធារណៈ ចំនួនប្រមាណ ៧ ភាគរយនៃប្រជាជនសរុបប៉ុណ្ណោះ ទទួលបានប្រាក់សោធននៅពេលចូលនិវត្តន៍ ដែលជាផ្នែកមួយនៃរបបសន្តិសុខសង្គម។

ក្រៅពីនេះ ស្ថាប័នមួយចំនួនក៏បានរៀបចំឲ្យមានរបបសោធនសម្រាប់មន្ត្រី-បុគ្គលិករបស់ខ្លួន ផងដែររួមមាន៖ ធនាគារជាតិនៃកម្ពុជា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងកំពង់ផែស្វយ័តក្រុងភ្នំពេញ ដែលរបបសោធនទាំងនោះស្ថិតក្រោមការគ្រប់គ្រង និងចាត់ចែងដោយស្ថាប័នផ្ទាល់ ហើយក៏មិនមាន ច្បាប់ និងបទប្បញ្ញត្តិសម្រាប់គ្រប់គ្រង និងត្រួតពិនិត្យនៅឡើយ។

ប្រព័ន្ធសោធននៅកម្ពុជា បានចាប់ផ្តើមឡើងដោយមានលក្ខណៈដាច់ដោយឡែកពីគ្នាទៅតាម ប្រភេទនៃសមាជិកគោលដៅ។ តាមរយៈព្រះរាជក្រឹត្យស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងព្រះរាជក្រឹត្យស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាលបានបង្កើតគ្រឹះស្ថាន សាធារណៈចំនួនពីរគឺ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) និងបេឡាជាតិ អតីតយុទ្ធជន (ប.ជ.អ) ដើម្បីគ្រប់គ្រង និងបើកផ្តល់ប្រាក់សោធនសម្រាប់មន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន ដែលជាមន្ត្រីនគរបាលជាតិ និងយោធិន។ យោងតាមបទប្បញ្ញត្តិនេះ ប.ជ.ស និង ប.ជ.អ ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ និងអតីតយុទ្ធជន ដែលស្ថិតក្រោមការគ្រប់គ្រង និង ចាត់ចែងរបស់ ប.ជ.ស និង ប.ជ.អ ទទួលហិរញ្ញប្បទានទាំងស្រុងពីថវិការដ្ឋ។ តាមរយៈការព្យាករណ៍ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅឆ្នាំ២០១៦នេះ រាជរដ្ឋាភិបាលនឹងត្រូវ ចំណាយថវិកាសរុបប្រមាណ ៥៥៦ ៣៤៦ លានរៀល ដើម្បីទ្រទ្រង់របបសន្តិសុខសង្គមសម្រាប់មន្ត្រី រាជការស៊ីវិល និងអតីតយុទ្ធជន ចំនួន ១០៦ ៦៣៣ នាក់។ ក្នុងនោះ ថវិកាដែលនឹងត្រូវចំណាយលើ ការបើកប្រាក់សោធនមានចំនួនប្រមាណ ៣៩៥ ១៧៩ លានរៀល។

**រូបភាពទី១១៖ ចំណាយថវិការដ្ឋក្នុងការទ្រទ្រង់របបសន្តិសុខសង្គម (គិតជាលានរៀល)**




ប្រភព៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ជាមួយគ្នានេះ តាមរយៈការអនុម័តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែល ស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ រាជរដ្ឋាភិបាលបានបង្កើតបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៅឆ្នាំ២០០៧ ជាគ្រឹះស្ថានសាធារណៈទទួលបន្ទុកលើការគ្រប់គ្រងនិងចាត់ចែងរបបប្រាក់

សោធនសម្រាប់កម្មករនិយោជិត។ ប៉ុន្តែ រហូតមកដល់ពេលនេះ របបសោធនសម្រាប់កម្មករនិយោជិតនៅមិនទាន់ត្រូវបានដាក់ឲ្យអនុវត្តនៅឡើយ។

## ៣.១.២ បញ្ហាប្រឈម

### ៣.១.២.១ ក្របខ័ណ្ឌស្ថាប័ន

*ក. លក្ខណៈរាយប៉ាយនៃស្ថាប័នប្រតិបត្តិករ*

ស្ថាប័នប្រតិបត្តិកររបបសោធនបច្ចុប្បន្នគឺ ប.ជ.ស ប.ជ.អ និង ប.ស.ស ដែលមានមុខងារ និងភារកិច្ចស្ទើរតែដូចគ្នាទាំងស្រុង ដែលមានភាពខុសគ្នាតែលើសមាជិកគោលដៅប៉ុណ្ណោះ។ ការដាក់ឲ្យដំណើរការគ្រឹះស្ថានសាធារណៈផ្សេងៗគ្នា ដើម្បីគ្រប់គ្រង និងចាត់ចែងរបបសោធនទៅតាមសមាជិកគោលដៅរៀងខ្លួនបែបនេះ នាំឲ្យមានចំណាយខ្ពស់លើដំណើរប្រតិបត្តិការស្ថាប័ន (ទាំងការឧបត្ថម្ភបុគ្គលិក និងការរៀបចំប្រព័ន្ធព័ត៌មានវិទ្យា ជាដើម)។

**រូបភាពទី១២៖ រចនាសម្ព័ន្ធស្ថាប័ននៃប្រព័ន្ធសន្តិសុខសង្គមបច្ចុប្បន្ន**




*ខ. អសង្គតិភាពនៃតាវកាលិក*

ការកំណត់តាវកាលិកសោធនសម្រាប់មន្ត្រីរាជការ នគរបាល និងយោធិនមិនមានសង្គតិភាពនឹងគ្នា ដោយសារការកំណត់តាវកាលិកសោធនទាំងនោះត្រូវបានកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិដោយឡែកពីគ្នា។ សោធនសម្រាប់មន្ត្រីរាជការ ត្រូវបានកំណត់ដោយអនុក្រឹត្យលេខ ៥៩ អនក្រ.បក

ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។ សោធនសម្រាប់មន្ត្រីនគរបាល ត្រូវបានកំណត់ដោយច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា។ រីឯ ប្រាក់សោធនរបស់យោធិនត្រូវបានកំណត់ដោយច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ។ អសង្គតិភាពនៃប្រាក់សោធននាំឲ្យមានអសមធម៌រវាងក្រុមផ្សេងៗនៃមន្ត្រីសាធារណៈ ជាពិសេស មន្ត្រីដែលមានឋានន្តរសក្តិប្រហាក់ប្រហែលគ្នា ប៉ុន្តែទទួលបានប្រាក់សោធនខុសគ្នា។

### ៣.១.២.២ ក្របខ័ណ្ឌហិរញ្ញវត្ថុ

*ក. សក្តានុពលនៃកំណើនចំណាយយ៉ាងគំហុក*

ចំណាយថវិកាសម្រាប់ទ្រទ្រង់របបសោធនសម្រាប់មន្ត្រីរាជការ និងអតីតយុទ្ធជនប្រចាំឆ្នាំកើនឡើងជាមធ្យមប្រមាណ ៣៨.៥ ភាគរយ ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៤។ ទន្ទឹមនេះ តាមរយៈគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការតម្លើងបៀវត្សជូនមន្ត្រីរាជការឲ្យបានយ៉ាងតិច ១ លានរៀលនៅឆ្នាំ២០១៨ នឹងធ្វើឲ្យចំណាយថវិការដ្ឋដើម្បីបើកផ្តល់ជូននិវត្តជនកើនឡើងយ៉ាងគំហុក[9] សម្រាប់រយៈពេលមធ្យម និងវែង ដែលដាក់សម្ពាធយ៉ាងខ្លាំងលើថវិកាជាតិ។

អង្គការពលកម្មអន្តរជាតិបានធ្វើការព្យាករណ៍ថា បន្ទុកនៃការទ្រទ្រង់របស់ថវិការដ្ឋចំពោះរបបសោធនសាធារណៈបច្ចុប្បន្ន ធៀបនឹងការចំណាយប្រាក់បៀវត្សមូលដ្ឋានសម្រាប់មន្ត្រីសាធារណៈ នឹងមានការកើនឡើងយ៉ាងគំហុកពីប្រមាណ ១៣.៨ ភាគរយនៅឆ្នាំ២០១៦ រហូតដល់ប្រមាណ ៤៦.៣ ភាគរយនៅឆ្នាំ២០៦៨ និងកើនឡើងរហូតដល់ប្រមាណ ៥៣.៩ ភាគរយ នៅឆ្នាំ២១០០។

**រូបភាពទី១៣៖ ការព្យាករណ៍អំពីការកើនឡើងនៃចំណាយថវិការដ្ឋ**




ប្រភព៖ អង្គការពលកម្មអន្តរជាតិ

[9] តារាងលិកសោធនត្រូវបានគណនាដោយផ្អែកលើភាគរយនៃប្រាក់បៀវត្សមូលដ្ឋានរបស់មន្ត្រីសាធារណៈ (៦០ ទៅ ៨០ ភាគរយ នៃបៀវត្សមូលដ្ឋាន)

*ខ. ការមិនទាន់អនុវត្តនូវអត្រាភាគទាន*

មកទល់ពេលនេះ រដ្ឋរ៉ាប់រងទាំងស្រុងលើចំណាយបើកផ្តល់ប្រាក់សោធនជូននិវត្តជន ទៅតាមតម្រូវការនៃចំណាយជាក់ស្តែងប្រចាំឆ្នាំ។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ស្តីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលតម្រូវឲ្យមន្ត្រីរាជការស៊ីវិលបង់ភាគទានចំនួន ៦ ភាគរយ និងរដ្ឋត្រូវចូលរួមបង់ភាគទានចំនួន ១៨ ភាគរយ។ ប៉ុន្តែ ការប្រមូលភាគទានតាមអត្រាដែលបានកំណត់រួចនេះមិនទាន់បានអនុវត្តនៅឡើយ។ ដូច្នេះ រដ្ឋនៅតែបន្តរ៉ាប់រងទាំងស្រុងលើការឧបត្ថម្ភនិវត្តជនដែលជាមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន។ គម្រោងតម្លើងបៀវត្សប្រចាំឆ្នាំ អាចនឹងគិតគូរពិចារណារួមគ្នាជាមួយនឹងការដាក់ឲ្យអនុវត្តការប្រមូលភាគទាននេះ។

*គ. បម្រែបម្រួលកត្តាប្រជាសាស្ត្រ*

បម្រែបម្រួលកត្តាប្រជាសាស្ត្រនឹងជំរុញឲ្យកម្ពុជាក្លាយទៅជាសង្គមចាស់ជរា តាមរយៈការកើនឡើងនៃអាយុកាលសង្ឃឹមរស់ និងការថយចុះនៃអត្រាបង្កកំណើត ជាដើម។ល។ កត្តាទាំងនេះ នាំឲ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើនិរន្តរភាពនៃមូលនិធិសោធននៅរយៈពេលវែង ជាពិសេស របបសោធនបច្ចុប្បន្ន ដែលត្រូវបានធ្វើហិរញ្ញប្បទានពីថវិការដ្ឋទាំងស្រុង តាមយន្តការទូទាត់តាមដំណើរ (Pay-As-You-Go)។

### ៣.១.២.៣ ក្របខ័ណ្ឌច្បាប់ និងត្រួតពិនិត្យ

បច្ចុប្បន្ន លិខិតបទដ្ឋានគតិយុត្តិដែលមានស្រាប់ ផ្តល់ត្រឹមតែក្របខ័ណ្ឌសម្រាប់ដាក់ឲ្យដំណើរការរបបសោធនកាតព្វកិច្ចប៉ុណ្ណោះ។ រីឯ ក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រង និងត្រួតពិនិត្យដំណើរការរបបសោធន ទាំងសម្រាប់វិស័យសាធារណៈ និងឯកជន ឲ្យស្របទៅតាមគោលការណ៍បច្ចេកទេស និងចីរភាពហិរញ្ញវត្ថុ នៅមិនទាន់ត្រូវបានរៀបចំនៅឡើយ។

ទន្ទឹមនេះ ប្រព័ន្ធចាកចេញពីការងារដោយស្ម័គ្រចិត្តសម្រាប់មន្ត្រីរាជការមុនកាលកំណត់របស់បញ្ញត្តិច្បាប់ រួមជាមួយការផ្តល់អត្ថប្រយោជន៍នៃរបបសន្តិសុខសង្គម ឬការផ្តល់របបឧបត្ថម្ភ ដែលអាចជួយសម្រួលដល់ការចាកចេញរបស់មន្ត្រីរាជការពីក្របខ័ណ្ឌរដ្ឋដោយស្ម័គ្រចិត្ត ក៏នៅពុំទាន់មានការគិតគូរ និងរៀបចំឲ្យសមស្របតាមការវិវឌ្ឍរបស់សង្គម និងរដ្ឋបាលសាធារណៈ។

## ៣.១.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត

ចក្ខុវិស័យរយៈពេលវែងសម្រាប់ការអភិវឌ្ឍប្រព័ន្ធសោធននៅកម្ពុជា គឺការសម្រេចបាននូវប្រព័ន្ធសោធនដែលមានការគ្របដណ្តប់ជាសកល។ ប្រព័ន្ធនេះ មានគោលបំណងផ្តល់ជូនប្រជាជនកម្ពុជាគ្រប់រូបនូវយន្តការការពារផ្នែកហិរញ្ញវត្ថុសម្រាប់ពេលចាស់ជរា តាមរយៈការផ្តល់ប្រាក់ចំណូលសមរម្យចំពោះប្រជាជនដែលចូលរួមក្នុងរបបសោធនកាតព្វកិច្ច និងស្ម័គ្រចិត្ត និងការកាត់បន្ថយជាអតិបរមានូវការធ្លាក់ខ្លួនទៅក្នុងភាពក្រីក្រនៅពេលចាស់ជរា ចំពោះប្រជាជននៃវិស័យសេដ្ឋកិច្ចទាំងក្នុង និងក្រៅ

ប្រព័ន្ធ។ រាជរដ្ឋាភិបាលកំពុងដំណើរការកំណែទម្រង់ប្រព័ន្ធសោធនឲ្យមានលក្ខណៈប្រមូលផ្ដុំ ដោយឈរលើគោលការណ៍បីគឺ៖ ភាពដែលអាចទ្រទ្រង់បាន សក្តិសិទ្ធិភាព និងចីរភាព។

### ៣.១.៣.១ ក្របខ័ណ្ឌស្ថាប័ន

*ក. ការធ្វើឲ្យមានសង្គតិភាពរវាងរបបសោធនសាធារណៈ*

នៅដំណាក់កាលចំពោះមុខ រាជរដ្ឋាភិបាលនឹងរៀបចំគោលការណ៍ណែនាំដើម្បីកំណត់អំពីយន្តការក្នុងការគិតគូរប្រាក់សោធនសម្រាប់មន្ត្រីនៃវិស័យសាធារណៈឡើងវិញ ដើម្បីកាត់បន្ថយជាបណ្តើរៗនូវគម្លាតរវាងការទទួលបានប្រាក់សោធនរបស់មន្ត្រីសាធារណៈ។ យន្តការអចិន្ត្រៃយ៍ដើម្បីកំណត់អំពីការធ្វើឲ្យមានសង្គតិភាពរវាងតាវកាលិកនៃរបបសោធនសាធារណៈនេះ នឹងត្រូវចែងនៅក្នុងច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម ដែលច្បាប់នេះទាមទារឲ្យមានការសិក្សាល្អិតល្អន់ និងពេលវេលាច្រើនសម្រាប់ការរៀបចំ។

*ខ. ការធ្វើឯកភាពូបនីយកម្មរបបសោធនដែលមានស្រាប់*

ការគ្រប់គ្រង និងដាក់ដំណើរការរបបសោធនទាំងឡាយរបស់ស្ថាប័នផ្សេងគ្នាគឺជាឧបសគ្គដល់ការអភិវឌ្ឍវិជ្ជាជីវៈឯកទេស និងជាបញ្ហាប្រឈមចំពោះប្រសិទ្ធភាព និងសក្តិសិទ្ធិភាពនៃការផ្តល់សេវាក្នុងចំណាយទាប។ ដូច្នេះ ដើម្បីធ្វើឲ្យមានសង្គតិភាពរវាងតាវកាលិកនៃសមាជិកគោលដៅនីមួយៗ សំដៅបង្កើនប្រសិទ្ធភាពនៃចំណាយថវិកា និងដើម្បីប្រមូលផ្តុំសមត្ថភាពជំនាញឲ្យធ្វើការចំគោលដៅ និងមានប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលនឹងធ្វើសមាហរណកម្មរបបសោធនដែលមានស្រាប់ឲ្យស្ថិតនៅក្រោមប្រព័ន្ធគ្រប់គ្រងតែមួយ ព្រមទាំង ពង្រីកវិសាលភាពឲ្យគ្របដណ្តប់មន្ត្រីរាជការទាំងអស់ រួមទាំងមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ និងមន្ត្រីនៃស្ថាប័នសាធារណៈផ្សេងទៀត។

*គ. ការរៀបចំប្រព័ន្ធចាកចេញពីការងារដោយស្ម័គ្រចិត្តសម្រាប់មន្ត្រីរាជការ*

រាជរដ្ឋាភិបាលនឹងរៀបចំប្រព័ន្ធចាកចេញពីការងារ ដែលអនុញ្ញាតឲ្យមន្ត្រីរាជការអាចចាកចេញពីការងារដោយបញ្ញត្តិច្បាប់ ដើម្បីជាប្រយោជន៍ដល់មន្ត្រីដែលចង់ចាកចេញពីក្របខ័ណ្ឌរដ្ឋ ដោយហេតុបានបំពេញការងារយូរ លក្ខខណ្ឌអាយុច្រើន ស្ថានភាពគ្រួសារ សុខភាព ឬសមត្ថភាពមិនសមស្របនឹងការតម្រូវនៃមុខតំណែងការងារ។ ទន្ទឹមនេះ ប្រព័ន្ធចាកចេញពីការងារនឹងបង្កើតនូវកាលានុវត្តភាពការងារដល់យុវជនដែលមានសមត្ថភាពសមស្របសម្រាប់ការងារ។ ការរៀបចំប្រព័ន្ធចាកចេញពីការងារសម្រាប់មន្ត្រីរាជការ ទាមទារឲ្យមានការគិតគូរច្បាស់លាស់អំពីលក្ខខណ្ឌ អត្ថប្រយោជន៍ ឬការឧបត្ថម្ភផ្សេងៗសម្រាប់ជាការគាំទ្រ ដល់មន្ត្រីរាជការដែលជ្រើសរើសប្រព័ន្ធនេះ។

*ឃ. ការដាក់ឲ្យដំណើរការរបបសោធនសម្រាប់កម្មករនិយោជិត*

ក្រៅពីការកែទម្រង់របបសោធនសាធារណៈ រាជរដ្ឋាភិបាលនឹងសិក្សាអំពីលទ្ធភាពក្នុងការរៀបចំដាក់ឲ្យដំណើរការរបបសោធនសម្រាប់កម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ របបនេះនឹងត្រូវធ្វើសមាហរណកម្មឲ្យស្ថិតនៅក្រោមប្រព័ន្ធគ្រប់គ្រងរួម និងមានសង្គតិភាព

ជាមួយរបបសោធនសាធារណៈ។ រាជរដ្ឋាភិបាលនឹងធ្វើការប្រឹក្សាយោបល់ជាមួយតំណាងនិយោជក និងតំណាងនិយោជិត ដើម្បីកំណត់អត្រាភាគទាន និងតាវកាលិកឲ្យមានលក្ខណៈសមស្រប និងអាចទទួលយកបាន។

*ង. ការដាក់ឲ្យដំណើរការរបបសោធនសម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលមិនក្រីក្រ*

ដើម្បីសម្រេចនូវគោលបំណងខាងលើ ពោលគឺការផ្តល់នូវយន្តការការពារសម្រាប់ពេលចាស់ជរាជូនប្រជាជនគ្រប់រូប រាជរដ្ឋាភិបាលនឹងសិក្សាអំពីលទ្ធភាពក្នុងការដាក់ឲ្យដំណើរការរបបសោធនសម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលមិនចាត់ចូលក្នុងក្រុមប្រជាជនក្រីក្រនិងងាយរងគ្រោះ រួមមាន អាជីវករលក់ដូរ និងប្រជាជនដែលស្ថិតក្នុងស្វ័យកម្មភាព ជាដើម។ បទពិសោធន៍អន្តរជាតិជាទូទៅបង្ហាញថា ការដាក់ឲ្យដំណើរការរបបសោធនសម្រាប់ក្រុមគោលដៅនេះ មានបញ្ហាប្រឈមច្រើន ដោយសារផលវិបាកនៃការកំណត់អត្តសញ្ញាណ និងប្រភពចំណូលរបស់បុគ្គលទាំងនោះ ដែលនាំឲ្យពិបាកក្នុងការកំណត់មូលដ្ឋានសម្រាប់ការបង់ភាគទាន។

ការដាក់ឲ្យដំណើរការរបបសោធននេះត្រូវធ្វើឡើងដោយសន្សឹមៗ តាមរយៈការជំរុញឲ្យចូលរួមដោយស្ម័គ្រចិត្តជាមុន មុននឹងបង្វែរទៅជារបបកាតព្វកិច្ចនៅពេលក្រោយ ដោយផ្អែកលើបុរេលក្ខខណ្ឌមួយចំនួនដូចជា ការកំណត់អត្តសញ្ញាណ ការយល់ដឹងអំពីអត្ថប្រយោជន៍នៃរបបសោធន ព្រមទាំងភាពចាស់ទុំ និងសមត្ថភាពក្នុងការគ្រប់គ្រងរបបសោធនប្រកបដោយវិជ្ជាជីវៈ និងតម្លាភាពរបស់ស្ថាប័នប្រតិបត្តិករផងដែរ។ ការដាក់ឲ្យអនុវត្តប្រព័ន្ធបង់ភាគទានថេរ (Flat-rate) អាចជាជម្រើសមួយសម្រាប់របបសោធនប្រភេទនេះ។

*ច. ការដាក់ឲ្យដំណើរការរបបសោធនឯកជនស្ម័គ្រចិត្ត*

ដើម្បីផ្តល់ជម្រើសក្នុងការសន្សំរយៈពេលវែង ឲ្យសមស្របទៅតាមលទ្ធភាពរបស់ប្រជាជនដែលមានចំណូលមធ្យមនិងខ្ពស់ រាជរដ្ឋាភិបាលនឹងរៀបចំហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ជាពិសេស គឺក្របខ័ណ្ឌគតិយុត្តិដើម្បីអនុញ្ញាតឲ្យរបបសោធនឯកជនស្ម័គ្រចិត្ត ដែលគ្រប់គ្រងដោយគ្រឹះស្ថានហិរញ្ញវត្ថុអាចដំណើរការទៅបាន។ របបសោធនឯកជនស្ម័គ្រចិត្តគឺជាសសរស្តម្ភទី៣នៃប្រព័ន្ធសោធនទូទៅដែលត្រូវបានអភិវឌ្ឍដោយធនាគារពិភពលោក ដែលមានមុខងារបំពេញបន្ថែមទៅលើសោធនកាតព្វកិច្ច ដែលផ្តល់ត្រឹមតែយន្តការសន្សំកម្រិតមូលដ្ឋានប៉ុណ្ណោះ។

*ឆ. ការសម្រួលសមាជិកភាព*

គម្រោងសោធនទាំងអស់ នឹងធានារយៈពេលយោងនៃអតីតភាពដែលបានបង់ភាគទាន និងសង្គតិភាពតាវកាលិក នៅពេលដែលមានការប្តូរសមាជិកភាពពីក្រុមគោលដៅមួយទៅក្រុមគោលដៅមួយ។ ឧទាហរណ៍៖ ការផ្លាស់ប្តូរពីរបបសោធនសម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធចូលទៅក្នុងរបបសោធនមន្ត្រីសាធារណៈ ឬការចូលទៅក្នុងរបបសោធនកម្មករនិយោជិត ឬប្តូរទៅវិញទៅមក ។

### ៣.១.៣.២ ក្របខ័ណ្ឌហិរញ្ញវត្ថុ

បម្រែបម្រួលនៃកត្តាប្រជាសាស្ត្រ និងនិន្នាការនៃការកើនឡើងជាបន្តបន្ទាប់នៃប្រាក់បៀវត្សរបស់មន្ត្រីសាធារណៈ បានបង្ហាញឲ្យឃើញពីសក្តានុពលនៃការកើនឡើងយ៉ាងគំហុកនៃចំណាយថវិការដ្ឋដើម្បីទ្រទ្រង់របបសោធនសាធារណៈសម្រាប់រយៈពេលមធ្យម និងវែងខាងមុខ។ ដូច្នេះ ដើម្បីរក្សាបាននូវភាពទ្រទ្រង់បាននៃថវិការដ្ឋ រាជរដ្ឋាភិបាលនឹងធ្វើការកែទម្រង់យន្តការហិរញ្ញប្បទានសម្រាប់ទ្រទ្រង់របបសោធនសាធារណៈ ពីប្រព័ន្ធដែលពឹងផ្អែកលើថវិការដ្ឋតាមយន្តការទូទាត់តាមដំណើរទៅជាប្រព័ន្ធផ្អែកលើការបង់ភាគទានវិញ។ ប្រព័ន្ធនេះនឹងតម្រូវឲ្យមន្ត្រីរាជការចូលរួមបង់ភាគទានចូលទៅក្នុងមូលនិធិរួម។ ទោះយ៉ាងណា ការតម្រូវឲ្យបង់ភាគទានចូលរបបសោធននេះត្រូវធ្វើឡើងក្នុងរូបភាពដែលមិនប៉ះពាល់ដល់កម្រិតប្រាក់បៀវត្សបច្ចុប្បន្នរបស់មន្ត្រីសាធារណៈ។

មុននឹងដាក់ឲ្យអនុវត្តការប្រមូលភាគទានពីមន្ត្រីសាធារណៈ រាជរដ្ឋាភិបាលនឹងធ្វើការសិក្សាឲ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីកំណត់អំពីលក្ខខណ្ឌបច្ចេកទេសទាំងឡាយនៃប្រព័ន្ធសោធនផ្អែកលើការបង់ភាគទាន រួមទាំងអំពីលក្ខខណ្ឌនៃក្រុមមន្ត្រីសាធារណៈ ដែលត្រូវបង់ភាគទាន ឬត្រូវបានលើកលែង ដោយផ្អែកលើ អតីតភាពការងារ កម្រិតអាយុចូលនិវត្តន៍ និងកម្រិតនៃប្រាក់បៀវត្ស។ ការសិក្សាក៏ចាំបាច់ត្រូវពិនិត្យឡើងវិញផងដែរអំពីកម្រិតនៃអាយុចូលនិវត្តន៍ ដែលជាកត្តាដ៏សំខាន់មួយចំពោះផលិតភាពការងារ និងចីរភាពហិរញ្ញវត្ថុនៃប្រព័ន្ធសោធន។

អនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ស្តីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បានកំណត់តែអត្រាភាគទានរួមសម្រាប់របបសន្តិសុខសង្គមទាំងអស់រួមមាន៖ របបសោធន ការបាត់បង់សម្បទាវិជ្ជាជីវៈ គ្រោះថ្នាក់ការងារ មាតុភាព មរណភាព និងអ្នកនៅក្នុងបន្ទុក។ ដោយសារតែរបបសោធនសាធារណៈទាំងអស់នឹងត្រូវធ្វើសមាហរណកម្មឲ្យទៅជារបបរួមមួយ នោះការកំណត់អត្រាភាគទានសម្រាប់របបនីមួយៗនឹងត្រូវគិតគូរឡើងវិញ ក្នុងគោលបំណងរក្សាបានតុល្យភាពរវាងប្រាក់ចំណូលរបស់មន្ត្រីសាធារណៈ និងលទ្ធភាពទ្រទ្រង់របស់ថវិកាជាតិ ព្រមទាំង រៀបចំឲ្យមានសង្គតិភាពរវាងសមាជិកគោលដៅទាំងអស់។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងពិនិត្យឡើងវិញលើអត្រាភាគទានដែលបានចែងក្នុងអនុក្រឹត្យខាងលើ ។

បទពិសោធន៍របស់បណ្តាប្រទេសមួយចំនួន បានបង្ហាញឲ្យឃើញពីទំនោរក្នុងការផ្លាស់ប្តូរពីរបបសោធនប្រភេទកំណត់តាវកាលិកជាមុន (Defined Benefit[២]) ទៅជារបបសោធនប្រភេទកំណត់ភាគទានជាមុន (Defined Contribution[៣]) ដើម្បីដោះខ្លួនចេញពីបន្ទុកហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរដែលប្រទេសជា

---

[២] របបសោធនប្រភេទកំណត់តាវកាលិកជាមុន គឺជាសោធនដែលកំណត់ជាមុននូវកម្រិតនៃតាវកាលិកសម្រាប់បើកផ្តល់ជូននិវត្តជន ដោយផ្អែកលើរយៈពេលនៃការបង់ភាគទាន និងកម្រិតនៃប្រាក់ចំណូល ។ "ដកស្រង់ចេញពីឯកសារគោលនយោបាយស្តីពីប្រព័ន្ធសោធននៅកម្ពុជារបស់អង្គការ ILO ឆ្នាំ ២០១៦" ។

[៣] របបសោធនប្រភេទកំណត់ភាគទានជាមុន គឺជារបបសោធនដែលមានលក្ខណៈជាការសន្សំ ដែលតាវកាលិកសម្រាប់បើកផ្តល់ជូននិវត្តជនគឺផ្អែកលើទឹកប្រាក់សន្សំបង្គរ បូករួមនឹងលទ្ធផលនៃការវិនិយោគ ។ "ដកស្រង់ចេញពីឯកសារគោលនយោបាយស្តីពីប្រព័ន្ធសោធននៅកម្ពុជារបស់អង្គការ ILO ឆ្នាំ ២០១៦" ។

ច្រើនកំពុងជួបប្រទះ។ បម្រែបម្រួលនៃកត្តាប្រជាសាស្ត្រ គឺជាហេតុផលចម្បងដែលនាំឲ្យមាននិន្នាការផ្លាស់ប្តូរនេះ។ ការធានាជាមុននូវតាវកាលិករបស់គម្រោងសោធនប្រភេទកំណត់តាវកាលិកជាមុនបង្ហាញអំពីហានិភ័យដែលអាចនឹងមានផលប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុនៃមូលនិធិសោធន និងចុងក្រោយធ្លាក់ជាបន្ទុកដ៏ធ្ងន់ធ្ងរមកលើថវិកាជាតិ។ ដូច្នេះ ដើម្បីជៀសវាងនូវបញ្ហាទាំងនេះ រាជរដ្ឋាភិបាលនឹងធ្វើការសិក្សាឲ្យបានល្អិតល្អន់អំពីប្រភេទនៃរបបសោធន ដែលសក្តិសមទៅនឹងស្ថានភាពជាក់ស្តែងរបស់កម្ពុជា។ លទ្ធផលនៃការសិក្សានេះ គឺជាទុនដ៏សំខាន់ក្នុងការជ្រើសរើសយកប្រភេទនៃរបបសោធនណាមួយ ដែលសមស្របទៅតាមបរិបទកម្ពុជា ។

#### ៣.១.៣.៣ ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ

ដើម្បីធានាឲ្យបាននូវការគ្រប់គ្រង និងចាត់ចែងរបបសោធនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព រាជរដ្ឋាភិបាលនឹងរៀបចំលិខិតបទដ្ឋានគតិយុត្តិសម្រាប់គ្រប់គ្រង និងត្រួតពិនិត្យ និងដាក់ឲ្យដំណើរការរបបសោធនសាធារណៈទាំងអស់ ដែលជាផ្នែកមួយនៃច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គមដែលនឹងត្រូវរៀបចំនៅពេលខាងមុខ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលក៏នឹងរៀបចំលិខិតបទដ្ឋានគតិយុត្តិសម្រាប់គ្រប់គ្រង និងដាក់ឲ្យដំណើរការប្រព័ន្ធសោធនឯកជនស្ម័គ្រចិត្ត នៅក្នុងក្របខ័ណ្ឌដោយឡែកពីច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម។

ក្របខ័ណ្ឌគតិយុត្តិទាំងនេះ នឹងកំណត់យ៉ាងច្បាស់លាស់អំពីគោលការណ៍គ្រឹះនៃការគ្រប់គ្រង និងចាត់ចែងមូលនិធិសោធន ក្នុងគោលបំណង (១) ផ្តល់ការការពារចំពោះសមាជិកនៃរបបសោធន និង (២) លើកកម្ពស់អភិបាលកិច្ចនៃរបបសោធន។ មូលនិធិសោធន គឺជាមូលនិធិបរធនបាលកិច្ច មួយប្រភេទដែលមិនអាចយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងក្រៅពីការយកទៅធ្វើការវិនិយោគ ដើម្បីបម្រើឲ្យផលប្រយោជន៍របស់សមាជិកនៃមូលនិធិសោធនបានឡើយ ទោះស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ។ ដើម្បីធានាបាននូវគោលការណ៍នេះ ក្របខ័ណ្ឌគតិយុត្តិត្រូវកំណត់ផងដែរអំពីមុខងាររបស់តួអង្គនីមួយៗនៃប្រតិបត្តិការសោធនរួមមាន៖ បរធនបាលទាយក ស្ថាប័នគ្រប់គ្រងការវិនិយោគ ស្ថាប័នគ្រប់គ្រងបញ្ជិកា និងធនាគារគ្រប់គ្រងទ្រព្យសកម្ម ជាដើម។

## ៣.២ ការថែទាំសុខភាព

### ៣.២.១ ទិដ្ឋភាពទូទៅ

យន្តការគាំពារសុខភាពបច្ចុប្បន្នមានតួនាទីយ៉ាងសំខាន់ ក្នុងការរួមចំណែកជាសក្តានុពលក្នុងដំណើរការឈានទៅសម្រេចបានការគ្របដណ្តប់សុខភាពជាសកល។ បច្ចុប្បន្ន កម្ពុជាមានយន្តការគាំពារសុខភាព ចំនួនបី ដែលបាននិងកំពុងដំណើរការសម្រាប់ក្រុមប្រជាជនគោលដៅរៀងៗខ្លួន។

#### ៣.២.១.១ ការថែទាំសុខភាពសម្រាប់ជនក្រីក្រ និងសម្រាប់កុមារ

បច្ចុប្បន្ន ប្រជាជនប្រមាណជាង ២ លាននាក់ ដែលស្ថិតក្នុងចំណាត់ថ្នាក់ជាប្រជាជនក្រីក្រ បាននិងកំពុងទទួលបានការបង្ការហានិភ័យហិរញ្ញវត្ថុ សម្រាប់ការថែទាំសុខភាពនៅបណ្តាមូលដ្ឋាន

សុខាភិបាលសាធារណៈទូទាំងប្រទេសតាមរយៈកម្មវិធីមូលនិធិសមធម៌សុខភាព។ មូលនិធិនេះ បង់ថ្លៃចំណាយនៃការប្រើប្រាស់សេវាថែទាំសុខភាពជំនួសប្រជាជនក្រីក្រ រួមមាន៖ សេវាពិគ្រោះពិនិត្យជំងឺក្រៅ (រាប់ទាំងការសម្រាលកូន) និងការសម្រាកព្យាបាលនិងថែទាំ (រាប់បញ្ចូលទាំងសេវាវះកាត់)។ ក្រៅពីនេះ មូលនិធិសមធម៌ក៏ផ្ដល់ជូនផងដែរនូវសោហ៊ុយបញ្ជូនអ្នកជម្ងឺទៅកាន់មន្ទីរពេទ្យបង្អែក ប្រាក់ឧបត្ថម្ភសម្រាប់អាហារ អ្នកថែរក្សាម្នាក់ក្នុងករណីអ្នកជំងឺត្រូវសម្រាកព្យាបាល និងឧបត្ថម្ភបុណ្យសពអ្នកជំងឺ។ មូលនិធិសមធម៌ គឺជាយន្តការ "ប្រមូលផ្ដុំហានិភ័យហិរញ្ញវត្ថុ" ទ្រង់ទ្រាយធំដែលបង្ហាញពីប្រសិទ្ធភាពនៃការវិនិយោគធនធានហិរញ្ញវត្ថុរបស់រដ្ឋ ដើម្បីលើកកម្ពស់សុខភាពប្រជាជនក្រីក្រ ជួយកាត់បន្ថយចំណាយប្រាក់ហោប៉ៅលើការថែទាំសុខភាព និងបង្ការហានិភ័យនៃចំណាយលើការថែទាំនិងព្យាបាលសុខភាព ព្រមទាំង ចូលរួមការពារការធ្លាក់ចូលទៅក្នុងភាពក្រីក្រដោយសារតម្រូវការសេវាសុខាភិបាល។ ហិរញ្ញប្បទានសម្រាប់ទ្រទ្រង់មូលនិធិនេះ គឺជាថវិកាបដិភាគរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ ផ្អែកតាមយុទ្ធសាស្ត្រហិរញ្ញប្បទានសុខាភិបាល រាជរដ្ឋាភិបាលនឹងទទួលបន្ទុកទាំងស្រុងលើហិរញ្ញប្បទានទ្រទ្រង់មូលនិធិសមធម៌សុខភាពនេះ នាពេលអនាគតខាងមុខ។

ក្រៅពីនេះ រាជរដ្ឋាភិបាលបានខិតខំលើកកម្ពស់ការគាំពារសុខភាពកុមារ តាមរយៈការចូលរួមផ្ដល់ហិរញ្ញប្បទានឧបត្ថម្ភមូលនិធិមន្ទីរពេទ្យគន្ធបុប្ផាជារៀងរាល់ឆ្នាំ ដែលផ្ដល់សេវាពិគ្រោះ ពិនិត្យជម្ងឺនិងសម្រាកព្យាបាលដោយឥតបង់ថ្លៃសម្រាប់កុមារទូទៅទូទាំងប្រទេស។ នៅឆ្នាំ២០១៥ រាជរដ្ឋាភិបាលបានបង្កើនការឧបត្ថម្ភធនដល់មូលនិធិគន្ធបុប្ផាប្រមាណ ១០ លានដុល្លារអាមេរិក។

### ៣.២.១.២ ការធានារ៉ាប់រងសុខភាពតាមសហគមន៍

អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបាន និងកំពុងប្រតិបត្តិគម្រោងធានារ៉ាប់រងសុខភាពនៅតាមសហគមន៍ចំនួន ៨ នៅក្នុងខេត្តចំនួន ៧ និងរាជធានីភ្នំពេញ សម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត។ គិតត្រឹមដំណាច់ឆ្នាំ២០១៥ ប្រជាជនចំនួន ១៤៨ ៤១៨ នាក់បានចូលរួមក្នុងគម្រោងទាំងនេះ។ ហិរញ្ញប្បទានសម្រាប់ទ្រទ្រង់គម្រោងទាំងនេះ បានមកពីការបង់ភាគទានពីសមាជិក និងការឧបត្ថម្ភធនពីដៃគូអភិវឌ្ឍន៍។ ប្រតិបត្តិការនៃគម្រោងទាំងនេះអាចចាត់ទុកថាជាយន្តការចាប់ផ្ដើមសម្រាប់ការអភិវឌ្ឍប្រព័ន្ធធានារ៉ាប់រងសុខភាពសង្គម សម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅពេលខាងមុខ។ បច្ចុប្បន្ន គម្រោងមួយចំនួនបានប្រែក្លាយទៅជាគ្រឹះស្ថានធានារ៉ាប់រងខ្នាតតូច។

### ៣.២.១.៣ ការធានារ៉ាប់រងសុខភាពក្នុងវិស័យឯកជន

វិស័យធានារ៉ាប់រងសុខភាពឯកជន កំពុងស្ថិតក្នុងដំណាក់កាលនៃការអភិវឌ្ឍដំបូងនៅឡើយ ប៉ុន្តែមានសក្ដានុពលរីកចម្រើនឆាប់រហ័ស។ បច្ចុប្បន្ន ផលិតផលធានារ៉ាប់រងសុខភាពរបស់ក្រុមហ៊ុនធានារ៉ាប់រងឯកជននៅមានវិសាលភាពតូចនៅឡើយ។ គិតត្រឹមឆ្នាំ២០១៥ មានក្រុមហ៊ុនធានារ៉ាប់រងចំនួន ៨ ប៉ុណ្ណោះដែលផ្ដល់ផលិតផលធានារ៉ាប់រងសុខភាព ហើយបុព្វលាភដែលប្រមូលបានមានចំនួន ៩.២ លានដុល្លារអាមេរិក ដែលស្មើនឹង ១០.៨ ភាគរយនៃទីផ្សារធានារ៉ាប់រងសរុប។

### ៣.២.២ បញ្ហាប្រឈម

#### ៣.២.២.១ ក្របខ័ណ្ឌស្ថាប័ន

*ក. ភាពរាយប៉ាយនៃរបបថែទាំសុខភាព*

ដូចបានបញ្ជាក់ខាងដើម **ប.ជ.ស ប.ជ.អ** និង **ប.ស.ស** មានមុខងារប្រហាក់ប្រហែលគ្នា គឺការគ្រប់គ្រងរបបសន្តិសុខសង្គមច្រើនប្រភេទសម្រាប់សមាជិកគោលដៅរៀងៗខ្លួន។ ក្នុងក្របខ័ណ្ឌនេះ របបថែទាំសុខភាពសម្រាប់សមាជិកគោលដៅនីមួយៗ ស្ថិតក្រោមការគ្រប់គ្រងដោយឡែកពីគ្នា និងមានបទប្បញ្ញត្តិនិងនីតិវិធីផ្សេងៗគ្នាផងដែរ។ មូលនិធិសមធម៌ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសុខាភិបាល ដោយមានការចូលរួមពីដៃគូអភិវឌ្ឍន៍ និងមានអង្គការក្រៅរដ្ឋាភិបាលដែលជាប្រតិបត្តិករ ខណៈដែលការធានារ៉ាប់រងសុខភាពតាមសហគមន៍ ត្រូវបានប្រតិបត្តិដោយអង្គការក្រៅរដ្ឋាភិបាល។ ភាពរាយប៉ាយនៃការគ្រប់គ្រង បង្កើតឲ្យមានចំណាយប្រតិបត្តិការខ្ពស់ អសង្គតិភាពកញ្ចប់តាវកាលិក ព្រមទាំងមានភាពខុសគ្នាលើការកំណត់លក្ខណៈវិនិច្ឆ័យសមាជិក និងអាទិភាពនៃរបបថែទាំសុខភាពនីមួយៗផងដែរ។

*ខ. ប្រព័ន្ធថែទាំបឋម និងគុណភាពនៃសេវាសុខាភិបាល*

គុណភាពទូទៅនៃសេវាសុខភាពសាធារណៈត្រូវបានកែលម្អ ដោយសារលទ្ធផលនៃការកែទម្រង់រចនាសម្ព័ន្ធគុណភាព ព្រមគ្នានឹងការពង្រឹងសមត្ថភាពធ្វើរោគវិនិច្ឆ័យនិងការលើកកម្ពស់បែបបទនៃការពិនិត្យព្យាបាល/ថែទាំទៅតាមពិធីសារ ឬមគ្គុទ្ទេសក៍ប្រតិបត្តិគ្លីនិក។ ទោះដូច្នេះក្តី កម្រិតគុណភាពសេវា ជាពិសេសសេវាសម្រាកព្យាបាល និងថែទាំ នៅមិនទាន់ឆ្លើយតបនឹងសេចក្តីរំពឹងទុករបស់អ្នកជំងឺ ឬអតិថិជននៅឡើយទេ ។ ដូច្នេះ ការបន្តពង្រឹងគុណភាពនៃការបណ្តុះបណ្តាលបង្កើនសមត្ថភាពគ្លីនិក ការពង្រឹងយន្តការនិយតកម្ម ការត្រួតពិនិត្យនិងតាមដានគុណភាពជាប្រចាំ និងការពង្រាយបុគ្គលិកជំនាញស្របតាមនិយាមបច្ចេកទេស គឺជាសក្តានុពលភាពនៃការលើកកម្ពស់គុណភាពនៃការផ្តល់សេវាថែទាំសុខភាព។ ការណ៍នេះ នឹងផ្តល់នូវលក្ខខណ្ឌអំណោយផលសម្រាប់ការអនុវត្ត និងការពង្រីកវិសាលភាពនៃរបបថែទាំសុខភាពសង្គម សម្រាប់មន្ត្រីរាជការ កម្មករនិយោជិត ព្រមទាំង ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធផងដែរ។

#### ៣.២.២.២ ក្របខ័ណ្ឌហិរញ្ញវត្ថុ

*ក. សមធម៌ក្នុងការប្រើប្រាស់សេវាថែទាំសុខភាព*

បច្ចុប្បន្ន មូលនិធិសមធម៌បានផ្តល់ការគាំពារផ្នែកសុខភាព ចំពោះប្រជាជនក្រីក្រប្រមាណជិត ២០ ភាគរយនៃប្រជាជនសរុប។ រីឯ មន្ទីរពេទ្យគន្ធបុប្ផាបានផ្តល់សេវាថែទាំនិងព្យាបាលជូនកុមារ និងទារក។ ដូច្នេះក្រៅពីប្រជាជនដែលទទួលអត្ថប្រយោជន៍ពីមូលនិធិសមធម៌ និងរបបធានារ៉ាប់រងសុខភាពសហគមន៍ ព្រមទាំងកុមារដែលទទួលបានសេវាពីមូលនិធិគន្ធបុប្ផា ប្រជាជនកម្ពុជាភាគច្រើននៅមិនទាន់ទទួលបានការគាំពារផ្នែកហិរញ្ញវត្ថុសម្រាប់ការថែទាំសុខភាពនៅឡើយ។

*ខ. ការថែទាំសុខភាពដោយប្រើប្រាស់ប្រាក់ចេញពីហោប៉ៅ (Out-of-pocket payment)*

និន្នាការនៃកំណើនចំណាយថវិកាជាតិលើការថែទាំសុខភាព រួមជាមួយសមត្ថភាពចំណាយរបស់គ្រួសារកើនឡើង បានឆ្លុះបញ្ចាំងពីកំណើននៃចំណាយសរុបលើសុខភាព ដោយរាប់បញ្ចូលទាំងចំណាយនៅក្នុងផ្នែកសុខាភិបាលឯកជន។ ទោះយ៉ាងនោះក្តី ចំណាយប្រាក់ហោប៉ៅរបស់គ្រួសារលើសុខភាពនៅតែជាប្រភពហិរញ្ញប្បទានចម្បងសម្រាប់ប្រព័ន្ធសុខាភិបាល។ នៅឆ្នាំ២០១៥ ចំណាយប្រាក់ហោប៉ៅរបស់ប្រជាជនផ្ទាល់លើការថែទាំសុខភាពមានដល់ទៅ ៦០ ភាគរយនៃចំណាយសរុបលើសេវាថែទាំសុខភាព ដោយសារការគ្របដណ្តប់នៃការធានារ៉ាប់រងសុខភាពសង្គមមានកម្រិតទាប។

ទំហំចំណាយប្រាក់ហោប៉ៅផ្ទាល់ច្រើនហួសសមត្ថភាពចំណាយរបស់ប្រជាជន នាំមកនូវបញ្ហាប្រឈមជាច្រើនរួមមាន៖ ការពន្យារពេលស្វែងរកការថែទាំសុខភាព ឬការផ្អាកការប្រើប្រាស់សេវាថែទាំសុខភាព ជាពិសេស ធ្វើឲ្យប៉ះពាល់ដល់ផលិតភាពសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ព្រមទាំងបង្ហាញអំពីកង្វះយន្តការសមស្របសម្រាប់ហិរញ្ញប្បទានការថែទាំសុខភាពប្រកបដោយប្រសិទ្ធភាព។

#### ៣.២.២.៣ ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ

រហូតមកទល់ពេលនេះ មានតែអនុក្រឹត្យស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារប៉ុណ្ណោះ ដែលចែងច្បាស់អំពីការដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់កម្មករនិយោជិត។ រីឯ របបថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈនិងក្រុមប្រជាជនផ្សេងៗទៀត មិនទាន់បានកំណត់ច្បាស់លាស់នៅក្នុងក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិណាមួយនៅឡើយទេ។

### ៣.២.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត

អនុលោមតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Sustainable Development Goals) របស់អង្គការសហប្រជាជាតិ កម្ពុជាមានចក្ខុវិស័យក្នុងការបោះជំហានទៅរកប្រព័ន្ធថែទាំសុខភាពសកលដូចបណ្តាប្រទេសនានាលើសកលលោក។ គោលបំណងនៃចក្ខុវិស័យនេះ គឺដើម្បីរក្សាបាននូវសាមគ្គីភាពសង្គម តាមរយៈការផ្តល់ជូនប្រជាជនកម្ពុជាគ្រប់រូបនូវសេវាសុខាភិបាលប្រកបដោយគុណភាព និងអាចទ្រទ្រង់បាន។ រាជរដ្ឋាភិបាលប្រកាន់ខ្ជាប់គោលការណ៍បួន សម្រាប់ការរៀបចំគោលនយោបាយអភិវឌ្ឍន៍ និងកំណែទម្រង់ប្រព័ន្ធថែទាំសុខភាពសង្គមនេះគឺ (១) អភិបាលកិច្ចល្អ (២) ប្រសិទ្ធភាពខ្ពស់នៃចំណាយ (៣) គណនេយ្យភាព និង (៤) ចីរភាពហិរញ្ញវត្ថុ។

#### ៣.២.៣.១ ក្របខ័ណ្ឌស្ថាប័ន

*ក. ការដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់កម្មករនិយោជិត*

រាជរដ្ឋាភិបាលបានសម្រេចដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់កម្មករនិយោជិត តាមរយៈការចេញអនុក្រឹត្យលេខ ០១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ បន្ថែមលើ

របបសន្តិសុខសង្គមផ្នែកហានិភ័យការងារដែលមានស្រាប់។ របបនេះ នឹងផ្តល់ជូនកម្មករនិយោជិតនូវសេវាថែទាំសុខភាពទូទៅ រួមមាន ការថែទាំ និងព្យាបាលជំងឺ ប្រាក់លំហែមាតុភាព ព្រមទាំងផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការឈប់សម្រាកព្យាបាលជំងឺផងដែរ។

*ខ. ការដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ*

រាជរដ្ឋាភិបាលនឹងរៀបចំដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ ដែលមានសង្គតិភាពទៅនឹងរបបថែទាំសុខភាពសម្រាប់កម្មករនិយោជិត។ ការដាក់ឲ្យដំណើរការរបបនេះត្រូវមានការត្រៀមលក្ខណៈគ្រប់គ្រាន់លើទិដ្ឋភាពចាំបាច់ទាំងឡាយ មានជាអាទិ៍ ទិដ្ឋភាពបច្ចេកទេសនៃការកំណត់និងប្រមូលភាគទាន ការផ្តល់សេវា ការទូទាត់ និងក្របខ័ណ្ឌច្បាប់។ ប្រព័ន្ធថែទាំសុខភាពត្រូវដំណើរការតាមយន្តការ "អ្នកទូទាត់តែមួយ (Single Payer)" ដើម្បីបង្កើនប្រសិទ្ធភាព កាត់បន្ថយចំណាយរដ្ឋបាល និងធានាសមធម៌ក្នុងប្រព័ន្ធ។ ក្នុងបរិការណ៍នេះ ប.ស.ស ដែលជាស្ថាប័នមានជំនាញនិងមានបទពិសោធន៍ គឺជាស្ថាប័នមានសក្តានុពលក្នុងការពង្រីកវិសាលភាពការងារដើម្បីគ្រប់គ្រង និងចាត់ចែងរបបថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ ដោយផ្អែកលើមូលដ្ឋាននៃការពង្រឹងសមត្ថភាពបន្តបន្ទាប់ទៀត ដើម្បីអាចទទួលភារកិច្ចបន្ថែមប្រកបដោយប្រសិទ្ធភាព។

របបនេះ នឹងគ្របដណ្តប់ទាំងមន្ត្រីសាធារណៈ និវត្តជននិងអតីតយុទ្ធជន ព្រមទាំង អ្នកនៅក្នុងបន្ទុកផងដែរ ដែលដំណាក់កាលនៃការពង្រីកវិសាលភាពឲ្យគ្របដណ្តប់ក្រុមគោលដៅនីមួយៗ នឹងត្រូវធ្វើឡើងដោយផ្អែកលើទិដ្ឋភាពពីរសំខាន់គឺ ភាពទ្រទ្រង់បាននៃថវិកាជាតិ និងសមត្ថភាពក្នុងការទ្រទ្រង់បាននៃសេវាសុខាភិបាលរបស់មូលដ្ឋានសុខាភិបាល។

*គ. ការបង្កើនគុណភាពសុខាភិបាល*

រាជរដ្ឋាភិបាលនឹងបន្តការយកចិត្តទុកដាក់បន្ថែមទៀត លើការលើកកម្ពស់គុណភាពនៃសេវាសុខាភិបាលរបស់មូលដ្ឋានសុខាភិបាលរបស់រដ្ឋ និងឯកជន ដែលអាចដើរទន្ទឹមគ្នាជាមួយនឹងបណ្តាប្រទេសជិតខាង។ គោលដៅនេះ រាជរដ្ឋាភិបាលនឹងដាក់ឲ្យដំណើរការប្រព័ន្ធទទួលស្គាល់គុណភាព (Accreditation System) ដែលជាយន្តការដើម្បីធានាគុណភាពរបស់មូលដ្ឋានសុខាភិបាល ទាំងរបស់រដ្ឋ និងឯកជន។ ការបង្កើនគុណភាពសុខាភិបាល មានសារៈសំខាន់ណាស់ក្នុងការកសាងជំនឿទុកចិត្តសាធារណជនមកលើប្រព័ន្ធថែទាំសុខភាពទាំងមូល។ កត្តានេះ នឹងជំរុញឲ្យមានការចូលរួមកាន់តែច្រើនរបស់ប្រជាជន ជាពិសេស ផ្តល់នូវផលវិជ្ជមាននៅពេលដែលរាជរដ្ឋាភិបាលដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

*ឃ. ការលើកកម្ពស់ការយល់ដឹងអំពីការថែទាំ និងការការពារសុខភាព*

ស្ថាប័នប្រតិបត្តិករដែលទទួលបន្ទុកគ្រប់គ្រង និងចាត់ចែងរបបថែទាំសុខភាពសង្គមមានភារកិច្ចរៀបចំកម្មវិធីផ្សព្វផ្សាយ និងបណ្តុះបណ្តាលប្រជាជនទូទៅ អំពីការថែទាំ និងការការពារសុខភាពតាម

គ្រប់មធ្យោបាយ។ មុខងារនេះ ត្រូវអនុវត្តក្នុងរូបភាពបំពេញគ្នាទៅវិញទៅមកជាមួយកម្មវិធីជាតិរបស់ក្រសួងសុខាភិបាល។

*ង. យន្តការត្រួតពិនិត្យការទូទាត់សេវាសុខាភិបាល*

ដើម្បីចៀសវាងនូវទំនាស់ផលប្រយោជន៍ និងការគៃបន្លំនានាដែលអាចកើតមានឡើងនៅក្នុងប្រតិបត្តិការទូទាត់ថ្លៃសេវាសុខាភិបាលរវាងប្រតិបត្តិករ និងមូលដ្ឋានសុខាភិបាល រាជរដ្ឋាភិបាលនឹងសិក្សាអំពីលទ្ធភាពក្នុងការបង្កើតស្ថាប័នស្វយ័តមួយ ដើម្បីផ្ទៀងផ្ទាត់ និងត្រួតពិនិត្យលើរាល់សំណើសុំទូទាត់ថ្លៃសេវា (Claim Review) របស់មូលដ្ឋានសុខាភិបាល។ ភាពចាំបាច់នៃវត្តមានរបស់ស្ថាប័ននេះ គឺការកសាងជំនឿទុកចិត្តសាធារណៈ តាមរយៈការគ្រប់គ្រង និងចាត់ចែងមូលនិធិថែទាំសុខភាពប្រកបដោយតម្លាភាព និងគណនេយ្យភាព។

*ច. ការសិក្សាសមិទ្ធិលទ្ធភាពលើការធានារ៉ាប់រងបន្ត*

ដើម្បីកាត់បន្ថយហានិភ័យ ដែលអាចមានផលប៉ះពាល់ដល់ស្ថិរភាព និងចីរភាពនៃមូលនិធិថែទាំសុខភាពសង្គម រាជរដ្ឋាភិបាលនឹងសិក្សាលើជម្រើសក្នុងការដាក់ឲ្យមានការធានារ៉ាប់រងបន្តលើប្រតិបត្តិការថែទាំសុខភាពសង្គមនេះ ក្នុងកម្រិតសមស្របណាមួយទៅឲ្យគ្រឹះស្ថានធានារ៉ាប់រងឯកជន។ រាជរដ្ឋាភិបាលនឹងសហការជាមួយគ្រឹះស្ថានធានារ៉ាប់រងឯកជន ដើម្បីពិនិត្យលទ្ធភាពក្នុងការដាក់ឲ្យដំណើរការប្រតិបត្តិការនេះ ដោយឈរលើគោលការណ៍ទីផ្សារ។

*ឆ. ការគ្រប់គ្រងមូលនិធិសមធម៌ និងមូលនិធិគន្ធបុប្ផា*

ផ្អែកតាមយុទ្ធសាស្ត្រហិរញ្ញប្បទានសុខាភិបាល រាជរដ្ឋាភិបាលនឹងទទួលរ៉ាប់រងទាំងស្រុងលើហិរញ្ញប្បទានទ្រទ្រង់មូលនិធិសមធម៌នាពេលអនាគត។ ដូច្នេះ រាជរដ្ឋាភិបាលនឹងដាក់ឲ្យការគ្រប់គ្រងមូលនិធិនេះស្ថិតនៅក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ប្រតិបត្តិករសន្តិសុខសង្គមរួម។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងសិក្សាអំពីលទ្ធភាពក្នុងការដាក់បញ្ចូលក្រុមប្រជាជន ដែលងាយរងគ្រោះមួយចំនួនទៀតដូចជា ជនពិការ ជនចាស់ជរា និងកុមារអាយុក្រោមប្រាំឆ្នាំឲ្យចូលជាសមាជិករបស់មូលនិធិសមធម៌ជាបន្តបន្ទាប់ទៅតាមលទ្ធភាពនៃការទ្រទ្រង់បាននៃថវិកាជាតិ។

រាជរដ្ឋាភិបាលក៏នឹងសិក្សាអំពីទិដ្ឋភាពហិរញ្ញប្បទាន និងការគ្រប់គ្រងមូលនិធិគន្ធបុប្ផា ដើម្បីត្រៀមខ្លួនក្នុងការផ្តល់ហិរញ្ញប្បទានមូលនិធិនេះទាំងស្រុងនៅពេលវេលាសមស្របណាមួយ។ នៅពេលនោះ ការគ្រប់គ្រងមូលនិធិនេះក៏នឹងត្រូវផ្ទេរឲ្យមកនៅក្រោមការគ្រប់គ្រងរបស់អ្នកទូទាត់តែមួយផងដែរ។

*ជ. ការបង្កើនការចូលរួមពីមូលដ្ឋានសុខាភិបាលឯកជន*

ដើម្បីពង្រីកការគ្របដណ្តប់ និងបង្កើនគុណភាពសេវាថែទាំសុខភាព ព្រមទាំង បង្កភាពងាយស្រួលក្នុងការទទួលបានសេវាថែទាំសុខភាពពីរបបថែទាំសុខភាពសង្គម រាជរដ្ឋាភិបាលនឹងជំរុញឲ្យមានការចូលរួមកាន់តែច្រើនពីសំណាក់មូលដ្ឋានសុខាភិបាលឯកជន ដើម្បីផ្តល់ជម្រើសបន្ថែមដល់ប្រជាជនក្នុងការចូលរួមនៅក្នុងប្រព័ន្ធថែទាំសុខភាពសង្គម។ រាជរដ្ឋាភិបាលនឹងរៀបចំឲ្យមានកញ្ចប់

តាវកាលិករួម (Uniform Benefit Package) មួយដែលមានលក្ខណៈសមស្រប និងអាចទទួលយកបានពីសំណាក់មូលដ្ឋានសុខាភិបាលឯកជន។

*ឈ. ការដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលមិនក្រីក្រ*

ដើម្បីឈានទៅសម្រេចគោលដៅនៃការគ្របដណ្តប់សុខភាពជាសកល រាជរដ្ឋាភិបាលនឹងធ្វើការសិក្សាអំពីលទ្ធភាពក្នុងការដាក់ឲ្យដំណើរការរបបថែទាំសុខភាពសង្គម សម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធតាមរយៈគោលការណ៍ចូលរួមដោយស្ម័គ្រចិត្តនៅក្នុងដំណាក់កាលដំបូង បន្ទាប់មកពិនិត្យលទ្ធភាពក្នុងការបង្វែរទៅជារបបកាតព្វកិច្ច យោងទៅតាមស្ថានភាពជាក់ស្តែង។

**រូបភាពទី១៤៖ រចនាសម្ព័ន្ធគ្រប់គ្រងប្រព័ន្ធថែទាំសុខភាព**




### ៣.២.៣.២ ក្របខ័ណ្ឌហិរញ្ញវត្ថុ

*ក. គោលការណ៍នៃការធ្វើហិរញ្ញប្បទានទ្រទ្រង់ប្រព័ន្ធថែទាំសុខភាព*

រាជរដ្ឋាភិបាលនឹងបន្តផ្តល់ការទ្រទ្រង់ហិរញ្ញវត្ថុ ក្រោមរូបភាពជាចំណាយបង់ភាគទានជំនួសឲ្យប្រជាជនក្រីក្រនិងងាយរងគ្រោះ។ ចំណែក ក្រុមប្រជាជនផ្សេងទៀត ទាំងវិស័យសេដ្ឋកិច្ចក្នុង និងក្រៅប្រព័ន្ធ ត្រូវមានកាតព្វកិច្ចបង់ភាគទានតាមការកំណត់មួយជាក់លាក់។ រាជរដ្ឋាភិបាលនឹងបន្តផ្តល់

ហិរញ្ញប្បទានតាមការចាំបាច់ ចំពោះដំណើរការនៃមូលដ្ឋានសុខាភិបាលសាធារណៈដោយប្រើប្រាស់ថវិកាជាតិ ខណៈពង្រឹងជាបណ្ដើរៗនូវស្វ័យភាព ប្រសិទ្ធភាព គណនេយ្យភាព និងស្ថិរភាពហិរញ្ញវត្ថុនៃមូលដ្ឋានសុខាភិបាល។

*ខ. ការកំណត់អត្រាភាគទាន*

ការកំណត់អត្រាភាគទានសម្រាប់របបថែទាំសុខភាពទាំងអស់ ត្រូវមានការសិក្សាផ្អែកហានិភ័យឲ្យបានត្រឹមត្រូវ និងត្រូវឈរលើគោលការណ៍ពិគ្រោះយោបល់សាធារណៈ ដើម្បីទទួលបានការគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងអស់ ទាំងស្ថាប័នរាជរដ្ឋាភិបាល តំណាងនិយោជក តំណាងនិយោជិត និងតំណាងប្រជាជនទូទៅ។

*គ. ការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស*

តម្រូវការនៃការប្រើប្រាស់សេវាសុខាភិបាលនឹងកើនឡើងជាលំដាប់ បន្ទាប់ពីរាជរដ្ឋាភិបាលដាក់ឲ្យដំណើរការរបបថែទាំសុខភាពសង្គមសម្រាប់កម្មករនិយោជិត និងមន្ត្រីសាធារណៈ។ តម្រូវការនេះនឹងកាន់តែកើនឡើងថែមទៀតនៅពេលដែលប្រព័ន្ធថែទាំសុខភាពសង្គម ត្រូវបានពង្រីកវិសាលភាពទៅដល់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅពេលខាងមុខ។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនេះ រាជរដ្ឋាភិបាលនឹងបង្កើនការវិនិយោគសាធារណៈទាំងទៅលើហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្សក្នុងវិស័យសុខាភិបាលទៅតាមភាពទ្រទ្រង់បាននៃថវិកាជាតិ។

**៣.២.៣.៣ ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ**

ការអភិវឌ្ឍប្រព័ន្ធថែទាំសុខភាពសង្គម ទាមទារនូវក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិចាំបាច់សម្រាប់គ្រប់គ្រង និងកំណត់ស្តង់ដារប្រតិបត្តិការនៅក្នុងប្រព័ន្ធនោះ ជាពិសេស គឺការកំណត់តួនាទីរបស់ភាគីពាក់ព័ន្ធនឹងរបបថែទាំសុខភាពសង្គម កំណត់នីតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុ ប្រភពហិរញ្ញវត្ថុនិងអត្រាភាគទាន នីតិវិធីសម្រាប់កំណត់កញ្ចប់អត្ថប្រយោជន៍ និងកិច្ចការពារអតិថិជន ជាដើម។ ក្របខ័ណ្ឌច្បាប់ និងយន្តការអនុវត្ត ក៏ត្រូវគិតគូរផងដែរនូវភាពចាំបាច់នៃការបោះជំហានទៅរកការថែទាំសុខភាពសកល តាមរយៈការជំរុញការចូលរួមជាកាតព្វកិច្ចរបស់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលមិនមែនក្រីក្រ ព្រមទាំង ដើម្បីកំណត់យន្តការធានាគុណភាព ការធ្វើសមាហរណកម្មប្រតិបត្តិករសន្តិសុខសង្គម និងការកំណត់តួនាទីបញ្ញត្តិករសមស្រប សំដៅធានាប្រតិបត្តិការដោយរលូន និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ទន្ទឹមនោះ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ ប.ស.ស ក៏នឹងត្រូវកែសម្រួល ដើម្បីអនុញ្ញាតឲ្យ ប.ស.ស ដើរតួជាស្ថាប័នប្រតិបត្តិកររួមក្នុងការគ្រប់គ្រងនិងចាត់ចែងរបបថែទាំសុខភាពសម្រាប់សមាជិកគោលដៅផ្សេងទៀត ដោយសារបច្ចុប្បន្ន ប.ស.ស មានអាណត្តិគ្រប់គ្រងនិងចាត់ចែងតែរបបសន្តិសុខសង្គមសម្រាប់កម្មករនិយោជិតដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារប៉ុណ្ណោះ។

## ៣.៣ ហានិភ័យការងារ

### ៣.៣.១ ទិដ្ឋភាពទូទៅ

បច្ចុប្បន្ន មានតែកម្មករនិយោជិតដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារប៉ុណ្ណោះ ទទួលបានការគាំពារពេញលេញពីហានិភ័យការងារ។ របបហានិភ័យការងារសម្រាប់កម្មករនិយោជិត ផ្តល់ជូនកម្មករនិយោជិតនូវការការពារពីហានិភ័យការងារនិងជំងឺវិជ្ជាជីវៈ។ គិតត្រឹមដំណាច់ឆ្នាំ២០១៥ កម្មករនិយោជិតចំនួនប្រមាណ ១ ២០០ ០០០ នាក់បានចូលរួមក្នុងរបបនេះ ដែលនិយោជកត្រូវរ៉ាប់រង ទាំងស្រុងលើការបង់ភាគទានជូន ប.ស.ស ក្នុងអត្រា ០.៨ ភាគរយនៃប្រាក់ឈ្នួលមធ្យមជាប់ភាគទាន (ចន្លោះពី ២០០ ០០០ ទៅ ១ ០០០ ០០០ រៀល) របស់កម្មករនិយោជិត។ តាវកាលិកដែលកម្មករនិយោជិតត្រូវទទួលបានពី ប.ស.ស រួមមាន តាវកាលិកដឹកជញ្ជូន និងថៃទាំព្យាបាលរហូតដល់មុខរបួសជាសះស្បើយ ប្រាក់បំណាច់ប្រចាំថ្ងៃក្នុងឱកាសអាក់ខានធ្វើការងារ ប្រាក់បាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍អាចទទួលប្រាក់ជាវិភាជបើកផ្តាច់ ឬជាធនលាភ ៣ ខែម្តង រហូតដល់ទទួលមរណភាព ចំពោះការបាត់បង់សមត្ថភាពការងារលើសពី ២០ ភាគរយឡើង និងផ្តល់សេវាបុននីតិសម្បទា ផ្តល់សោហ៊ុយបូជាសព និងផ្តល់ប្រាក់ចិញ្ចឹមដល់ឧត្តរជីវី (ប្រពន្ធ ឬប្តី កូន និងឪពុកម្តាយ ឬជនចាស់ជរាក្នុងបន្ទុក)។

ចំណែកឯ មន្ត្រីសាធារណៈ ការផ្តល់តាវកាលិកហានិភ័យការងារ គឺផ្តល់ជូនសម្រាប់ការបាត់បង់សមត្ថភាពអចិន្ត្រៃយ៍ នៅពេលមានគ្រោះថ្នាក់ក្នុងអំឡុងពេលបំពេញបេសកកម្ម។ រីឯ ប្រាក់បៀវត្សក៏មិនត្រូវបានកាត់នៅពេលឈប់សម្រាកព្យាបាលជំងឺផងដែរ។

### ៣.៣.២ បញ្ហាប្រឈម

#### ៣.៣.២.១ របបហានិភ័យការងារសម្រាប់កម្មករនិយោជិត

បញ្ហាប្រឈមបីដែលតែងកើតឡើង នៅក្នុងក្របខ័ណ្ឌនៃរបបហានិភ័យការងារសម្រាប់កម្មករនិយោជិតគឺ (១) ដោយសារមិនមានសំបុត្រអាពាហ៍ពិពាហ៍ កូនមិនអាចទទួលតាវកាលិកពី ប.ស.ស នៅពេលដែលឪពុកឬម្តាយទទួលរងគ្រោះថ្នាក់ដោយសារការងាររហូតដល់បាត់បង់ជីវិត (២) កូនពិការនៅក្នុងបន្ទុកអាចទទួលបានអត្ថប្រយោជន៍ពី ប.ស.ស ត្រឹមអាយុ ២១ ឆ្នាំប៉ុណ្ណោះ ដែលការណ៍នេះធ្វើឲ្យកូនពិការដែលមានអាយុលើសពី២១ឆ្នាំ មិនមានចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាព និង (៣) ការកំណត់កញ្ចប់តាវកាលិក ដែលរួមបញ្ចូលសេវាបុននីតិសម្បទាសម្រាប់កម្មករនិយោជិត ក៏មិនទាន់មានភាពច្បាស់លាស់សម្រាប់ការដាក់ឲ្យអនុវត្ត។

#### ៣.៣.២.២ របបហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ

បច្ចុប្បន្ន មន្ត្រីសាធារណៈទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ នៅពេលសម្រាកព្យាបាលពីគ្រោះថ្នាក់ការងារ និងនៅពេលរងគ្រោះបាត់បង់សមត្ថភាពការងារ។ ចំណែកការព្យាបាល គឺផ្អែកតាមគោលនយោបាយរបស់ក្រសួងសាមីដែលមិនមានគោលការណ៍ ឬស្តង់ដារច្បាស់លាស់។ កត្តានេះ មិនទាន់

បានផ្តល់ការគាំពារពេញលេញជូនដល់មន្ត្រីសាធារណៈនៅពេលមានបញ្ហាសុខភាព ឬរងគ្រោះថ្នាក់ការងារ ជាពិសេសនៅពេលមានជំងឺរិដ្ឋជីវៈរ៉ាំរ៉ៃ ដោយសារការបំពេញការងារនោះឡើយ។

### ៣.៣.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត

#### ៣.៣.៣.១ របបហានិភ័យការងារសម្រាប់កម្មករនិយោជិត

រាជរដ្ឋាភិបាល នឹងកែសម្រួលលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងរបបហានិភ័យការងារសម្រាប់កម្មករនិយោជិតដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដើម្បីអនុញ្ញាតឲ្យកូននៅក្នុងបន្ទុកទទួលបានអត្ថប្រយោជន៍ពីរបបនេះ ទោះបីឪពុកឬម្តាយដែលជាសមាជិករបស់ ប.ស.ស ពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ហើយទទួលរងហានិភ័យការងាររហូតដល់បាត់បង់ជីវិត។ ម្យ៉ាងវិញទៀត ការកែសម្រួលលិខិតបទដ្ឋាននេះក៏នឹងអនុញ្ញាតឲ្យកូនពិការដែលពុំមានលទ្ធភាពរកប្រាក់ចំណូល ទទួលបានអត្ថប្រយោជន៍ពី ប.ស.ស រហូតអស់មួយជីវិត។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏នឹងដាក់បញ្ចូលសេវាបុននីតិសម្បទាបន្ថែម ទៅក្នុងកញ្ចប់តាវកាលិកសម្រាប់សមាជិករបស់ ប.ស.ស ផងដែរ។

#### ៣.៣.៣.២ របបហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ

ក្នុងរយៈកាលខ្លីចំពោះមុខ រាជរដ្ឋាភិបាលនឹងសិក្សារៀបចំឲ្យមានគោលការណ៍ និងស្តង់ដារច្បាស់លាស់សម្រាប់ការជួយទ្រទ្រង់ដល់មន្ត្រីសាធារណៈ ដែលរងគ្រោះដោយសារហានិភ័យការងារ។ នៅរយៈកាលមធ្យម ឬវែង រាជរដ្ឋាភិបាលនឹងរៀបចំឲ្យមានរបបហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈឲ្យទទួលបានតាវកាលិកពេញលេញ បន្ថែមលើតាវកាលិកដែលអនុវត្តបច្ចុប្បន្នដើម្បីឲ្យមានសង្គតិភាពជាមួយរបបហានិភ័យការងារផ្សេងទៀត ជាពិសេស គឺបន្ថែមការថែទាំជំងឺរិដ្ឋជីវៈរ៉ាំរ៉ៃ ដែលត្រូវការព្យាបាលរយៈពេលវែង និងមានចំណាយខ្ពស់។ ក្នុងដំណាក់កាលនេះ ដើម្បីធានាបាននូវសង្គតិភាពរវាងរបបថែទាំសុខភាព និងរបបហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ ប.ស.ស ដែលជាស្ថាប័នមានជំនាញនិងបទពិសោធន៍ផ្នែកនេះ នឹងត្រូវទទួលគ្រប់គ្រងនិងចាត់ចែងរបបហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈផងដែរ។

## ៣.៤ និកម្មភាព

### ៣.៤.១ ទិដ្ឋភាពទូទៅ

រហូតមកដល់ពេលនេះ របបនិកម្មភាព មិនទាន់មានវត្តមាននៅកម្ពុជានៅឡើយ។ ការដាក់ឲ្យដំណើរការរបបនេះ ត្រូវគិតគូរឲ្យបានគ្រប់ជ្រុងជ្រោយទៅតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចជាតិ និងស្ថានភាពសង្គម ព្រមទាំង ត្រូវការពេលវេលាដ៏សមស្របមួយ ដែលរបបនេះត្រូវអនុវត្តចំពោះតែជនទាំងឡាយណា ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារប៉ុណ្ណោះ។ រាជរដ្ឋាភិបាលបានដាក់ចេញរួចហើយនូវគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ ដែលក្នុងនោះក៏បានចង្អុលឲ្យមានការសិក្សាអំពីលទ្ធភាពដាក់ឲ្យដំណើរការរបបនេះផងដែរ។ គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ បានរួមចំណែកក្នុងការអនុវត្តប្រកបដោយភាពជោគជ័យនូវរបៀបវារៈគោល-

នយោបាយយុទ្ធសាស្ត្រ សំដៅបង្កើនឱកាសការងារសមរម្យជូនដល់ប្រជាជនកម្ពុជា និងលើកកម្ពស់ផលិតភាពការងារ ជំរុញការអភិវឌ្ឍជំនាញនិងធនធានមនុស្ស ព្រមទាំង ពង្រឹងអភិបាលកិច្ចទីផ្សារការងារដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ។

### ៣.៤.២ បញ្ហាប្រឈម

ទោះបីជា រាជរដ្ឋាភិបាលបានបង្ហាញអំពីឆន្ទៈតាមរយៈគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ ឲ្យមានការសិក្សាលើលទ្ធភាពដាក់ឲ្យដំណើរការរបបនេះក្តី ប៉ុន្តែផ្អែកលើបទពិសោធន៍កន្លងមកនៃបណ្តាប្រទេសដែលស្ថិតក្នុងកម្រិតអភិវឌ្ឍន៍ និងមានរចនាសម្ព័ន្ធទីផ្សារការងារប្រហាក់ប្រហែលកម្ពុជា បានបង្ហាញថាការដាក់ឲ្យដំណើរការរបបនិកម្មភាពអាចជួបបញ្ហាស្មុគស្មាញជាច្រើនដែលតម្រូវឲ្យមានពេលវេលា និងលទ្ធភាពគ្រប់គ្រាន់ ដើម្បីឆ្លើយតប និងដោះស្រាយបញ្ហាស្មុគស្មាញទាំងនោះ ទៅតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចជាតិ។

ម្យ៉ាងទៀតការដាក់ឲ្យដំណើរការរបបនិកម្មភាពនេះ ត្រូវការមន្ត្រីជំនាញដែលមានបទពិសោធន៍ច្បាស់លាស់ក្នុងការគ្រប់គ្រងនិងចាត់ចែង។ បច្ចុប្បន្ន ការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញសម្រាប់របបនេះនៅមានកង្វះខាតនៅឡើយ។

### ៣.៤.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត

របបនិកម្មភាព ដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារកម្មករនិយោជិតពីហានិភ័យក្នុងការធ្លាក់ចូលក្នុងភាពក្រីក្រនៅពេលបាត់បង់ឱកាសការងារ។ របបនិកម្មភាពនេះ ដើរតួកាន់តែសំខាន់នៅក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ច ដែលត្រូវបានចាត់ទុកជាធាតុផ្សំមួយក្នុងការរក្សានូវលំនឹងសេដ្ឋកិច្ច និងភាពចលាចលនៅក្នុងសង្គមផងដែរ។ ដូច្នេះ រាជរដ្ឋាភិបាលនឹងធ្វើការសិក្សាឲ្យបានច្បាស់អំពីលទ្ធភាពនៃការដាក់ឲ្យដំណើរការរបបនេះ ទៅតាមស្ថានភាពនៃការរីកចម្រើនរបស់សេដ្ឋកិច្ចជាតិ។

ក្រៅពីការសិក្សាអំពីលទ្ធភាពក្នុងការដាក់ឲ្យដំណើរការរបបនិកម្មភាពនេះ ការកសាងសមត្ថភាពមន្ត្រីជំនាញគឺជាកត្តាចាំបាច់មួយផងដែរដើម្បីត្រៀមខ្លួនទទួលយកការងារនេះ។ ផ្អែកតាមចរិតលក្ខណៈនៃរបបនិកម្មភាពនេះ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាស្ថាប័ននាំមុខក្នុងការបំពេញការងារទាំងនេះ។ ដូច្នេះ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកាតព្វកិច្ចទទួលបន្ទុកធ្វើការសិក្សាសមិទ្ធិលទ្ធភាពលើគម្រោងដាក់ឲ្យដំណើរការរបបនេះ ជាមួយនឹងការបង្កើតឲ្យមានក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ដោយប្រឹក្សាយោបល់ជាមួយស្ថាប័នរដ្ឋ ស្ថាប័នឯកជន និងដៃគូអភិវឌ្ឍន៍។

## ៣.៥ ពិការភាព

### ៣.៥.១ ទិដ្ឋភាពទូទៅ

ផ្អែកតាមរបាយការណ៍ជំរឿនឆ្នាំ២០១៣បង្ហាញថា កម្ពុជាមានជនពិការប្រមាណ ៣០០ ០០០ នាក់ ស្មើនឹង ២.០៦ ភាគរយ នៃចំនួនប្រជាជនសរុប។ មូលហេតុចម្បងនៃពិការភាពគឺបណ្តាលមកពី

គ្រាប់មីន និងសំណល់ជាតិផ្ទុះសេសសល់ពីសង្គ្រាមនៅមានចំនួនច្រើន។ ដើម្បីឆ្លើយតបនឹងបញ្ហានេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់លើការបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ដោយបានបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និងបានសហការជាមួយនឹងដៃគូអភិវឌ្ឍន៍ធ្វើកិច្ចការជាច្រើនក្នុងគោលដៅទប់ស្កាត់ និងបង្ការកំណើននៃជនពិការនៅកម្ពុជា។

ការលើកកម្ពស់ និងពង្រីកសិទ្ធិជាមូលដ្ឋានរបស់ជនពិការជាគោលដៅអាទិភាពមួយនៃគោល-នយោបាយសង្គមកិច្ចរបស់រាជរដ្ឋាភិបាល។ តាមរយៈការចង្អុលបង្ហាញរបស់ច្បាប់ស្តីពីការលើកកម្ពស់សិទ្ធិជនពិការ រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាសកម្មភាពជនពិការ ដោយមានយន្តការសម្របសម្រួលថ្នាក់ជាតិក្នុងការពិគ្រោះយោបល់លើបញ្ហាជនពិការ ការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីជនពិការព្រមទាំង ការតាមដាន និងការវាយតម្លៃលើការអនុវត្តគោលនយោបាយផ្សេងៗពាក់ព័ន្ធនឹងជនពិការ។

មូលនិធិជនពិការ (ម.ជ.ព) ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១០ ដើម្បីទទួលបន្ទុកការងារលើកកម្ពស់សុខុមាលភាពជនពិការ តាមរយៈការស្តារលទ្ធភាពពលកម្ម ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការរកការងារជូនជនពិការ ជាដើម។ ម.ជ.ព បានផ្តល់ការគាំពារជូនជនពិការជាមធ្យមចំនួនប្រមាណ ២៨ ០០០ នាក់ ជារៀងរាល់ឆ្នាំ។

រាជរដ្ឋាភិបាល បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ដែលជាផែនទីបង្ហាញផ្លូវរយៈពេលមធ្យម ដើម្បីកំណត់ឲ្យបានច្បាស់នូវគោលនយោបាយ និងការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធនីមួយៗពាក់ព័ន្ធនឹងការលើកកម្ពស់សុខុមាលភាពជនពិការ។

### ៣.៥.២ បញ្ហាប្រឈម

#### ៣.៥.២.១ ការកំណត់អត្តសញ្ញាណជនពិការ

យន្តការនៃការកំណត់អត្តសញ្ញាណរបស់ជនពិការនៅមានភាពខ្វះខាតច្រើននៅឡើយ ដែលនាំឲ្យជនពិការមួយចំនួន មិនបានទទួលអត្ថប្រយោជន៍ពីគោលនយោបាយនានារបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា។

#### ៣.៥.២.២ បញ្ហាហិរញ្ញវត្ថុ

មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មភាគច្រើនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ម.ជ.ព ទទួលហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។ នៅឆ្នាំ២០០២ កម្ពុជាមានមជ្ឈមណ្ឌលចំនួន ១៦ នៅទូទាំងប្រទេស ប៉ុន្តែបានថយចុះនៅត្រឹម ១១ ប៉ុណ្ណោះនាពេលបច្ចុប្បន្ន ដោយមូលហេតុសំខាន់មួយគឺកត្តាហិរញ្ញវត្ថុ។

#### ៣.៥.២.៣ គុណភាពនៃការស្តារលទ្ធភាពពលកម្ម

គុណភាពនៃការស្តារលទ្ធភាពពលកម្មនៅមានកម្រិត ដែលទាមទារឲ្យមានការពង្រឹងបន្ថែមទាំងលើសមត្ថភាពមន្ត្រីជំនាញក្នុងការពន្លឿនការព្យាបាលជូនជនពិការ ជាមួយនឹងឧបករណ៍បច្ចេកទេសជំនួយសម្រាប់ប្រក្រតីភាពនៃជីវិតជនពិការ។

### ៣.៥.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត

#### ៣.៥.៣.១ កំណែទម្រង់ការកំណត់អត្តសញ្ញាណរបស់ជនពិការ

ដើម្បីកំណត់អត្តសញ្ញាណជនពិការឲ្យបានគ្រប់ជ្រុងជ្រោយ រដ្ឋាភិបាលនឹងកែសម្រួលយន្តការ និងនីតិវិធីក្នុងការកំណត់អត្តសញ្ញាណរបស់ជនពិការ ដោយផ្តល់អាទិភាពលើជនពិការក្រីក្រ តាមរយៈការលើកកម្ពស់សមត្ថភាពស្ថាប័ន ការកសាងសមត្ថភាពមន្ត្រីជំនាញ និងការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា ជាមួយការគ្រប់គ្រងទិន្នន័យឲ្យបានច្បាស់លាស់ជាដើម។

#### ៣.៥.៣.២ ការកំណត់លក្ខខណ្ឌនៃការផ្តល់ការគាំពារ

ដើម្បីកាត់បន្ថយគម្លាតនៃការទទួលបានអត្ថប្រយោជន៍រវាងជនពិការ ដែលស្ថិតនៅក្នុងក្រុមគោលដៅផ្សេងៗគ្នា រាជរដ្ឋាភិបាលនឹងកំណត់ឡើងវិញនូវលក្ខខណ្ឌ និងយន្តការចាំបាច់នានា ដើម្បីធ្វើយ៉ាងណាផ្តល់អត្ថប្រយោជន៍ជូនជនពិការគ្រប់រូបប្រកបដោយសមធម៌។

#### ៣.៥.៣.៣ ការជំរុញការចូលរួមវិភាគទានពីវិស័យឯកជន

រាជរដ្ឋាភិបាលនឹងសិក្សាលើលទ្ធភាពក្នុងការលើកទឹកចិត្តដល់វិស័យឯកជន ឲ្យចូលរួមបង់វិភាគទានសម្រាប់ទ្រទ្រង់មូលនិធិជនពិការ តាមរយៈការដាក់ចេញនូវគោលនយោបាយលើកទឹកចិត្តផ្សេងៗ ដូចជា ការបង់ភាគទានចូលមូលនិធិជនពិការត្រូវបានទទួលស្គាល់ជាចំណាយមុនបង់ពន្ធ (Tax Deductible Expense) ឬការលើកទឹកចិត្តផ្សេងទៀត។

#### ៣.៥.៣.៤ ការបង្កើនគុណភាពស្តារលទ្ធភាពពលកម្មជនពិការ

រាជរដ្ឋាភិបាលនឹងជំរុញការបង្កើនគុណភាពនៃការស្តារលទ្ធភាពពលកម្មជូនជនពិការ ដូចជា បង្កើនប្រសិទ្ធភាពនៃការព្យាបាល និងពន្លឿនប្រក្រតីភាពជីវិតនៃជនពិការ ព្រមទាំង ពង្រឹងការអនុវត្តច្បាប់ការងារដើម្បីធានាឲ្យបាននូវសុវត្ថិភាពនៅកន្លែងធ្វើការ ក្នុងគោលដៅកាត់បន្ថយគ្រោះថ្នាក់ និងពិការភាពដែលបង្កឡើងដោយគ្រោះថ្នាក់ការងារ។ កត្តានេះ មិនត្រឹមតែបង្កើនប្រសិទ្ធភាពនៃចំណាយថវិកាប៉ុណ្ណោះទេ ថែមទាំងអាចលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់ជនពិការឲ្យកាន់តែប្រសើរឡើងផងដែរ។

#### ៣.៥.៣.៥ ការបង្កើនការបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ

រាជរដ្ឋាភិបាលនឹងជំរុញលើកទឹកចិត្តឲ្យជនពិការគ្រប់រូប ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្តល់លទ្ធភាពឲ្យពួកគាត់អាចត្រឡប់ចូលបម្រើការងារវិញ ឬមានលទ្ធភាពក្នុងការបង្កើតមុខរបរផ្ទាល់ខ្លួនថ្មី។ ក្រៅពីនេះ រាជរដ្ឋាភិបាលក៏នឹងបង្កើតកម្មវិធីស្វែងរកការងារធ្វើជូនជនពិការដែលទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។

### ៣.៥.៣.៦ ការធ្វើសមាហរណកម្មការគ្រប់គ្រងមូលនិធិជនពិការ

រាជរដ្ឋាភិបាលនឹងបង្វែរការគ្រប់គ្រង ម.ជ.ព ឲ្យស្ថិតនៅក្រោមប្រតិបត្តិករសន្តិសុខសង្គមរួម ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពចំណាយថវិកា ព្រមទាំង ផ្តល់លទ្ធភាពក្នុងការធ្វើសម្បទានឆ្លងពីអតិរេកថវិការបស់របបផ្សេងៗ ដើម្បីទ្រទ្រង់ការលើកកម្ពស់សុខមាលភាពជនពិការឲ្យកាន់តែប្រសើរឡើង។ ទន្ទឹមនេះ ការបង្វែរការគ្រប់គ្រងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មឲ្យស្ថិតនៅក្រោមប្រតិបត្តិកររួម ផ្តល់លទ្ធភាពក្នុងការពង្រីកវិសាលភាពនៃការផ្តល់សេវាស្តារលទ្ធភាពពលកម្មនេះសម្រាប់ជនពិការគ្រប់រូប ទាំងជនពិការដែលជាមន្ត្រីសាធារណៈ កម្មករនិយោជិតដែលបាត់បង់សម្បទាវិជ្ជាជីវៈនៅក្នុងពេលបម្រើការងារ និងជនពិការទូទៅទៀតផង។

# ◆ ជំពូកទី៤

# អភិបាលកិច្ច

# ជំពូកទី៤

# អភិបាលកិច្ច

## ៤.១ ទិដ្ឋភាពទូទៅ

បច្ចុប្បន្ន គោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធគាំពារសង្គម ត្រូវបានដាក់ចេញដោយក្រសួង-ស្ថាប័នរដ្ឋជាច្រើនទៅតាមមុខងារនិងភារកិច្ចរៀងៗខ្លួន។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានសមត្ថកិច្ចក្នុងការរៀបចំគោលនយោបាយដែលពាក់ព័ន្ធនឹងការគាំពារសង្គម ទាំងកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងជនពិការ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈផ្តោតលើការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់កម្មករនិយោជិត និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រសួងសុខាភិបាលទទួលបន្ទុកលើមូលនិធិសមធម៌ ដែលផ្តល់ការគាំពារផ្នែកសុខភាពសម្រាប់ប្រជាជនក្រីក្រនិងងាយរងគ្រោះ និងការលើកកម្ពស់សុខភាពមាតានិងទារក។ ក្រសួងអប់រំ យុវជន និងកីឡាផ្តោតលើកម្មវិធីផ្តល់អាហារតាមសាលារៀននិងអាហារូបករណ៍។ ចំណែកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកលើកម្មវិធីសន្តិសុខស្បៀង។ រីឯ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដើរតួជាស្ថាប័នសម្របសម្រួលការរៀបចំគោលនយោបាយជំនួយសង្គម។

## ៤.២ បញ្ហាប្រឈម

ការរៀបចំគោលនយោបាយគាំពារសង្គមដោយឡែកពីគ្នារបស់ក្រសួង-ស្ថាប័ននីមួយៗ បង្ហាញពីកង្វះខាតនូវយន្តការសម្របសម្រួលរួមមួយ។ កត្តានេះនាំឲ្យមានអសង្គតិភាព ភាពខ្វះចន្លោះ ឬភាពត្រួតស៊ីគ្នារវាងគោលនយោបាយនីមួយៗ ដែលមានផលប៉ះពាល់ជាអវិជ្ជមានដល់ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន ទាំងធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស។

មិនតែប៉ុណ្ណោះ យន្តការតាមដាន និងត្រួតពិនិត្យអំពីប្រសិទ្ធភាពនៃការគ្រប់គ្រង ឬដំណើរការកម្មវិធីជាតិនីមួយៗក៏មិនទាន់មានវត្តមាននៅឡើយ ដែលនេះជាឧបសគ្គសម្រាប់ការវាស់ស្ទង់ផលិត-ភាពនិងប្រសិទ្ធភាពនៃការវិនិយោគសាធារណៈរបស់រដ្ឋ ព្រមទាំង ផ្តល់ផលវិបាកផងដែរក្នុងការកំណត់គោលនយោបាយអភិវឌ្ឍន៍ជាបន្តបន្ទាប់។

## ៤.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត

នៅចំពោះមុខបញ្ហាប្រឈម និងចំណុចខ្វះខាតលើរចនាសម្ព័ន្ធនៃការគ្រប់គ្រងប្រព័ន្ធគាំពារសង្គមនេះ រាជរដ្ឋាភិបាលបានកំណត់នូវគោលដៅក្នុងការរៀបចំឲ្យមានប្រព័ន្ធគាំពារសង្គម ដែលមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព និងប្រសិទ្ធភាព គ្របដណ្តប់ទាំងវិស័យសាធារណៈ និងឯកជន ដែលត្រូវមានការកំណត់ និងបែងចែកតួនាទីច្បាស់លាស់រវាង និងក្នុងកម្រិតនីមួយៗ ពោលគឺកម្រិតគោលនយោបាយ កម្រិតបញ្ញត្តិករ និងកម្រិតប្រតិបត្តិករ។

### ៤.៣.១ កម្រិតគោលនយោបាយ

ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឲ្យកាន់តែប្រសើរឡើង ព្រមទាំង ដើម្បីឆ្លើយតបនឹងតម្រូវការបន្ស៊ីយុទ្ធសាស្ត្រ គោលនយោបាយ និងសកម្មភាពគាំពារសង្គមនានា រាជរដ្ឋាភិបាលនឹងបង្កើត "**ក្រុមប្រឹក្សាជាតិគាំពារសង្គម**" ដែលមានតួនាទីជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួល និងតម្រង់ទិសជាយុទ្ធសាស្ត្ររួម លើការងាររៀបចំគោលនយោបាយគាំពារសង្គមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

#### ៤.៣.១.១ សមាសភាព នៃក្រុមប្រឹក្សាជាតិគាំពារសង្គម

ដើម្បីធានានូវការបំពេញភារកិច្ចសម្របសម្រួលពហុវិស័យ ប្រកបដោយប្រសិទ្ធភាពខ្ពស់ "**ក្រុមប្រឹក្សាជាតិគាំពារសង្គម**" នេះ នឹងត្រូវបង្កើតឡើងដោយមានសមាសភាពជាឥស្សរជនមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល។ ក្រុមប្រឹក្សាជាតិនេះ ត្រូវមានសមាសភាពមកពីក្រសួង-ស្ថាប័នសំខាន់ៗរួមមាន៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងផែនការ ក្រសួងយុត្តិធម៌ និងក្រសួងមុខងារសាធារណៈ ជាដើម។

#### ៤.៣.២.២ មុខងារនៃក្រុមប្រឹក្សាជាតិគាំពារសង្គម

ក្រុមប្រឹក្សាជាតិគាំពារសង្គម មានមុខងារ (១) សម្របសម្រួលការរៀបចំគោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធគាំពារសង្គមរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ឲ្យមានលក្ខណៈជាគោលនយោបាយរួមដើម្បីដាក់ស្នើសុំការអនុម័តពីប្រមុខរាជរដ្ឋាភិបាល (២) ពិនិត្យ និងតាមដានលើវឌ្ឍនភាព និងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយគាំពារសង្គម ដើម្បីជំរុញឲ្យការអនុវត្តប្រព្រឹត្តទៅដោយរលូនមានសង្គតិភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព និង (៣) ផ្សារភ្ជាប់ និងបន្ស៊ីប្រព័ន្ធជំនួយសង្គមជាមួយនឹងប្រព័ន្ធសន្តិសុខសង្គម ដើម្បីធានាសង្គតិភាព និងបំពេញបន្ថែមសកម្មភាពចាំបាច់ នៅក្នុងចក្ខុវិស័យរួមនៃប្រព័ន្ធគាំពារសង្គម និងផ្តល់លទ្ធភាពសម្រាប់ការផ្ទេរក្រុមគោលដៅពីប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀតនៅពេលដែលឱកាសផ្តល់ឲ្យ។ ក្រុមប្រឹក្សាជាតិគាំពារសង្គម មានអគ្គលេខាធិការដ្ឋានដើម្បីទទួលបន្ទុកការងារប្រចាំថ្ងៃ។ អគ្គលេខាធិការដ្ឋាននេះ ត្រូវបង្កើតឡើងក្រោមចំណុះក្រសួង-ស្ថាប័នសមស្របមួយរបស់រាជរដ្ឋាភិបាលដោយឈរលើគោលការណ៍ ប្រសិទ្ធភាព និងសក្តិសិទ្ធិភាពនៃការគ្រប់គ្រង និងការសម្របសម្រួលស្ថាប័ន។

### ៤.៣.២ កម្រិតបញ្ញត្តិករ

ខុសប្លែកពីកម្មវិធី និងសកម្មភាពនៃប្រព័ន្ធជំនួយសង្គម ដែលទទួលហិរញ្ញប្បទានពីថវិកាជាតិ ភាពជោគជ័យនៃប្រព័ន្ធសន្តិសុខសង្គម គឺអាស្រ័យលើទំនុកចិត្តរបស់អ្នកចូលរួមដែលបានបង់ភាគទាន។ ចំណុចនេះទាមទារឲ្យមានយន្តការត្រួតពិនិត្យ និងតាមដានជាទៀងទាត់ដើម្បីធានាថា ផលប្រយោជន៍

របស់អ្នកចូលរួមក្នុងរបបនីមួយៗត្រូវបានរក្សា។ លើសពីនេះ ដំណើរការរបបសន្តិសុខសង្គមមានលក្ខណៈស្មុគស្មាញនិងហានិភ័យខ្ពស់ ដែលអាចជះឥទ្ធិពលដល់ស្ថិរភាពនៃវិស័យហិរញ្ញវត្ថុ និងថវិកាជាតិ ព្រមទាំង សេដ្ឋកិច្ចជាតិទាំងមូល។ ដូច្នេះ រាជរដ្ឋាភិបាលនឹងបង្កើតបញ្ញត្តិករសន្តិសុខសង្គម ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យដំណើរការប្រព្រឹត្តទៅរបស់ស្ថាប័នប្រតិបត្តិករសន្តិសុខសង្គម។ បញ្ញត្តិករមានតួនាទីចម្បងក្នុងការតាមដានស្ថានភាពហិរញ្ញវត្ថុ កំណត់បទប្បញ្ញត្តិប្រុងប្រយ័ត្ន ស្តង់ដារប្រតិបត្តិការ និងវិធានចាំបាច់នានា ព្រមទាំង ត្រួតពិនិត្យអនុលោមភាពដើម្បីធានាថាប្រតិបត្តិការនៅក្នុងការផ្តល់សេវាសន្តិសុខសង្គមប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព និងចីរភាពហិរញ្ញវត្ថុ។ ទន្ទឹមនេះ ការបង្កើតយន្តការការពារសមាជិក និងផ្សះផ្សាវិវាទនៅពេលមានទំនាស់ ក៏ជាការទទួលខុសត្រូវរបស់ស្ថាប័នបញ្ញត្តិករផងដែរ។

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការបំពេញការងារ និងដើម្បីចៀសវាងនូវការបង្កើតស្ថាប័នច្រើន និងរាយប៉ាយ ដែលនាំឲ្យមានផលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការចំណាយថវិកាជាតិ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម នឹងបំពេញមុខងារបន្ថែមជាស្ថាប័នបញ្ញត្តិករដើម្បីតាមដាន គ្រប់គ្រង និងត្រួតពិនិត្យរាល់ប្រតិបត្តិការរបស់ប្រតិបត្តិករសន្តិសុខសង្គម។

### ៤.៣.៣ កម្រិតប្រតិបត្តិករ

គោលដៅចម្បងមួយនៃការធ្វើកំណែទម្រង់ប្រព័ន្ធគាំពារសង្គមនេះ គឺការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធគ្រប់គ្រងរបស់ស្ថាប័នប្រតិបត្តិករ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រង និងដើម្បីបង្កើនប្រសិទ្ធភាពចំណាយថវិកាផងដែរ។ តាមរយៈនេះ រាជរដ្ឋាភិបាលនឹងធ្វើការកែទម្រង់ស្ថាប័នប្រតិបត្តិករដូចខាងក្រោម៖

#### ៤.៣.៣.១ ប្រតិបត្តិករជំនួយសង្គម

រាជរដ្ឋាភិបាលនឹងសិក្សាលើលទ្ធភាពក្នុងការបង្កើតមូលនិធិជំនួយសង្គម ដើម្បីគ្រប់គ្រង និងដាក់ឲ្យដំណើរការកម្មវិធីជាតិជំនួយសង្គមដែលមានលក្ខណៈជាកម្មវិធីឧបត្ថម្ភជាសាច់ប្រាក់។ ការបង្កើតមូលនិធិនេះ គឺជាការរៀបចំយន្តការសម្រាប់ការបោះជំហានទៅរកការធ្វើសមាហរណកម្មកម្មវិធីឧបត្ថម្ភសាច់ប្រាក់ទាំងអស់ឲ្យទៅជាកញ្ចប់កម្មវិធីតែមួយនៅពេលអនាគតផងដែរ។

មូលនិធិជំនួយសង្គម ក៏ដើរតួយ៉ាងសំខាន់ផងដែរក្នុងការរៀបចំយន្តការបំពេញការងារជាមួយថ្នាក់ក្រោមជាតិ ដើម្បីជំរុញ និងបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាជំនួយសង្គមទាំងឡាយ ព្រមទាំងសម្របសម្រួលលើការរៀបចំការគ្រប់គ្រងប្រព័ន្ធចុះបញ្ជីសមាជិកឲ្យមានលក្ខណៈទូលំទូលាយ និងប្រមូលផ្តុំ។

#### ៤.៣.៣.២ ប្រតិបត្តិករសន្តិសុខសង្គម

រាជរដ្ឋាភិបាលនឹងធ្វើកំណែទម្រង់ស្ថាប័ន តាមរយៈការធ្វើសមាហរណកម្មស្ថាប័នប្រតិបត្តិករដែលមានស្រាប់ទាំងអស់ពោលគឺ ប.ជ.ស ប.ជ.អ ប.ស.ស និង ម.ជ.ព ឲ្យទៅជាស្ថាប័នតែមួយ។

ស្ថាប័នថ្មីនេះគឺជាគ្រឹះស្ថានសាធារណៈ ដែលមានមុខងារគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមទាំងអស់រួមមាន៖ សោធន ថែទាំសុខភាព ហានិភ័យការងារ ពិការភាព និងនិកម្មភាព។ល។

**រូបភាពទី១៥៖ ការធ្វើសមាហរណកម្មប្រតិបត្តិករសន្តិសុខសង្គម**




### ៤.៣.៣.៣ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ស្ថាប័នប្រតិបត្តិករសន្តិសុខសង្គម

*ក. ក្រុមប្រឹក្សាភិបាល*

សមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ស្ថាប័នទាំងនេះ ត្រូវមានសមាសភាពមកពីស្ថាប័នពាក់ព័ន្ធទាំងអស់ រួមមានតំណាងមកពីស្ថាប័នរដ្ឋ តំណាងនិយោជក និងតំណាងនិយោជិត ព្រមទាំងអាចមានតំណាងស្ថាប័នផ្តល់សេវាសុខាភិបាលផងដែរ។

*ខ. គណៈកម្មាធិការជំនាញ*

គណៈកម្មាធិការជំនាញមួយចំនួន គួរត្រូវបង្កើតឡើងដើម្បីជំរុញប្រសិទ្ធភាពការងាររួមមាន៖ គណៈកម្មាធិការត្រួតពិនិត្យគុណភាពសុខាភិបាល គណៈកម្មាធិការវិនិយោគ គណៈកម្មាធិការសវនកម្ម ឬគណៈកម្មាធិការចាំបាច់ផ្សេងទៀត។

*គ. គោលការណ៍ប្រតិបត្តិ*

ប្រតិបត្តិការរបស់ស្ថាប័ននេះ ត្រូវធ្វើឡើងដោយឈរលើគោលការណ៍អភិបាលកិច្ចល្អ។ ស្ថាប័នប្រតិបត្តិករត្រូវអនុវត្តទៅតាមគោលការណ៍ចម្បងមួយចំនួនដូចជា (១) ការរៀបចំបញ្ជិកាគណនេយ្យដោយអនុលោមតាមស្តង់ដារ (២) ការបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (៣) ការដាក់ឲ្យធ្វើសវនកម្មឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុ (៤) ការផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍ហិរញ្ញវត្ថុ និង (៥) ការដាក់ឲ្យមានការវាយតម្លៃឯករាជ្យលើប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ថវិកាភាគទាននៅរៀងរាល់ ៥ ឬ ១០ ឆ្នាំម្តង។

*ឃ. យន្តការធ្វើសម្បទានឆ្លង*

រាជរដ្ឋាភិបាល នឹងសិក្សាសមិទ្ធិលទ្ធភាពលើការរៀបចំយន្តការធ្វើសម្បទានឆ្លងរវាងរបប ឬកម្មវិធីនីមួយៗ (លើកលែងរបបសោធន) ដើម្បីប្រើប្រាស់ធនធាននៃរបប ឬកម្មវិធីដែលមានអតិរេកថវិកាមកជួយស្រោចស្រង់របប ឬកម្មវិធីដែលមានឱនភាពថវិកា ក្នុងគោលដៅជៀសវាងការទម្លាក់បន្ទុកទាំង

ស្រុងមកលើថវិកាជាតិនៅពេលដែលរបបណាមួយមានឱនភាពថវិកា។ ការធ្វើសម្បទានឆ្លងនេះចាំបាច់ត្រូវគិតគូរដល់ចីរភាព និងភាពរឹងមាំផ្នែកហិរញ្ញវត្ថុនៃរបប ឬកម្មវិធីដែលពាក់ព័ន្ធ និងជៀសវាងនូវការកើតមាននូវហានិភ័យចិត្តសាស្ត្រចំពោះរបបឬកម្មវិធីទាំងនោះ។

**រូបភាពទី១៦៖ រចនាសម្ព័ន្ធនៃប្រព័ន្ធគាំពារសង្គម**



# ◆ ជំពូកទី៥

# បញ្ហាភូខវិស័យ

# ជំពូកទី៥
# បញ្ហាប្រឈមក្នុងវិស័យ

## ៥.១ ការវិនិយោគ

### ៥.១.១ ទិដ្ឋភាពទូទៅ

វិស័យធនាគារគឺជាវិស័យនាំមុខនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា។ គ្រឹះស្ថានធនាគារបានកើនឡើងជាលំដាប់ ដែលនៅឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាបណ្ណធនាគារពាណិជ្ជចំនួន ៣៦ ធនាគារឯកទេសចំនួន ៩ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៤៤។ អត្រាការប្រាក់នៃប្រាក់បញ្ញើមានកាលកំណត់ជារូបិយវត្ថុជាតិស្ថិតនៅក្នុងរង្វង់គួរឲ្យទាក់ទាញ (ក្នុងចន្លោះពី ៥ ទៅ ១០ ភាគរយ)។

ទីផ្សារវិនិយោគមូលនិធិនៅកម្ពុជា ស្ថិតក្នុងដំណាក់កាលចាប់ផ្តើមនៅឡើយ ដោយសារតែការអភិវឌ្ឍរបស់ទីផ្សារហិរញ្ញវត្ថុនៅមានកម្រិត។ ទីផ្សារមូលបត្របានចាប់ផ្តើមដំណើរការនៅឆ្នាំ២០១១ ហើយរហូតមកដល់ពេលនេះមានក្រុមហ៊ុនចំនួន ៤ (ក្នុងនោះ ២ ជាសហគ្រាសរដ្ឋ) បានចុះបញ្ជីលក់មូលបត្រនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្នុងទិសដៅជំរុញការអភិវឌ្ឍទីផ្សារមូលបត្រ គណៈ-កម្មការមូលបត្រកម្ពុជា (គ.ម.ក) បានកែសម្រួលប្រកាសស្តីពីការបោះផ្សាយមូលបត្រជាសាធារណៈ ដើម្បីបន្ធូរបន្ថយលក្ខខណ្ឌតម្រូវមួយចំនួនសម្រាប់ក្រុមហ៊ុនបោះផ្សាយ ដោយធ្វើការបែងចែកទីផ្សារជាពីរគឺ (១) ទីផ្សារគោលសម្រាប់សហគ្រាសខ្នាតធំ និង (២) ទីផ្សារកំណើនសម្រាប់សហគ្រាសធុនតូច និងមធ្យម។

ដោយឡែក វិស័យអចលនទ្រព្យក៏បាននិងកំពុងមានសន្ទុះរីកចម្រើនយ៉ាងខ្លាំងក្លាបន្ទាប់ពីវិបត្តិហិរញ្ញវត្ថុសកល។

### ៥.១.២ បញ្ហាប្រឈម

ឧបករណ៍ហិរញ្ញវត្ថុសម្រាប់វិនិយោគមិនទាន់មានលក្ខណៈសម្បូរបែប ដូចជា អវត្តមានរបស់មូលបត្ររដ្ឋនិងសញ្ញាបណ្ណឯកជន ចំនួនតិចតួចនៃក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈជាដើម។ រីឯ ទីផ្សារវិនិយោគមូលនិធិឯកជន (Private Equity) ក៏នៅមានទំហំតូច។ ជាក់ស្តែង ប.ស.ស ដែលជាស្ថាប័នប្រតិបត្តិកររបបសន្តិសុខសង្គម ដែលមានអតិរេកមូលនិធិអាចយកទៅធ្វើការវិនិយោគបាននោះ បានវិនិយោគមូលនិធិរបស់ខ្លួនតែលើប្រាក់បញ្ញើនៅធនាគារប៉ុណ្ណោះ។ លើសពីនេះ ជំនាញវិជ្ជាជីវៈពាក់ព័ន្ធ រួមទាំងក្របខ័ណ្ឌបទប្បញ្ញត្តិចាំបាច់នានាក៏នៅមិនទាន់ពេញលេញ។

### ៥.១.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត

#### ៥.១.៣.១ ការបន្តផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនបោះផ្សាយ

រាជរដ្ឋាភិបាលបន្តជំរុញលើកទឹកចិត្តឲ្យក្រុមហ៊ុនឯកជន និងសហគ្រាសរដ្ឋធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ តាមរយៈការកែសម្រួលអនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលរំពឹងថាចំនួនក្រុមហ៊ុនចុះបញ្ជីបោះផ្សាយលក់មូលបត្រនឹង

មានការកើនឡើងជាបន្តបន្ទាប់ តាមរយៈការកែសម្រួលលក្ខខណ្ឌសម្រាប់ការចុះបញ្ជីបោះផ្សាយលក់មូលបត្រជាសាធារណៈ ដើម្បីអនុញ្ញាតឲ្យសហគ្រាសធុនតូចនិងមធ្យម មានលទ្ធភាពក្នុងការកៀរគរហិរញ្ញប្បទានក្នុងទីផ្សារមូលបត្រ។

### ៥.១.៣.២ ជំរុញការអភិវឌ្ឍទីផ្សារសញ្ញាបណ្ណ

រាជរដ្ឋាភិបាលបាននិងកំពុងរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិ និងបច្ចេកទេស ដើម្បីត្រៀមខ្លួនក្នុងការចាប់ផ្តើមធ្វើការបោះផ្សាយលក់មូលបត្ររដ្ឋ ឲ្យស្របនឹងគោលដៅនៃយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ។ គោលដៅនៃការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ គឺមិនត្រឹមតែលើកកម្ពស់បរិដ្ឋានវិនិយោគសម្រាប់មូលនិធិសន្តិសុខសង្គមប៉ុណ្ណោះទេ ប៉ុន្តែនឹងក្លាយជាកត្តាលីករដ៏សំខាន់ក្នុងការជំរុញការអភិវឌ្ឍទីផ្សារទុន និងទីផ្សាររូបិយវត្ថុក្នុងស្រុកផងដែរ។ មិនតែប៉ុណ្ណោះ ទីផ្សារមូលបត្ររដ្ឋនឹងផ្តល់ជាយន្តការសមស្របសម្រាប់ការកៀរគរហិរញ្ញប្បទាន ប្រកបដោយនិរន្តរភាពរបស់រាជរដ្ឋាភិបាល ជាពិសេសនៅពេលដែលហិរញ្ញប្បទានសហប្រតិបត្តិការកាន់តែថយចុះជាបន្តបន្ទាប់ ដោយសារការវិវឌ្ឍឈានឡើងនៃសេដ្ឋកិច្ចកម្ពុជា។ បន្ថែមលើនេះ រាជរដ្ឋាភិបាលក៏បាននិងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តិចាំបាច់ ដើម្បីផ្តល់ការអនុញ្ញាតឲ្យក្រុមហ៊ុនឯកជន អាចធ្វើការបោះផ្សាយលក់សញ្ញាបណ្ណសាជីវកម្មនៅក្នុងទីផ្សារមូលបត្រ ផងដែរ។

### ៥.១.៣.៣ ការរៀបចំគោលការណ៍ណែនាំស្តីពីវិនិយោគ

បញ្ញត្តិករប្រព័ន្ធសន្តិសុខសង្គម មានតួនាទីរៀបចំគោលការណ៍ណែនាំស្តីពីការវិនិយោគមូលនិធិរបស់ស្ថាប័នប្រតិបត្តិករ ដែលផ្តោតទៅលើការធ្វើពិពិធកម្មការវិនិយោគ ដោយមិនពឹងផ្អែកទាំងស្រុងតែលើការវិនិយោគក្នុងវិស័យធនាគារ ដើម្បីកំណត់អំពីទម្រង់នៃផតហ្វូលីយ៉ូ និងកម្រិតហានិភ័យ ក្នុងគោលដៅធានាឲ្យបាននូវស្ថិរភាព និងនិរន្តរភាពនៃមូលនិធិ។

### ៥.១.៣.៤ ការរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងការវិនិយោគមូលនិធិ

រាជរដ្ឋាភិបាល តាមរយៈ គ.ម.ក នឹងបញ្ចប់ការរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រង និងការផ្តល់អាជ្ញាបណ្ណដល់គម្រោងវិនិយោគរួម (Collective Investment Scheme – CIS) ដើម្បីអនុញ្ញាតឲ្យស្ថាប័ននេះអាចដំណើរការនៅកម្ពុជា។ ទន្ទឹមនេះ ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីបរធនបាលកិច្ចក៏នឹងត្រូវពន្លឿនដើម្បីផ្តល់ក្របខ័ណ្ឌគតិយុត្តិសមស្រប សម្រាប់ការការពារលើរាល់សកម្មភាពវិនិយោគនីមួយៗ។

## ៥.២ គោលនយោបាយពន្ធដារ

### ៥.២.១ ទិដ្ឋភាពទូទៅ

ការគិតគូរគ្រប់ជ្រុងជ្រោយលើគោលនយោបាយពន្ធដារ ដែលពាក់ព័ន្ធនឹងប្រតិបត្តិការនៃប្រព័ន្ធគាំពារសង្គម គឺជាកត្តាចាំបាច់ក្នុងការចូលរួមចំណែកអភិវឌ្ឍប្រព័ន្ធនេះ ជាពិសេស ការលើកទឹកចិត្តឲ្យមានការចូលរួមពីសំណាក់ប្រជាជនកាន់តែច្រើនឡើងៗ។ ប្រតិបត្តិការនៃរបបសន្តិសុខសង្គម ដែលជារបបបង់ភាគទាន គឺជាកម្មវត្ថុនៃការគិតគូរលើគោលនយោបាយពន្ធដារនេះ ក្នុងនោះរួមមាន៖ (១)

ប្រតិបត្តិការបង់ភាគទាន (២) ប្រាក់ចំណេញពីការវិនិយោគមូលនិធិ និង (៣) ប្រតិបត្តិការបើកផ្តល់តាវកាលិក។

តាមរយៈខ្លឹមសារនៃសារាចរណែនាំលេខ ០០២ សហវ. ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែមបញ្ជាក់ថា ប្រាក់ឧបត្ថម្ភដែលកម្មករនិយោជិតទទួលបានពីរបបសន្តិសុខសង្គម មិនត្រូវបានគិតបញ្ចូលក្នុងមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស និងមិនមែនជាកម្មវត្ថុនៃពន្ធលើអត្ថប្រយោជន៍បន្ថែមទេ។ ប៉ុន្តែ តាវកាលិកនៃរបបសន្តិសុខសង្គម សម្រាប់ក្រុមប្រជាជនផ្សេងទៀត មិនទាន់ត្រូវបានកំណត់ឲ្យបានច្បាស់លាស់នោះទេ។

## ៥.២.២ បញ្ហាប្រឈម

គោលនយោបាយពន្ធដារ ពាក់ព័ន្ធនឹងប្រតិបត្តិការនានានៃប្រព័ន្ធគាំពារសង្គមនៅមិនទាន់បានកំណត់ឲ្យបានគ្រប់គ្រាន់ និងច្បាស់លាស់ខណៈដែលប្រព័ន្ធគាំពារសង្គមនេះនៅមិនទាន់បានចាប់ផ្តើមអនុវត្តនៅឡើយ។ ការកំណត់ឲ្យបានជាក់លាក់នូវរបបពន្ធ នាំឲ្យមានការចូលរួមជាបច្ច័យជាវិជ្ជមានក្នុងការជំរុញការអភិវឌ្ឍប្រព័ន្ធនេះ ទាំងការចូលរួមបង់ភាគទាននៅក្នុងរបបសន្តិសុខសង្គម ក៏ដូចជាការលើកទឹកចិត្តឲ្យមានការចូលរួមបង់ប្រាក់វិភាគទានសម្រាប់ទ្រទ្រង់កម្មវិធីជំនួយសង្គមផងដែរ។

## ៥.២.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត

### ៥.២.៣.១ របបពន្ធលើការបង់ភាគទានចូលរបបសន្តិសុខសង្គម

រាល់ភាគទានដែលបង់ចូលមូលនិធិសន្តិសុខសង្គមរបស់មន្ត្រីសាធារណៈ និងកម្មករនិយោជិតគួរត្រូវបានដកចេញពីមូលដ្ឋានសម្រាប់ការគិតពន្ធលើប្រាក់បៀវត្ស។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងរៀបចំលិខិតបទដ្ឋានគតិយុត្តិចាំបាច់ដើម្បីកំណត់អំពីមូលដ្ឋាននៃការគិតពន្ធនេះ។

### ៥.២.៣.២ របបពន្ធសម្រាប់ប្រាក់ចំណេញពីការវិនិយោគមូលនិធិ

ប្រាក់ចំណេញដែលទទួលបានពីការវិនិយោគមូលនិធិ ជាទូទៅ ត្រូវជាប់កាតព្វកិច្ចពន្ធតាមច្បាប់ស្តីពីសារពើពន្ធ។ ប៉ុន្តែដើម្បីផ្តល់ជាអត្ថប្រយោជន៍បន្ថែមដល់និវត្តជន រាជរដ្ឋាភិបាលនឹងសិក្សាអំពីផលប៉ះពាល់នានា ដើម្បីឈានទៅដល់ការសម្រេចចិត្តក្នុងការផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារចំពោះប្រតិបត្តិការនេះ។

### ៥.២.៣.៣ របបពន្ធសម្រាប់តាវកាលិករបបសន្តិសុខសង្គម

ការទទួលបានតាវកាលិកពីរបបសន្តិសុខសង្គម មិនទាន់មានការកំណត់ឲ្យបានច្បាស់អំពីការលើកលែង ឬការអនុគ្រោះពន្ធនៅឡើយ។ រាជរដ្ឋាភិបាលនឹងរៀបចំក្របខ័ណ្ឌគតិយុត្តិចាំបាច់ ដើម្បីបំពេញនូវភាពខ្វះចន្លោះទាំងនេះ។

### ៥.២.៣.៤ របបពន្ធសម្រាប់ការចូលរួមវិភាគទានសប្បុរសធម៌ក្នុងមូលនិធិជំនួយសង្គម

រាជរដ្ឋាភិបាលនឹងសិក្សាលើលទ្ធភាពក្នុងការកំណត់អំពីការលើកទឹកចិត្តផ្នែកពន្ធដារ លើការបង់ប្រាក់វិភាគទានសប្បុរសធម៌ទៅឲ្យមូលនិធិជំនួយសង្គមនានា ដើម្បីលើកទឹកចិត្តឲ្យមានការចូលរួម

វិភាគទានក្នុងវិស័យនេះឲ្យកាន់តែច្រើនឡើង។ ការដកការបង់វិភាគទានសប្បុរសធម៌របស់សហគ្រាស ឬស្ថាប័ននានាពីប្រាក់ចំណូលដែលជាប់ពន្ធ គឺជាទិសដៅអាទិភាព ដែលនឹងត្រូវលើកយកមកសិក្សា។

## ៥.៣ ប្រព័ន្ធចុះបញ្ជី

### ៥.៣.១ ទិដ្ឋភាពទូទៅ

ប្រព័ន្ធចុះបញ្ជីក្រុមប្រជាជន ដែលត្រូវទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ត្រូវបានដំណើរការដោយឡែកផ្សេងៗគ្នាទៅតាមមុខងារ និងភារកិច្ចរបស់ស្ថាប័នមានសមត្ថកិច្ចដែលទទួលខុសត្រូវទៅតាមប្រភេទនៃកម្មវិធី និងរបបរៀងៗខ្លួន។

ក្រសួងផែនការជាស្ថាប័នទទួលបន្ទុកក្នុងការរៀបចំ និងធ្វើបច្ចុប្បន្នភាពបណ្ណសមធម៌ ដែលជាការកំណត់អត្តសញ្ញាណប្រជាជនក្រីក្រ ដែលត្រូវទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជំនួយសង្គម។ រីឯ ប.ជ.ស ប.ជ.អ ប.ស.ស និង ម.ជ.ព មានប្រព័ន្ធដោយឡែកដើម្បីគ្រប់គ្រង និងចុះបញ្ជីសមាជិករៀងៗខ្លួន។ ចំណែកឯការកំណត់អត្តសញ្ញាណ និងអត្រានុកូលដ្ឋានរបស់ប្រជាជនទូទៅវិញ គឺស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។

### ៥.៣.២ បញ្ហាប្រឈម

ការដាក់ឲ្យដំណើរការប្រព័ន្ធចុះបញ្ជីទៅតាមក្រុមប្រជាជនរៀងៗខ្លួន អាចនាំឲ្យមានការត្រួតស៊ីគ្នារវាងការកំណត់អត្តសញ្ញាណប្រជាជននីមួយៗ ដែលធ្វើឲ្យប្រជាជនមួយរូបអាចមានអត្តសញ្ញាណលើសពីមួយ។ កត្តានេះ នឹងជំរុញឲ្យមានគម្លាតកាន់តែធំលើភាពត្រឹមត្រូវនៃទិន្នន័យស្ដីពីប្រជាជនដែលផ្តល់ការលំបាកដល់ការកំណត់គោលនយោបាយគាំពារសង្គម និងគោលនយោបាយអភិវឌ្ឍន៍ផ្សេងទៀតឲ្យចំគោលដៅ និងមានប្រសិទ្ធភាព។ កត្តានេះ ក៏បង្កឲ្យមានការធ្វើការងារដដែលៗរបស់ស្ថាប័នផ្សេងៗគ្នាដែលអាចចាត់ទុកថាជាការខ្ជះខ្ជាយធនធាន។ មិនតែប៉ុណ្ណោះ ការដាក់ឲ្យដំណើរការប្រព័ន្ធចុះបញ្ជី និងធ្វើអត្តសញ្ញាណកម្មផ្សេងៗគ្នាបែបនេះ នឹងនាំឲ្យមានចំណាយធនធានថវិកាយ៉ាងច្រើនសន្ធឹកសន្ធាប់ផងដែរ។

### ៥.៣.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត

រាជរដ្ឋាភិបាលមានគោលដៅរៀបចំកែទម្រង់ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណកម្ម ឲ្យកាន់តែប្រសើរឡើងតាមរយៈការប្រើបច្ចេកវិទ្យាជីវមាត្រ (Biometric) ដើម្បីទប់ស្កាត់បញ្ហាទិន្នន័យស្ទួន។ តាមរយៈការដាក់ឲ្យប្រើប្រាស់ប្រព័ន្ធថ្មីនេះ ពលរដ្ឋមួយរូបអាចមានអត្តសញ្ញាណតែមួយប៉ុណ្ណោះ។

រាជរដ្ឋាភិបាលនឹងតភ្ជាប់ជាមួយប្រព័ន្ធអត្តសញ្ញាណកម្មថ្មីនេះជាមួយប្រព័ន្ធផ្សេងទៀត ដូចជាប្រព័ន្ធគ្រប់គ្រងបណ្ណសមធម៌របស់ក្រសួងផែនការ ព្រមទាំង ប្រព័ន្ធចុះបញ្ជីរបស់ប្រតិបត្តិករសន្តិសុខសង្គម ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងទិន្នន័យ និងការចែករំលែកទិន្នន័យរវាងស្ថាប័នមានសមត្ថកិច្ច ព្រមទាំងដើម្បីកាត់បន្ថយចំណាយជាអតិបរមា ក៏ដូចជា ការធ្វើការងារដដែលៗផងដែរ។

## ៥.៤ ការអប់រំ និងផ្សព្វផ្សាយ

### ៥.៤.១ ទិដ្ឋភាពទូទៅ

ការយល់ដឹងរបស់ប្រជាជនកម្ពុជាពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម នៅមិនទាន់មានលក្ខណៈទូលំទូលាយ និងច្បាស់លាស់នៅឡើយ។ ជាក់ស្តែង ប្រជាជនមួយចំនួនធំធ្លាប់បានទទួលអត្ថប្រយោជន៍ពីប្រព័ន្ធនេះរួចស្រេចទៅហើយ ជាពិសេស កម្មវិធីជំនួយសង្គមនានា ដែលរាជរដ្ឋាភិបាលបានអនុវត្តកន្លងមក ។

ចំណែក ការយល់ដឹងពាក់ព័ន្ធនឹងប្រព័ន្ធសន្តិសុខសង្គមកាន់តែមានកម្រិតថែមទៀត។ កន្លងមកប្រជាជនកម្ពុជា តែងបានទទួលដឹងឮអំពីការទទួលបានប្រាក់សោធនរបស់មន្ត្រីសាធារណៈ។ ប៉ុន្តែមិនមានប្រជាជនច្រើនទេ ដែលរំពឹងថាការបម្រើការងារនៅក្នុងវិស័យឯកជនក៏អាចទទួលបាននូវរបបប្រាក់សោធននោះដែរ។

ការយល់ដឹងអំពីប្រព័ន្ធនេះ ឃើញថាមានសន្ទុះកើនឡើងច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ តាមរយៈវត្តមានរបស់ ប.ជ.ស ប.ជ.អ ប.ស.ស និង ម.ជ.ព។ ស្ថាប័នទាំងនេះ បានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន តាមរយៈការបំពេញមុខងាររបស់ខ្លួនដោយអនុវត្តផ្ទាល់ និងការអនុវត្តកម្មវិធីផ្សព្វផ្សាយនានាទៅដល់សមាជិករៀងៗខ្លួន។

### ៥.៤.២ បញ្ហាប្រឈម

កម្រិតទាបនៃការអភិវឌ្ឍប្រព័ន្ធនេះ គឺជាកត្តាចម្បង ដែលនាំឲ្យមិនមានការយល់ដឹងច្រើនពីសំណាក់សាធារណជនទូទៅ។ ការអនុវត្តកម្មវិធីផ្សព្វផ្សាយគោលនយោបាយនានា ដែលពាក់ព័ន្ធនឹងប្រព័ន្ធនេះ ក៏នៅមានកម្រិត។

ម្យ៉ាងវិញទៀត ចំណេះដឹងពាក់ព័ន្ធនឹងប្រព័ន្ធនេះក៏មិនទាន់ត្រូវបានចែករំលែកឲ្យបានច្រើននៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅរបស់ក្រសួងអប់រំ យុវជន និងកីឡានៅឡើយ។

### ៥.៤.៣ យុទ្ធសាស្ត្រ និងគោលដៅអនាគត

ដើម្បីលើកកម្ពស់ចំណេះដឹងពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គមនៅកម្ពុជា រាជរដ្ឋាភិបាលនឹងប្រើប្រាស់វិធីសាស្ត្រពីរគឺ៖ (១) ការអប់រំដោយផ្ទាល់ និង (២) ការអប់រំដោយប្រយោល។

#### ៥.៤.៣.១ ការលើកកម្ពស់ចំណេះដឹងដោយផ្ទាល់

វិធីសាស្ត្រនេះ គឺការលើកកម្ពស់ចំណេះដឹងតាមរយៈការអប់រំ និងផ្សព្វផ្សាយដោយផ្ទាល់អំពីគោលនយោបាយ ឬកម្មវិធីជាក់លាក់នៃប្រព័ន្ធគាំពារសង្គម។ ទាំងស្ថាប័នបញ្ញត្តិករ និងប្រតិបត្តិករ ត្រូវសហការគ្នារៀបចំបង្កើតកម្មវិធីផ្សព្វផ្សាយចំណេះដឹងជូនសាធារណជនឲ្យបានកាន់តែច្រើន និងគ្រប់ទីកន្លែង ធ្វើយ៉ាងណាឲ្យប្រជាជនគ្រប់រូបយល់ច្បាស់អំពីសិទ្ធិជាមូលដ្ឋានរបស់ខ្លួនក្នុងការទទួលបានអត្ថប្រយោជន៍ ព្រមទាំង កាតព្វកិច្ចរបស់ខ្លួនក្នុងការចូលរួមក្នុងប្រព័ន្ធនេះផងដែរ។

### ៥.៤.៣.២ ការលើកកម្ពស់ចំណេះដឹងដោយប្រយោល

រាជរដ្ឋាភិបាលនឹងសិក្សាលើលទ្ធភាព ក្នុងការដាក់បញ្ចូលមូលដ្ឋានគ្រឹះនៃសិក្សាធិការហិរញ្ញវត្ថុ (financial literacy) ទៅក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ទៅតាមកម្រិតនៃថ្នាក់សិក្សានីមួយៗ ដើម្បីបញ្ជ្រាបជាបណ្ដើរៗនូវផ្នត់គំនិត និងការយល់ដឹងរបស់កុមារកម្ពុជាពាក់ព័ន្ធនឹងការរៀបចំផែនការហិរញ្ញវត្ថុផ្ទាល់ខ្លួន។

គោលដៅនេះ មិនត្រឹមតែធ្វើឡើងដើម្បីលើកកម្ពស់ចំណេះដឹងពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គមតែមួយប៉ុណ្ណោះទេ គឺដើម្បីលើកកម្ពស់ចំណេះដឹងមូលដ្ឋានអំពីប្រព័ន្ធហិរញ្ញវត្ថុទាំងមូល ព្រោះថាសិក្សាធិការហិរញ្ញវត្ថុ នឹងគ្របដណ្ដប់ទាំងការប្រើប្រាស់សេវារបស់គ្រឹះស្ថានធនាគារ សេវាធានារ៉ាប់រង ប្រតិបត្តិការមូលបត្រ និងប្រតិបត្តិការហិរញ្ញវត្ថុដទៃទៀតផងដែរ។

# ◆ ជំពូកទី៦

# ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ២០១៦-២០២៥

## ជំពូកទី ៦
## ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ២០១៦-២០២៥

| គោលនយោបាយ | រយៈពេលខ្លី (២០១៦-២០១៨) | រយៈពេលមធ្យម (២០១៨-២០២០) | រយៈពេលវែង (២០២០-២០២៥) | ស្ថាប័នអនុវត្ត |
|---|---|---|---|---|
| **១. ប្រព័ន្ធជំនួយសង្គម** | | | | |
| ១.១ ការឆ្លើយតបនឹងគ្រោះអាសន្ន | | | | |
| *កម្មវិធីសន្តិសុខស្បៀង* | • បន្តពង្រឹងសមត្ថភាពប្រព័ន្ធស្បៀងបម្រុងជាតិ<br>• ពិនិត្យ និងវាយតម្លៃការអនុវត្ត | • បន្តពង្រឹងសមត្ថភាពប្រព័ន្ធស្បៀងបម្រុងជាតិ<br>• ពិនិត្យ និងវាយតម្លៃការអនុវត្ត | • បន្តពង្រឹងសមត្ថភាពប្រព័ន្ធស្បៀងបម្រុងជាតិ<br>• ពិនិត្យ និងវាយតម្លៃការអនុវត្ត | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ១.២ ការអភិវឌ្ឍមូលធនមនុស្ស | | | | |
| *កម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ៥ ឆ្នាំ* | • សិក្សា និងវាយតម្លៃ អំពីម៉ូដែលនៃការដាក់ឲ្យអនុវត្តកម្មវិធីលើកកម្ពស់អាហារូបត្ថម្ភ រួមបញ្ចូលទាំងការអនុវត្តសាកល្បង ដើម្បីកំណត់អំពីម៉ូដែលណាមួយ ដែលមានប្រសិទ្ធភាព និងសមស្របសម្រាប់កម្ពុជា<br>• កំណត់អំពីស្ថាប័នអនុវត្ត និងកំណត់ឲ្យបានច្បាស់អំពីតួនាទី និងភារកិច្ច<br>• ធ្វើការកំណត់អំពីខេត្តគោលដៅដែលត្រូវដាក់ឲ្យអនុវត្តមុន ដោយផ្អែកលើភាពងាយរងគ្រោះនិងតម្រូវការ<br>• រៀបចំយន្តការការងារ និងការកសាងសមត្ថភាព | • ពង្រីកវិសាលភាពគ្របដណ្តប់ថ្នាក់ជាតិ ព្រមទាំងធ្វើការកែសម្រួលឲ្យកាន់តែមានប្រសិទ្ធភាព និងសក្តិសិទ្ធិភាព<br>• ពង្រីកការអនុវត្តគ្របដណ្តប់ថ្នាក់ជាតិដោយពឹងផ្អែកលើការវិភាគអំពីតម្រូវការនិងគោលដៅអាទិភាពលើតំបន់ភូមិសាស្ត្រ ប្រជាសាស្ត្រ សេដ្ឋកិច្ចសង្គម និងកត្តាសមធម៌ដទៃទៀត<br>• ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត | • ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្ត<br>• ធ្វើការកែសម្រួលដើម្បីធានាឲ្យបាននូវប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។ | ប្រតិបត្តិករជំនួយសង្គម |

| | | | | |
|---|---|---|---|---|
| | • បង្កើតយន្តការពិនិត្យតាមដាននិងវាយតម្លៃដើម្បីវាស់ស្ទង់វឌ្ឍនភាព និងសិក្សាលើផលប៉ះពាល់ជាមួយនឹងការសម្រេចចិត្តប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា<br>• ដាក់ឲ្យអនុវត្តកម្មវិធីលើកកម្ពស់អាហារូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ៥ ឆ្នាំ នៅក្នុងខេត្តអាទិភាព<br>• សិក្សាលើយន្តការផ្តល់ការពិនិត្យផ្ទៃពោះ | | | |
| *កម្មវិធីផ្តល់អាហារនៅតាមសាលារៀន* | • សិក្សា និងរៀបចំដាក់ឲ្យដំណើរការសាកល្បងកម្មវិធីអាហារដែលដាំនៅផ្ទះ<br>• អភិវឌ្ឍសមត្ថភាពស្ថាប័ន រួមទាំងអ្នកធ្វើការងារសង្គម<br>• រៀបចំគោលនយោបាយជាតិស្តីពីការផ្តល់អាហារនៅតាមសាលារៀន<br>• សិក្សាលើទិដ្ឋភាពគ្រប់គ្រង និងហិរញ្ញវត្ថុ នៃកម្មវិធីនេះ | • ផ្អែកលើលទ្ធផលនៃការសិក្សាពិនិត្យរៀបចំការដាក់ឲ្យដំណើរការកម្មវិធីអាហារដាំនៅផ្ទះ<br>• រៀបចំក្របខ័ណ្ឌស្ថាប័ន និងធនធានមនុស្សដើម្បីគ្រប់គ្រង និងចាត់ចែង កម្មវិធីនេះទាំងស្រុងដោយរដ្ឋ<br>• សិក្សាអំពីប្រសិទ្ធភាព និងសក្តិសិទ្ធិភាពនៃការអនុវត្តកម្មវិធី | • សិក្សាអំពីលទ្ធភាពក្នុងការពង្រីកវិសាលភាពសម្រាប់ថ្នាក់មត្តេយ្យសិក្សា និងថ្នាក់មធ្យមសិក្សាបឋមភូមិ | ក្រសួងអប់រំ យុវជន និងកីឡា |
| *កម្មវិធីអាហារូបករណ៍កម្រិតបឋមសិក្សា* | • បន្តពង្រឹងការអនុវត្តកម្មវិធីដែលមានស្រាប់<br>• ពិនិត្យឡើងវិញនូវលក្ខណៈវិនិច្ឆ័យដើម្បីទទួលបានអត្ថប្រយោជន៍<br>• រៀបចំប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃឲ្យស្របគ្នាជាមួយកម្មវិធីអាហារូបករណ៍ថ្នាក់មធ្យមសិក្សា និងប្រព័ន្ធអេឡិចត្រូនិកសម្រាប់ការចុះវត្តមាន | • សិក្សាអំពីលទ្ធភាពក្នុងការពង្រីកវិសាលភាពគ្របដណ្តប់ទូទាំងប្រទេសលើកម្មវិធីដែលមានស្រាប់<br>• សិក្សាអំពីលទ្ធភាពក្នុងការពង្រីកវិសាលភាពគ្របដណ្តប់ពីថ្នាក់ទី១-៦ | • សិក្សាអំពីលទ្ធភាពក្នុងការពង្រីកកម្រិតអត្ថប្រយោជន៍សម្រាប់អាហារូបករណ៍ពីថ្នាក់ទី១-៦ | ក្រសួងអប់រំ យុវជន និងកីឡា |

| | | | | |
|---|---|---|---|---|
| | • សិក្សាបង្កើតយន្តការផ្តល់អាហារូបករណ៍សម្រាប់ថ្នាក់បឋមសិក្សាតាមរយៈគណនីធនាគារដោយពឹងផ្អែកលើការវិភាគតម្លៃនិងអត្ថប្រយោជន៍ | • រៀបចំការវិភាគលើការពង្រីកកម្រិតអត្ថប្រយោជន៍អាហារូប-ករណ៍ ដើម្បីធានាការចុះឈ្មោះចូលរៀនបានទាន់ពេលវេលា និងវត្តមាន។ | | |
| *កម្មវិធីអាហារូបករណ៍កម្រិតមធ្យមសិក្សា* | • បន្តពង្រឹងការអនុវត្តកម្មវិធីដែលមានស្រាប់<br>• ធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាព និងសក្តិសិទ្ធិភាពក្នុងការអនុវត្ត (យន្តការផ្តល់អាហារូបករណ៍តាមរយៈធនាគារ និងយន្តការសម្រាប់កំណត់អត្តសញ្ញាណអ្នកទទួលអត្ថប្រយោជន៍ ។ល។)<br>• រៀបចំគោលនយោបាយថ្នាក់ជាតិស្តីពីការអប់រំមូលដ្ឋាន | • សិក្សាអំពីលទ្ធភាពក្នុងការពង្រីកវិសាលភាពនៃការគ្របដណ្តប់ពីថ្នាក់ទី៧-១២<br>• ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត | • សិក្សាអំពីលទ្ធភាពក្នុងការពង្រីកកម្រិតអត្ថប្រយោជន៍<br>• ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត | ក្រសួងអប់រំ យុវជន និងកីឡា |
| **១.៣ ការបណ្តុះបណ្តាលវិជ្ជាជីវៈ** | | | | |
| *ការបណ្តុះបណ្តាលវិជ្ជាជីវៈ* | • រៀបចំគោលនយោបាយជាតិស្តីពី ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (Technical Vocational Education and Training:TVET) សម្រាប់បង្កើនលទ្ធភាព និងសមធម៌ក្នុងការទទួលបានសេវាTVET ដើម្បីបង្កើតការងារ និងកាត់បន្ថយភាពក្រីក្រ<br>• បន្ត និងសិក្សាលើការពង្រីកវិសាលភាពការបណ្តុះបណ្តាលវិជ្ជាជីវៈដោយផ្តោតលើការពង្រីកកម្មវិធីស្ពានចម្លងបន្តជំនាញសម្រាប់យុវជនក្រៅសាលា | • ពិនិត្យនិងតាមដានការអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ការបណ្តុះបណ្តាលវិញ្ញាបនបត្រកម្រិត១-៣ ដល់ជនក្រីក្រ និងស្ត្រីក្នុងវិស័យអាទិភាព | • បន្តអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ការបណ្តុះបណ្តាលវិញ្ញាបនបត្រកម្រិត១-៣ ដល់ជនក្រីក្រ និងស្ត្រីក្នុងវិស័យអាទិភាព | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | | | | |
|---|---|---|---|---|
| | • បណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់សម្រាប់ប្រជាជនក្រីក្រតាមជនបទ<br>• សិក្សាការដាក់ឲ្យអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ការបណ្តុះបណ្តាលវិញ្ញាបនបត្រជំនាញកម្រិត ១-៣ ដល់ជនក្រីក្រ និងស្ត្រីក្នុងវិស័យអាទិភាព | | | |
| ១.៤ សុខុមាលភាពសម្រាប់ប្រជាជនងាយរងគ្រោះ | | | | |
| *កម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនពិការ* | • រៀបចំសេចក្តីណែនាំសម្រាប់ការអនុវត្តអនុក្រឹត្យស្តីពីប្រាក់ឧបត្ថម្ភសម្រាប់ជនពិការ<br>• រៀបចំរចនាសម្ព័ន្ធស្ថាប័នដើម្បីគ្រប់គ្រង និងចាត់ចែងកម្មវិធីនេះឲ្យមានប្រសិទ្ធភាពខ្ពស់<br>• អនុវត្តអនុក្រឹត្យស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ជនពិការនៅក្នុងខេត្តគោលដៅ<br>• ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្ត និងលទ្ធផលនៅក្នុងខេត្តគោលដៅ | • សិក្សាអំពីលទ្ធភាពក្នុងការពង្រីកវិសាលភាពនៃការអនុវត្តទៅកាន់ខេត្តផ្សេងៗទៀត | • ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត និងលទ្ធផល<br>• ធ្វើការកែសម្រួលដើម្បីការអនុវត្តប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាព | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| *កម្មវិធីគាំពារជនចាស់ជរា* | • កំណត់លក្ខណៈវិនិច្ឆ័យអ្នកទទួលផល និងកម្រិតអត្ថប្រយោជន៍<br>• សិក្សាពីលទ្ធភាពសម្រាប់កំណត់អត្តសញ្ញាណអ្នកទទួលផល និងស្ថាប័នអនុវត្ត<br>• រៀបចំនិងអភិវឌ្ឍសមត្ថភាពស្ថាប័ន<br>• កំណត់ខេត្តគោលដៅ<br>• សិក្សាការដាក់ឲ្យដំណើរការកម្មវិធីនេះ ដាក់ភ្ជាប់គ្រួសាររួមជាមួយកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ និងកុមារ | • សិក្សាការដាក់ឲ្យអនុវត្តកម្មវិធីគាំពារជនចាស់ជរានៅក្នុងខេត្តអាទិភាព<br>• ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្ត និងលទ្ធផល<br>• រៀបចំផែនការដើម្បីពង្រីកវិសាលភាព ក្នុងការគ្របដណ្តប់ទូទាំងប្រទេស | • ដាក់ឲ្យអនុវត្តកម្មវិធីទូទាំងប្រទេស<br>• ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

| | | | | |
|---|---|---|---|---|
| ១.៥ ហិរញ្ញប្បទាន | | | | |
| *ហិរញ្ញវត្ថុសម្រាប់ទ្រទ្រង់* | • បំពេញសេណារីយ៉ូចំណាយសម្រាប់ធាតុនីមួយៗនៃកម្មវិធីជំនួយសង្គម ដើម្បីពង្រីកកម្មវិធីអាទិភាព រួមបញ្ចូលទាំងចំណាយរដ្ឋបាល<br>• សិក្សាពីលំហថវិកាដែលទាក់ទងនឹងធនធានសាធារណៈ<br>• បង្កើតផែនការហិរញ្ញវត្ថុរយៈពេលវែង រួមបញ្ចូលទាំងការកៀរគរប្រភពធនធាន (ការបែងចែកកម្លាំងពលកម្ម រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍) | • សិក្សា និងវាយតម្លៃផែនការកៀរគរធនធានរយៈពេលវែងសម្រាប់ការគ្របដណ្តប់ជាសកលនៃកម្មវិធីជំនួយសង្គម ដើម្បីពង្រឹងប្រសិទ្ធភាព និងសក្តិសិទ្ធិភាព<br>• ការវាយតម្លៃពីលទ្ធផលនៃការអន្តរាគមផ្នែកជំនួយសង្គមសម្រាប់ការវិភាគលើចំណាយ និងលទ្ធផលដែលទទួលបាន<br>• ការបង្កើនភាពជាម្ចាស់របស់រាជរដ្ឋាភិបាលទៅលើផ្នែកបច្ចេកវិទ្យា និងហិរញ្ញវត្ថុ | • បន្តធ្វើការវិភាគលើចំណាយ និងលទ្ធផលដែលទទួលបាន<br>• រាល់ធាតុទាំងអស់របស់កម្មវិធីជំនួយសង្គមត្រូវបានទ្រទ្រង់ផ្នែកហិរញ្ញវត្ថុដោយរាជរដ្ឋាភិបាល | • ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **២. ប្រព័ន្ធសន្តិសុខសង្គម** | | | | |
| ២.១ សោធន | | | | |
| *យន្តការបណ្តោះអាសន្នដើម្បីកាត់បន្ថយគម្លាតនៃរបបសោធនរបស់មន្ត្រីសាធារណៈ* | • រៀបចំសេចក្តីសម្រេច/ណែនាំ ដើម្បីបញ្ជាក់ឡើងវិញអំពីការកំណត់របបប្រាក់សោធនសម្រាប់មន្ត្រីនគរបាលជាតិ និងយោធិននៃកងយោធពលខេមរភូមិន្ទ | | | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| *របបសោធនសម្រាប់មន្ត្រីសាធារណៈ* | • កែសម្រួលព្រះរាជក្រឹត្យស្តីពីការបង្កើត ប.ជ.ស និង ប.ជ.អ ដើម្បីធ្វើឯកភាពរូបនីយកម្ម ប.ជ.ស និង ប.ជ.អ ឲ្យទៅជាស្ថាប័នតែមួយ និងពង្រីកវិសាលភាពឲ្យគ្របដណ្តប់មន្ត្រីសាធារណៈផ្សេង | • រៀបចំយន្តការវិនិយោគមូលនិធិ<br>• សិក្សាវាយតម្លៃអំពីហានិភ័យ | • សិក្សាវាយតម្លៃអំពីហានិភ័យ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

| | | | | |
|---|---|---|---|---|
| | ទៀត ទាំងក្រុមនីតិបញ្ញត្តិ ស្ថាប័នតុលាការ និងស្ថាប័នរដ្ឋផ្សេងទៀត<br>• ពិនិត្យឡើងវិញលើអត្រាភាគទាន សម្រាប់របបសោធនសម្រាប់មន្ត្រីសាធារណៈទាំងអស់<br>• ផ្លាស់ប្តូរពីប្រព័ន្ធមិនបង់ភាគទាន ទៅជាប្រព័ន្ធបង់ភាគទាន | | | • ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| *ប្រព័ន្ធចាកចេញពីការងារដោយស្ម័គ្រចិត្តសម្រាប់មន្ត្រីរាជការ* | • រៀបចំដាក់ឲ្យដំណើរការប្រព័ន្ធចាកចេញពីការងារដោយស្ម័គ្រចិត្ត<br>• សិក្សាអំពីលក្ខខណ្ឌ និងការផ្តល់អត្ថប្រយោជន៍ពីប្រព័ន្ធសន្តិសុខសង្គម | • ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត | • ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត | • ក្រសួងមុខងារសាធារណៈ |
| *របបសោធនសម្រាប់កម្មករនិយោជិត* | • សិក្សាអំពីលទ្ធភាពក្នុងការដាក់ឲ្យដំណើរការរបបសោធនកាតព្វកិច្ចសម្រាប់កម្មករនិយោជិត | • ដាក់ឲ្យដំណើរការរបបសោធនកាតព្វកិច្ចសម្រាប់កម្មករនិយោជិត | • សិក្សាវាយតម្លៃអំពីហានិភ័យ | • ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| *របបសោធនសម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ* | • សិក្សាអំពីលទ្ធភាពក្នុងការដាក់ឲ្យដំណើរការរបបសោធនសម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅក្រោមយន្តការដែលមានស្រាប់ ពោលគឺ ប.ជ.ស ឬ ប.ស.ស ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រង និងចំណាយថវិកា | • ដាក់ឲ្យដំណើរការរបបសោធនសម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាលក្ខណៈស្ម័គ្រចិត្ត | • ពិនិត្យលទ្ធភាពក្នុងការបង្វែររបបសោធនសម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធឲ្យទៅជារបបសោធនកាតព្វកិច្ច | • ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>• ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| *ប្រភេទនៃរបបសោធនកាតព្វកិច្ច* | • សិក្សាអំពីប្រភេទនៃរបបសោធន ដែលសមស្របទៅនឹងបរិបទរបស់កម្ពុជា ដោយផ្តោតលើលទ្ធភាព | • រៀបចំផែនការ និងកាលវិភាគដាក់លាក់សម្រាប់ដំណើរការ | • ជំរុញការអនុវត្តទៅតាមផែនការ និងកាលវិភាគដែលបានកំណត់ | • ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

| | | | | |
|---|---|---|---|---|
| | នៃការទ្រទ្រង់របស់ថវិកាជាតិ និងនិរន្តរភាពផ្នែកហិរញ្ញវត្ថុនៃរបបសោធននីមួយៗ | អនុវត្តដោយផ្អែកលើលទ្ធផលនៃការសិក្សា | | • ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| *របបសោធនឯកជនស្ម័គ្រចិត្ត* | • រៀបចំបទប្បញ្ញត្តិដើម្បីអនុញ្ញាតឲ្យដំណើរការរបបសោធនឯកជនស្ម័គ្រចិត្តដែលគ្រប់គ្រងដោយស្ថាប័នហិរញ្ញវត្ថុ | • ផ្តល់អាជ្ញាបណ្ណដល់ស្ថាប័នហិរញ្ញវត្ថុ ដើម្បីដាក់ឲ្យដំណើរការរបបសោធនឯកជនស្ម័គ្រចិត្ត | • គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារសោធនឯកជនស្ម័គ្រចិត្ត | • ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ២.២ ការថែទាំសុខភាព | | | | |
| *របបថែទាំសុខភាពសម្រាប់កម្មករនិយោជិត* | • រៀបចំបទប្បញ្ញត្តិពាក់ព័ន្ធដើម្បីដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់កម្មករនិយោជិត | • ពង្រីកវិសាលភាពរបបថែទាំសុខភាពទៅដល់អ្នកនៅក្នុងបន្ទុករបស់កម្មករនិយោជិត | • ពិនិត្យ និងវាយតម្លៃការអនុវត្ត | • ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| *របបថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ* | • សិក្សាអំពីលទ្ធភាពក្នុងការដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ<br>• រៀបចំបទប្បញ្ញត្តិពាក់ព័ន្ធដើម្បីដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ | • ពង្រីកវិសាលភាពរបបថែទាំសុខភាពទៅដល់អ្នកនៅក្នុងបន្ទុករបស់មន្ត្រីសាធារណៈ | • ពិនិត្យ និងវាយតម្លៃការអនុវត្ត | • ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ក្រសួងសុខាភិបាល |
| *របបថែទាំសុខភាពសម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ* | • សិក្សាអំពីលទ្ធភាពក្នុងការគ្រប់គ្រងមូលនិធិសមធម៌សុខភាព និងមូលនិធិគន្ធបុប្ផា<br>• សិក្សាអំពីលទ្ធភាពក្នុងការពង្រីកវិសាលភាពនៃមូលនិធិសមធម៌ ឲ្យគ្របដណ្តប់ប្រជាជនដែល | • រៀបចំបទប្បញ្ញត្តិដើម្បីដាក់ឲ្យការគ្រប់គ្រងមូលនិធិសមធម៌ និងមូលនិធិគន្ធបុប្ផា ស្ថិតនៅ | • ដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលមិនមានបណ្ណ | • ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | | | | |
|---|---|---|---|---|
| | ងាយរងគ្រោះផ្សេងទៀត ដូចជា៖ កុមារអាយុក្រោម ៥ ឆ្នាំ ចាស់ជរា និងជនពិការ ជាដើម ។ | ក្រោមប្រព័ន្ធថែទាំសុខភាពសង្គមរួម<br>• សិក្សាអំពីលទ្ធភាពក្នុងការដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់ប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលមិនមានបណ្ណសមធម៌ | សមធម៌ ជាលក្ខណៈស្ម័គ្រចិត្ត<br>• សិក្សាអំពីលទ្ធភាពក្នុងការបង្វែររបបស្ម័គ្រចិត្តនេះទៅជារបបកាតព្វកិច្ច | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ក្រសួងសុខាភិបាល |
| *ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ* | • ពង្រឹងយន្តការលើកកម្ពស់គុណភាពសេវា ដើម្បីឈានជំហានៗឆ្ពោះទៅរកការដាក់ឲ្យដំណើរការប្រព័ន្ធទទួលស្គាល់គុណភាព (Accreditation System)<br>• បង្កើនការវិនិយោគសាធារណៈលើហេដ្ឋារចនា-សម្ព័ន្ធសុខាភិបាល ដោយរាប់បញ្ចូលទាំងធនធានមនុស្ស<br>• រៀបចំយន្តការដើម្បីលើកកម្ពស់ការយល់ដឹងអំពីការថែទាំ និងការការពារសុខភាព<br>• សិក្សាអំពីលទ្ធភាពក្នុងការដាក់ឲ្យមានការធានារ៉ាប់រងបន្ថ | • សិក្សាអំពីលទ្ធភាពក្នុងការបង្កើតយន្តការត្រួតពិនិត្យឯករាជ្យលើការទូទាត់សេវាសុខាភិបាល<br>• ការបង្កើនការចូលរួមពីមូលដ្ឋានសុខាភិបាលឯកជន តាមរយៈការកែសម្រួលកញ្ចប់តាវកាលិកនៃរបបថែទាំសុខភាពសង្គមនីមួយៗ | • សិក្សាអំពីលទ្ធភាពក្នុងការដាក់ឲ្យអនុវត្តកញ្ចប់តាវកាលិករួមសម្រាប់គ្រប់របបថែទាំសុខភាពសង្គមទាំងអស់ | • ក្រសួងសុខាភិបាល<br>• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **២.៣ ហានិភ័យការងារ** | | | | |
| *របបហានិភ័យការងារសម្រាប់កម្មករនិយោជិត* | • កែសម្រួលលិខិតបទដ្ឋានគតិយុត្តិ ដើម្បីអនុញ្ញាតឲ្យកូនក្នុងបន្ទុកទទួលបានអត្ថប្រយោជន៍ពីរបបនេះ ទោះបីឪពុកឬម្តាយដែលជាសមាជិករបស់ ប.ស.ស ពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ ហើយទទួលរងគ្រោះថ្នាក់ការងាររហូតដល់បាត់បង់ជីវិត និង ដើម្បី | • ការតាមដាននិងវាយតម្លៃការអនុវត្ត | • ការតាមដាននិងវាយតម្លៃការអនុវត្ត | • ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | | | | |
|---|---|---|---|---|
| | អនុញ្ញាតឲ្យកូនពិការដែលពុំមានលទ្ធភាពរកប្រាក់ចំណូល ទទួលបានអត្ថប្រយោជន៍ពី ប.ស.ស រហូតអស់មួយជីវិត ។ | | | |
| *របបហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ* | • សិក្សារៀបចំឲ្យមានគោលការណ៍ និងស្តង់ដារច្បាស់លាស់សម្រាប់ការជួយទ្រទ្រង់ដល់មន្ត្រីសាធារណៈដែលរងគ្រោះដោយសារហានិភ័យការងារ ។ | • ដាក់ឲ្យដំណើរការរបបហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ ដោយផ្អែកលើទិដ្ឋភាពនៃថវិកាជាតិ | • ការតាមដាននិងវាយតម្លៃការអនុវត្ត | • ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **២.៤ និកម្មភាព** | | | | |
| *របបនិកម្មភាព* | • សិក្សាសមិទ្ធិលទ្ធភាពដើម្បីដាក់ឲ្យដំណើរការរបបនិកម្មភាព<br>• កសាងសមត្ថភាពមន្ត្រីជំនាញ | • ដាក់ឲ្យដំណើរការរបបនិកម្មភាពទៅតាមលទ្ធភាពដែលអាចធ្វើបាន | • ការតាមដាននិងវាយតម្លៃការអនុវត្ត | • ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **២.៣ ពិការភាព** | | | | |
| *ការកំណត់អត្តសញ្ញាណនិងលក្ខខណ្ឌសម្រាប់ការទទួលបានអត្ថប្រយោជន៍* | • រៀបចំយន្តការកំណត់អត្តសញ្ញាណជនពិការឲ្យបានគ្រប់ៗគ្នា ទៅតាមក្រុមនីមួយៗ ដើម្បីជាមូលដ្ឋានក្នុងការកំណត់កញ្ចប់អត្ថប្រយោជន៍ទៅតាមតម្រូវការជាក់ស្តែង ប្រកបដោយសមធម៌ | • ការតាមដាននិងវាយតម្លៃការអនុវត្ត | • ការតាមដាននិងវាយតម្លៃការអនុវត្ត | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| *ការស្តារលទ្ធភាពពលកម្ម* | • បង្កើនការវិនិយោគបន្ថែមលើសមត្ថភាពមន្ត្រីជំនាញ និងឧបករណ៍បច្ចេកទេស | • បន្តពង្រឹងគុណភាពនៃការស្តារលទ្ធភាពពលកម្ម | • បន្តពង្រឹងគុណភាពនៃការស្តារលទ្ធភាពពលកម្ម | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | | | | |
|---|---|---|---|---|
| *ការបណ្តុះបណ្តាលវិជ្ជាជីវៈ* | • រៀបចំកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងការរកការងារធ្វើជូនជនពិការ | • បន្តពង្រឹងការរៀបចំកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងការរកការងារធ្វើជូនជនពិការ | • បន្តពង្រឹងការរៀបចំកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងការរកការងារធ្វើជូនជនពិការ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>• ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **៣. អភិបាលកិច្ច** | | | | |
| *កម្រិតគោលនយោបាយ* | • រៀបចំបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម និងអគ្គលេខាធិការដ្ឋាន ដើម្បីដំណើរការការងារ | • ពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ | • ពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ | • គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| *កម្រិតបញ្ញត្តិករ* | • បង្កើតអង្គភាពថ្មីមួយក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីដើរតួជាបញ្ញត្តិករសន្តិសុខសង្គម | • ពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ | • ពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ | • ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| *កម្រិតប្រតិបត្តិករ* | • រៀបចំ ធ្វើសមាហរណកម្មស្ថាប័នប្រតិបត្តិកររបបសន្តិសុខសង្គមទាំងអស់ ពោលគឺ ប.ជ.ស ប.ជ.អ ប.ស.ស និង ម.ជ.ព ឲ្យទៅជាស្ថាប័នតែមួយ ។<br>• សិក្សាលើការរៀបចំយន្តការធ្វើសម្បទានឆ្លង រវាងរបបធានារ៉ាប់រងនីមួយៗ<br>• សិក្សាអំពីលទ្ធភាពក្នុងការបង្កើតស្ថាប័នប្រតិបត្តិករ ដើម្បីគ្រប់គ្រង និងចាត់ចែងមូលនិធិជំនួយសង្គមរួមមួយ | • ពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ | • ពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ | • គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| *ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ* | • រៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម ដោយកំណត់អំពីរចនាសម្ព័ន្ធគ្រប់គ្រងនៃប្រព័ន្ធគាំពារសង្គមទាំងមូល មុខងារ និងភារកិច្ចនៃស្ថាប័នពាក់ព័ន្ធទាំងអស់ យន្តការតាមដាន និងត្រួតពិនិត្យ | • រៀបចំលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ | • រៀបចំលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ | • គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ |

| | | | | |
|---|---|---|---|---|
| | ព្រមទាំង ដំណើរការនៃរបបសន្តិសុខសង្គមនីមួយៗ រួមទាំង កម្មវិធីជំនួយសង្គមផងដែរ | | | |
| **៤. បញ្ហាឆ្លងវិស័យ** | | | | |
| *ការវិនិយោគ* | • បញ្ចប់ការរៀបចំបទប្បញ្ញត្តិសម្រាប់ការបោះផ្សាយមូលបត្ររដ្ឋ និងសញ្ញាបណ្ណសាជីវកម្ម | • រៀបចំប្រព័ន្ធព័ត៌មានវិទ្យាចាំបាច់ដើម្បីត្រៀមខ្លួនចាប់ផ្តើមបោះផ្សាយមូលបត្ររដ្ឋ | • ចាប់ផ្តើមបោះផ្សាយមូលបត្ររដ្ឋ | • ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>• គ.ម.ក |
| *គោលនយោបាយពន្ធដារ* | • សិក្សាអំពីគម្លាតបទប្បញ្ញត្តិដែលនៅសេសសល់ពាក់ព័ន្ធនឹងគោលនយោបាយពន្ធដារសម្រាប់ប្រតិបត្តិការប្រព័ន្ធគាំពារសង្គម<br>• សិក្សាអំពីលទ្ធភាពក្នុងការផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារដើម្បីជំរុញការធ្វើវិភាគទានសប្បុរសធម៌ទៅក្នុងមូលនិធិជំនួយសង្គម | • រៀបចំបទប្បញ្ញត្តិចាំបាច់នានាដើម្បីដាក់ឲ្យអនុវត្តពេញលេញនូវគោលនយោបាយពន្ធដារពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម | • ពិនិត្យ និងតាមដាន ឬកែសម្រួលតាមការចាំបាច់ | • ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| *ប្រព័ន្ធចុះបញ្ជី* | • សិក្សាអំពីលទ្ធភាពក្នុងការតភ្ជាប់ប្រព័ន្ធអត្ត-សញ្ញាណកម្មប្រជាជនទូទៅ ជាមួយប្រព័ន្ធបណ្ណសមធម៌ និងប្រព័ន្ធចុះបញ្ជីសមាជិករបស់ប្រតិបត្តិករសន្តិសុខសង្គម | • ដាក់ឲ្យអនុវត្តសាកល្បងនូវការតភ្ជាប់ប្រព័ន្ធទាំងអស់ | • ដាក់ឲ្យអនុវត្តការតភ្ជាប់ពេញលេញ | • ក្រសួងមហាផ្ទៃ<br>• ក្រសួងផែនការ<br>• ប្រតិបត្តិករសន្តិសុខសង្គម<br>• ប្រតិបត្តិករជំនួយសង្គម |
| *ការអប់រំ* | • រៀបចំកម្មវិធីលើកកម្ពស់ចំណេះដឹងសាធារណជនស្តីពីគោលនយោបាយនានាពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម | • បន្តរៀបចំកម្មវិធីលើកកម្ពស់ចំណេះដឹងសាធារណជនស្តីពីគោលនយោបាយនានាពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម | • បន្តរៀបចំកម្មវិធីលើកកម្ពស់ចំណេះដឹងសាធារណជនស្តីពីគោលនយោបាយនានាពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម | • ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>• ក្រសួងអប់រំ យុវជន និងកីឡា<br>• ក.ក.ជ |

| | | | | |
|---|---|---|---|---|
| | • សិក្សាអំពីលទ្ធភាពក្នុងការដាក់បញ្ចូលមូលដ្ឋានគ្រឹះនៃសិក្សាធិការហិរញ្ញវត្ថុក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា | • ដាក់បញ្ចូលមូលដ្ឋានគ្រឹះនៃសិក្សាធិការហិរញ្ញវត្ថុក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា | • ពិនិត្យ និងតាមដានការអនុវត្ត ព្រមទាំង ធ្វើការកែសម្រួលតាមតម្រូវការជាក់ស្តែង | • ប្រតិបត្តិករសន្តិសុខសង្គម<br>• ប្រតិបត្តិករជំនួយសង្គម |

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ១

## សទ្ទានុក្រម

| | | |
|---|---|---|
| ១ | កញ្ចប់តាវកាលិករួម (Uniform Benefit Package) | សំដៅដល់កញ្ចប់អត្ថប្រយោជន៍រួម ឬតែមួយ ដែលរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព ផ្តល់ជូនប្រជាជនគ្រប់រូប ទាំងវិស័យ សេដ្ឋកិច្ចក្នុង និងក្រៅប្រព័ន្ធ។ |
| ២ | កត្តាប្រជាសាស្ត្រ (Demography) | សំដៅដល់រចនាសម្ព័ន្ធនៃស្ថានភាពរបស់ប្រជាជន ដោយផ្អែកលើកត្តា អាយុ ភេទ អត្រាកំណើត ជាដើម ។ល។ |
| ៣ | កម្មវិធីជាតិជំនួយសង្គម (Social Assistance Program) | សំដៅដល់កម្មវិធីដែលទ្រទ្រង់ដោយថវិកាជាតិ សម្រាប់ផ្តល់ការគាំពារ ជាពិសេសដល់ជនក្រីក្រ និងងាយរងគ្រោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ ក្នុងការរស់នៅប្រចាំថ្ងៃ។ |
| ៤ | កម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ (VSTP) | គឺជាកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនក្រីក្រដែលរស់នៅតាមសហគមន៍ជនបទ ជនជាតិភាគតិច និងអ្នកបោះបង់ការសិក្សា ឲ្យទទួលបាននូវជំនាញក្នុងការបង្កើតអាជីវកម្មដើម្បីចិញ្ចឹមជីវិត។ |
| ៥ | ការធានារ៉ាប់រងបន្ត (Re-insurance) | សំដៅដល់យន្តការក្នុងការចែករំលែកហានិភ័យមួយផ្នែកទៅកាន់ស្ថាប័នមួយទៀត ដែលមានជំនាញនៅក្នុងការគ្រប់គ្រងហានិភ័យ (អ្នកធានារ៉ាប់រងបន្ត)។ |
| ៦ | ការបណ្តុះបណ្តាលស្ពានចម្លងជំនាញ (Skill Bridging Program) | សំដៅដល់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលផ្តល់មូលដ្ឋានគ្រឹះ ដើម្បីឈានទៅទទួលយកកម្មវិធីបណ្តុះបណ្តាលជំនាញជាក់លាក់ណាមួយ។ |
| ៧ | គណនេយ្យភាព (Accountability) | សំដៅដល់ការទទួលខុសត្រូវចំពោះសកម្មភាព និងការសម្រេចចិត្តនានា ដែលបានអនុវត្តនៅក្នុងតួនាទី ភារកិច្ច និងដែនសមត្ថកិច្ចរបស់ខ្លួន។ |
| ៨ | តម្លាភាព (Transparancy) | សំដៅដល់ការអនុញ្ញាតឲ្យភាគីពាក់ព័ន្ធទាំងអស់ ទទួលបានព័ត៌មានត្រឹមត្រូវ និងគ្រប់គ្រាន់ ទៅតាមមុខងាររៀងៗខ្លួន។ |
| ៩ | តាវកាលិក (Benefit) | សំដៅដល់អត្ថប្រយោជន៍ដែលសមាជិកនៃរបបសន្តិសុខសង្គមទទួលបានពីសមាជិកភាពនៃរបបសន្តិសុខសង្គម |
| ១០ | និកម្មភាព (Unemployment) | សំដៅដល់ភាពគ្មានការងារធ្វើរបស់ប្រជាជនដែលស្ថិតនៅក្នុងកម្លាំងពលកម្ម។ |
| ១១ | បរិយាប័ន្ន (Inclusion) | សំដៅដល់ការដាក់បញ្ចូលប្រជាពលរដ្ឋគ្រប់រូប ទៅក្នុងប្រព័ន្ធគាំពារសង្គម។ |
| ១២ | ប្រព័ន្ធទទួលស្គាល់គុណភាព (Accreditation System) | សំដៅដល់យន្តការរបស់ក្រសួងសុខាភិបាលដើម្បីកំណត់កម្រិតគុណភាព នៃមូលដ្ឋានសុខាភិបាលរបស់រដ្ឋ និងឯកជន។ |

| | | |
|---|---|---|
| ១៣ | ពិការភាព ( Disability ) | សំដៅដល់ភាពខ្វះខាត បាត់បង់ ខូចខាតសរីរាង្គណាមួយ ឬសតិបញ្ញា ដែលបណ្តាលឲ្យមានការរំខានដល់ជីវភាពរស់នៅ ឬសកម្មភាពនានាប្រចាំថ្ងៃ ដូចជាជនពិការរាងកាយ ពិការភ្នែក ពិការក្នុងការស្តាប់ ពិការសតិបញ្ញា មនសិការវិកល និងប្រភេទពិការផ្សេងៗទៀត ដែលនាំឲ្យមានលក្ខណៈមិនប្រក្រតី។ |
| ១៤ | ពិពិធកម្មវិនិយោគ ( Investment Diversification ) | សំដៅដល់ការវិនិយោគដែលមិនពឹងផ្អែកទៅលើតែឧបករណ៍ហិរញ្ញវត្ថុមួយប្រភេទ។ |
| ១៥ | ភាគទាន ( Contribution ) | សំដៅដល់ប្រាក់ដែលត្រូវបង់ ដោយសមាជិក និង/ឬក្នុងនាមសមាជិក ចូលទៅក្នុងរបបណាមួយនៃប្រព័ន្ធសន្តិសុខសង្គម។ |
| ១៦ | មូលបត្ររដ្ឋ ( Government Securities ) | សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលបោះផ្សាយដោយរាជរដ្ឋាភិបាល។ |
| ១៧ | លំហថវិកាជាតិ ( Fiscal Space ) | សំដៅដល់ថវិការដ្ឋមួយចំណែកដែលអាចយកទៅប្រើប្រាស់ក្នុងគោលដៅណាមួយ ដោយមិនប៉ះពាល់ដល់ចីរភាពនៃថវិកា។ |
| ១៨ | សង្គតិភាព ( Consistency ) | សំដៅដល់ ភាពដូចគ្នា ឬប្រទាក់ក្រឡាគ្នា ឬប្រហាក់ប្រហែលគ្នា។ |
| ១៩ | សង្គមចាស់ជរា ( Aging Society ) | សំដៅដល់សង្គមមួយដែលចំនួននៃមនុស្សចាស់ ច្រើនជាងចំនួនប្រជាជនក្នុងវ័យពលកម្ម។ |
| ២០ | សញ្ច័យហិរញ្ញវត្ថុ ( Financial Saving ) | សំដៅដល់ការសន្សំប្រាក់គ្រប់រូបភាព ទាំងការសន្សំ ទូទៅ និងការសន្សំក្នុងរូបភាពជាការវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុ។ |
| ២១ | សមតុល្យជញ្ជីងទូទាត់ ( Balance of Payment ) | សំដៅដល់តម្លៃនៃការទូទាត់ផ្នែកពាណិជ្ជកម្មរបស់ប្រទេសមួយជាមួយប្រទេសផ្សេងទៀត នៅក្នុងអំឡុងពេលមួយជាក់លាក់។ |
| ២២ | សមធម៌ ( Equity ) | សំដៅដល់ភាពសមរម្យនៃការផ្តល់ជូន ឬទទួលបានអ្វីមួយ ដែលកម្រិតនៃការផ្តល់ជូន ឬទទួលបាននោះ ត្រូវបានកំណត់ដោយផ្អែកលើចរិតលក្ខណៈនៃបុគ្គលនីមួយៗ។ |
| ២៣ | សមភាព ( Equality ) | សំដៅដល់ភាពស្មើគ្នានៃការផ្តល់ជូន ឬទទួលបានអ្វីមួយ ដោយមិនផ្អែកលើចារិតលក្ខណៈនៃបុគ្គលនីមួយៗនោះឡើយ។ |
| ២៤ | សមាហរណកម្ម ( Integration ) | សំដៅដល់ការដាក់បញ្ចូលនៃសមាសធាតុតូចៗ ឲ្យទៅជាប្រព័ន្ធតែមួយ។ |
| ២៥ | សសរស្តម្ភ ( Pillar ) | សំដៅដល់ធាតុផ្សំសំខាន់ៗ សម្រាប់ទ្រទ្រង់ ប្រព័ន្ធ ឬគោលនយោបាយណាមួយ។ |
| ២៦ | ស្ថាប័នបញ្ញត្តិករ ( Operator ) | សំដៅដល់ស្ថាប័នដែលទទួលបន្ទុករៀបចំ និងដាក់ឲ្យអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ផ្សេងៗ។ |
| ២៧ | ស្ថាប័នប្រតិបត្តិករ ( Regulator ) | សំដៅដល់ស្ថាប័នដែលទទួលបន្ទុកអនុវត្តគោលនយោបាយនីមួយៗ ដោយផ្ទាល់។ |
| ២៨ | ហានិភ័យ ( Risk ) | សំដៅដល់ឱកាសដែលបញ្ហាអវិជ្ជមានណាមួយអាចកើតឡើង។ |

| | | |
|---|---|---|
| ២៩ | អតិផរណា (Inflation) | សំដៅដល់ការឡើងថ្លៃជាទូទៅរបស់ទំនិញ ឬសេវានានានៅក្នុងសេដ្ឋកិច្ច។ |
| ៣០ | ឧត្តមភាពប្រៀបធៀប (Comparative Advantage) | សំដៅដល់អត្ថប្រយោជន៍ដែលបានមកពីអ្វីដែលយើងមាន ឬផលិតបានច្រើនជាង និងល្អជាង។ |
| ៣១ | ឧត្តរជីវី (Survivor) | សំដៅដល់អ្នកនៅក្នុងបន្ទុកដែលនៅរស់រានមានជីវិត របស់សមាជិករបបសន្តិសុខសង្គម ដែលទទួលមរណៈភាព។ |
| ៣២ | អភិបាលកិច្ច (Governance) | សំដៅដល់ការគ្រប់គ្រង ដឹកនាំ និងចាត់ចែងស្ថាប័ន ឬកិច្ចការអ្វីមួយ។ |
| ៣៣ | អាយុកាលសង្ឃឹមរស់ (Life Expectancy) | សំដៅដល់អាយុរស់នៅមធ្យម របស់ប្រជាជននៃប្រទេសណាមួយ។ |
| ៣៤ | អ្នកទូទាត់តែមួយ (Single Payer) | សំដៅដល់យន្តការដែលអនុញ្ញាតឲ្យស្ថាប័នប្រតិបត្តិករតែមួយគត់ទទួលបន្ទុកអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ប្រជាពលរដ្ឋគ្រប់រូប។ |

**ឧបសម្ព័ន្ធ២**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥២ . សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារបច្ចេកទេសសម្រាប់រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១** . -

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសសម្រាប់រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម សម្រាប់ប្រទេសកម្ពុជា ដែលមានសមាសភាព ដូចខាងក្រោម÷

| | | | | |
|---|---|---|---|---|
| ១ | លោកជំទាវ | **ខួន សុខា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២ | ឯកឧត្តម | **ភាន់ម៉ន** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣ | ឯកឧត្តម | **សំហេង បូរស** | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៤ | ឯកឧត្តម | **ង៉ាន ប៊ុនធឿន** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៥ | ឯកឧត្តម | **ទិន សុខឃួន** | អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ៦ | លោកជំទាវ | **អ៊ុំ សាម៉ុល** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៧ | ឯកឧត្តម | **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយក-ដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៨ | ឯកឧត្តម | **សាន វឌ្ឍនា** | អគ្គលេខាធិការរងនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | សមាជិក |
| ៩ | ឯកឧត្តម | **ចាន់ សុធី** | អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១០ | ឯកឧត្តម | **ផាន់ ផល្លា** | អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១១ | ឯកឧត្តម | **ម៉ី ស៊ាន់** | អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១២ | លោក | **ប៊ូ ចន្ទតីរូ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៣ | លោក | **ឆាយ រតនៈ** | ប្រធាននាយកដ្ឋានធានារ៉ាប់រង និង សោធននៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៤ | លោក | **ភក្តី សម្បូរណ៍** | ប្រធានការិយាល័យសោធននៃនាយកដ្ឋានធានារ៉ាប់រង និងសោធននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | លេខាធិការ |

**ប្រការ២** . -

ក្រុមការងារបច្ចេកទេសសម្រាប់រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម មានមុខងាររៀបចំ និង តាក់តែងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម សំដៅជំរុញការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា ឱ្យមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព ប្រសិទ្ធភាព ចីរភាព និងស្ថិរភាពហិរញ្ញវត្ថុ និងមានតួនាទី និងភារកិច្ច ដូច ខាងក្រោម÷

- សិក្សា និងរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គម ឱ្យមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព ប្រសិទ្ធភាព ចីរភាព និងស្ថេរភាពហិរញ្ញវត្ថុ
- សិក្សាវិភាគគ្រប់ជ្រុងជ្រោយលើស្ថានភាពបច្ចុប្បន្ននៃគោលនយោបាយ និងការអនុវត្តគោលនយោបាយរបបសន្តិសុខសង្គមក្នុងប្រទេសកម្ពុជា ដោយលើកអនុសាសន៍ពីការកំណែទម្រង់រចនាសម្ព័ន្ធក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់ រួមទាំងសិក្សា និងរៀបចំក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិចាំបាច់ ដើម្បីជំរុញឱ្យដំណើរការនៃប្រព័ន្ធសន្តិសុខសង្គមទាំងមូលប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់ប្រកបដោយតម្លាភាព គណនេយ្យភាព និងចីរភាព
- រៀបចំក្របខ័ណ្ឌគោលនយោបាយសម្រាប់ប្រព័ន្ធសន្តិសុខសង្គមទាំងមូលរបស់កម្ពុជា ដើម្បីដាក់ជូនរាជរដ្ឋាភិបាលអនុម័ត
- សិក្សា និងលើកអនុសាសន៍អំពីការកំណត់អត្រាវិភាគទានសម្រាប់ទ្រទ្រង់ និងការកំណត់តាវកាលិកនៃរបបសន្តិសុខសង្គមនីមួយៗដោយគិតគូរឱ្យបានច្បាស់លាស់អំពីផលប៉ះពាល់នានា ដែលពាក់ព័ន្ធទៅនឹងបន្ទុកថវិការដ្ឋ និងបន្ទុករបស់អ្នកពាក់ព័ន្ធផ្សេងទៀត ដូចជា៖ មន្ត្រីរាជការ នគរបាល ទាហាន និងកម្មករនិយោជិត ព្រមទាំងនិយោជក ផងដែរ
- សិក្សា និងលើកអនុសាសន៍អំពីគោលនយោបាយពន្ធដារដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការនៃរបបសន្តិសុខសង្គមនីមួយៗ សំដៅទ្រទ្រង់ការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គម
- ពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធនានា ទាំងស្ថាប័នរដ្ឋ និងឯកជន ដើម្បីទទួលបានធាតុចូលបន្ថែមសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម ឱ្យមានលក្ខណៈតថភាព និងអាចអនុវត្តបាន
- ពិគ្រោះយោបល់ជាមួយអ្នកជំនាញការ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គមឱ្យស្របតាមស្តង់ដារ និងនិយាមអន្តរជាតិ
- ពិនិត្យឡើងវិញជាប្រចាំលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម ឱ្យស្របតាមនិន្នាការ និងការវិវឌ្ឍជាសកល
- រាយការណ៍ជាប្រចាំជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីវឌ្ឍនភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម ។

**ប្រការ៣ .-**

ក្រុមការងារបច្ចេកទេសសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម មាននាយកដ្ឋានធានារ៉ាប់រង និងសោធន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាលេខាធិការដ្ឋាន ។

**ប្រការ៤** . -

សមាជិកនៃក្រុមការងារបច្ចេកទេសសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គមត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ឬអនុប្រធាន (តាមការចាត់តាំងរបស់ប្រធាន) ករណីប្រធានអវត្ត-មាន ។

**ប្រការ៥** . -

សេចក្ដីសម្រេចលេខ ១៥៣ សសរចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការបង្កើតក្រុមការងារបច្ចេកទេសសម្រាប់រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសោធនត្រូវទុកជានិរាករណ៍ ។

**ប្រការ៦** . -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញ-វត្ថុ ប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍កសិកម្ម និងជនបទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ១ មានភារ-កិច្ចអនុវត្តសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន
  នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ